Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

# ការរក្សាបាននូវកំណើនខ្ពស់

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា





**ប្រធានបទពិសេស៖**

បញ្ហាដុល្លាររូបនីយកម្ម៖ គុណសម្បត្តិ គុណវិបត្តិ និងកិច្ចការបន្ទាប់

WORLD BANK GROUP

ខែមេសា ឆ្នាំ២០១៥

# ការរក្សាបាននូវកំណើនខ្ពស់

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែមេសា ឆ្នាំ២០១៥

WORLD BANK GROUP

@ រក្សាសិទ្ធិគ្រប់យ៉ាង

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជាផលិតផលរបស់ធនាគារពិភពលោក។

របកគំហើញ ការបកស្រាយ និងការសន្និដ្ឋាន នៅក្នុងបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ គឺជារបកគំហើញ ការបកស្រាយ និងការសន្និដ្ឋានរបស់បុគ្គលិកធនាគារពិភពលោក ហើយមិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់គណៈគ្រប់គ្រងរបស់ធនាគារ របស់ក្រុមប្រឹក្សាភិបាល ឬរដ្ឋាភិបាលដែលធនាគារពិភពលោកតំណាងនោះទេ។

ធនាគារពិភពលោកមិនធានាពីភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងវណ្ណកម្មនេះទេ។

# អារម្ភកថា និងសេចក្តីថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) គឺជាផលិតផលមួយរបស់បុគ្គលិករបស់ធនាគារពិភពលោក។ ផលិតផលនេះត្រូវបានរៀបចំដោយ លោក លី សូដេត (Sodeth Ly) និង លោក អេនរិកកេ អាល់ដាហ្ស ខារ៉ូល (Enrique Aldaz–Carroll)ការអនុវត្តជាសាកលនៃផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធ (MFMGP) ការិយាល័យធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ កញ្ញា គី លីនណា (Linna Ky) មានតួនាទីជាជំនួយការស្រាវជ្រាវ។ ក្រុមការងារធ្វើការក្រោមការដឹកនាំរបស់លោក ម៉ាសូ អេ វើហ្គិស (Mathew A. Verghis) អ្នកគ្រប់គ្រងនៃការអនុវត្តជាសាកលនៃផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធ។ លោកស្រី ការ៉ូលីណា មេជា ម៉ែនទីឡា (Carolina Mejia-Mantilla) ការអនុវត្តជាសាកលនៃផ្នែកកាត់បន្ថយ ភាពក្រីក្របានរួមចំណែកអត្ថបទផ្នែកភាពក្រីក្រនៅក្នុងរបាយការណ៍នេះ។ ក្រុមការងារសូមថ្លែងអំណរគុណ ចំពោះយោបល់ការប្រឹក្សា និងការណែនាំ ដែលលោកអូលរិក ហ្សាចៅ (Ulrich Zachau) នាយកប្រចាំប្រទេស លោកអាឡាសាន សូ (Alassane Sow) នាយកគ្រប់គ្រង និង លោក សាបីស អាលី មូហីប (Shabih Ali Mohib) ប្រធានកម្មវិធី បានផ្តល់ជូន។

របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានផលិតឡើងពីរដងក្នុងមួយឆ្នាំ ដើម្បីផ្តល់ព័ត៌មានថ្មីៗអំពីវឌ្ឍនភាពផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានបោះពុម្ពផ្សាយ និងចែកចាយយ៉ាងទូលំទូលាយទៅកាន់អាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមអ្នកវិភាគ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ ។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានកំណត់ពេលចេញឲ្យស្របជាមួយនឹងការបោះពុម្ពរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ារបស់ការអនុវត្តជាសាកលនៃផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធ (MFMGP) នៃធនាគារពិភពលោក។

យើងបានទទួលយោបល់ និងសំណើដ៏មានតម្លៃពីលោកនីកូលា ស្បាតាហ្វូរ៉ា (Nokola L. Spatafora) ការិយាល័យប្រធានសេដ្ឋវិទូប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក លោករ៉ាហ្វ វ៉ាន់ ឌន (Ralph van Doorn) ការអនុវត្តជាសាកលនៃផ្នែកម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងសារពើពន្ធ និង ដែល លោកស្រី រ៉ាឆាដា អនាន់តាវ៉ាស៊ីលប៉ា (Ratchada Anantavrasilpa) ការអនុវត្តជាសាកលនៃផ្នែកហិរញ្ញវត្ថុ និងទីផ្សារ។ របាយការណ៍នេះក៏ទទួលបានការរួមចំណែកតាមរយៈការផ្តល់ជូនយោបល់ ការណែនាំ និងទស្សនៈរបស់ភាគីពាក់ព័ន្ធជាច្រើននៅក្នុងរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអ្នកសិក្សាស្រាវជ្រាវ។ ក្រុមការងារសូមអរគុណចំពោះពួកគាត់ដែលបានចំណាយពេល និងផ្តល់ការរួមចំណែក។

យើងសូមថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះអាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ពួកគាត់ក្នុងការរៀបចំរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ។

ក្រុមការងារផ្នែកទំនាក់ទំនងនៅកម្ពុជា ដែលរួមមានលោក ប៊ូ សារឿន (Saroeun Bou) និងលោកស្រី សុភានិត សំអឿន (Sophinith Sam Oeun) បានរៀបចំអត្ថបទផ្សព្វផ្សាយតាមសារព័ត៌មាន អត្ថបទបង្ហាញតាមគេហទំព័រ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារពិភពលោកនៅកម្ពុជា សូមចូលទៅមើលនៅ www.worldbank.org/cambodia។

ដើម្បីមានឈ្មោះនៅក្នុងបញ្ជីចែកចាយរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាតាមអ៊ីម៉ែល និងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធ សូមទាក់ទង កញ្ញា គី លីនណា តាមសារអេឡិកត្រូនិច lky@worldbank.org។ សម្រាប់សំណួរ ស្ដីពីខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

# មាតិកា

ខ្លឹមសារសង្ខេប ... i

វឌ្ឍនភាពផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗនេះ ... 1

១ វិស័យផលិតកម្ម ... 1

ក) វិស័យកាត់ដេរ ... 4

ខ) វិស័យសំណង់ និងអចលនទ្រព្យ ... 4

គ) វិស័យទេសចរណ៍ ... 5

ឃ) វិស័យកសិកម្ម ... 6

២ វិស័យទូទាត់ក្រៅប្រទេស ... 7

ក) ការនាំចេញ ... 8

ខ) ការនាំចូល ... 9

៣ អតិផរណា ... 9

៤ វិស័យរូបិយវត្ថុ ... 10

ក) រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រា ប្តូរប្រាក់ ... 10

ខ) វិស័យធនាគារ ... 12

៥ វិស័យសារពើពន្ធ ... 13

ក) សមាសភាគចំណូល ... 14

ខ) សមាសភាគចំណាយ ... 15

គ) តុល្យភាពសារពើពន្ធ ... 15

ឃ) ថវិកាឆ្នាំ ២០១៥ ... 15

៦ ការកាត់បន្ថយភាពក្រីក្រ ... 19

សារគន្លឹះ និងអនុសាសន៍ ... 21

ប្រធានបទពិសេស ៖ បញ្ហាដុល្លារូបនីយកម្ម ៖ គុណសម្បត្តិ គុណវិបត្តិ និងកិច្ចការបន្ទាប់ ... 24

១ ការជំរុញទឹកចិត្ត ... 24

២ សាវតារ ... 24

៣ គុណសម្បត្តិ ... 25

៤ គុណវិបត្តិ ... 26

៥ កិច្ចការបន្ទាប់ ... 29

សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា ... 32

# ខ្លឹមសារសង្ខេប

***ប្រទេសកម្ពុជានៅតែបន្តមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ទោះបីជាមានល្បឿនកំណើនយឺតបន្តិចក្តី។***
*កំណើនពិតសម្រាប់ឆ្នាំ ២០១៤ ត្រូវបានប៉ាន់ស្មានថាមានចំនួន ៧ភាគរយ។ វិស័យកាត់ដេរសម្លៀកបំពាក់ ជាមួយនឹងវិស័យសំណង់ និង សេវាកម្មជាពិសេសហិរញ្ញវត្ថុ និងអចលនទ្រព្យ នៅតែបន្តជំរុញកំណើនដដែល។ យ៉ាងណាក៏ដោយ មានសញ្ញាណមួយចំនួនដែលបង្ហាញពីចំណុចខ្សោយផ្នែកផលិតសម្លៀកបំពាក់ និងកសិកម្ម ដែលកំពុងធ្វើឲ្យល្បឿនកំណើនយឺតបន្តិច។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចជារួម នៅតែមានភាពសមស្របដដែល។ ការពង្រឹងផ្នែកសារពើ ពន្ធនៅតែបន្តមាន ដោយមានកំណើនបន្ថែម ទៀតក្នុងការប្រមូលចំណូល ដែលបានមកពីការគ្រប់គ្រងចំណូល មានភាពប្រសើរជាងមុន។ ភាពក្រីក្រនៅតែបន្តថយចុះក្នុងប្រទេសកម្ពុជា (នៅឆ្នាំ ២០១២ អត្រានៃភាពក្រីក្រមានចំនួន ១៧,៧ ភាគរយ) បើទោះជាល្បឿននៃការកាត់បន្ថយភាពក្រីក្រ ថយចុះខ្លាំងក៏ដោយ។ អត្រាកំណើន ពិតនៅក្នុងប្រទេសកម្ពុជាត្រូវបានរំពឹងថាថយចុះ មកនៅ ៦,៩ ភាគរយនៅក្នុងឆ្នាំ ២០១៥ និង ២០១៦ ដោយសារកម្ពុជាត្រូវប្រឈមមុខនឹងការ ប្រកួតប្រជែងខ្លាំងជាងមុនក្នុងការនាំចេញនូវ សម្លៀកបំពាក់ ការបន្តធ្លាក់ចុះនៃកំណើនក្នុង វិស័យកសិកម្ម និងកំណើនតិចជាងមុនក្នុង វិស័យទេសចរណ៍។*

*វឌ្ឍនភាពថ្មីៗ*

**វិស័យកាត់ដេរសម្លៀកបំពាក់នៅតែជាម៉ាស៊ីនមួយក្នុងចំណោមម៉ាស៊ីនសំខាន់ៗ ជំរុញកំណើនរបស់ប្រទេសកម្ពុជា។** បើទោះជាវិស័យកាត់ដេរសម្លៀកបំពាក់នៅកម្ពុជានៅតែបន្តកើនឡើង ថ្មីៗនេះ វិស័យនេះបានជួបប្រទះការប្រកួតប្រជែង ខ្លាំងជាងមុន ដែលកើតឡើងដោយសារតែការបន្តកំណើនតម្លៃប្រាក់ដុល្លាអាមេរិក ការលេចឡើងនូវអ្នកប្រកួតប្រជែងក្នុងតំបន់ ដែលផ្តល់ប្រាក់ឈ្នួលទាប ជាពិសេសប្រទេសមីយ៉ាន់ម៉ា និងផលប៉ះពាល់រយៈពេលយូរនៃ ការរំជើបរំជួលក្នុងទីផ្សារពលកម្មនាពេលកន្លងមក ទៅលើការបញ្ជាទិញសម្លៀកបំពាក់។ ការនាំចេញផលិតផលសម្លៀកបំពាក់ មានចំនួនកំណើនត្រឹម ៩,២ ភាគរយ (គិតជាតម្លៃ) និង ១១,២ ភាគរយ (គិតជាបរិមាណ) ក្នុងឆ្នាំ ២០១៤ បើធៀបនឹងឆ្នាំ២០១៣ អត្រាកំណើននេះមានចំនួន ១៧,៦ ភាគរយ (គិតជាតម្លៃ) និង ១៣,៤ ភាគរយ (គិតជាបរិមាណ) វិស័យសំណង់នៅតែមានភាពរឹងមាំ ដោយសារតែការទទួលបានទំនុកចិត្តធុរកិច្ចឡើងវិញ និងភាពប្រសើរឡើង នៃស្ថិរភាពនយោបាយក្នុងប្រទេស។ អត្រាកំណើន នៃការចូលទស្សនានៃភ្ញៀវទេសចរឆ្នាំ២០១៤ មានការថយចុះបន្តិច ដោយមានកំណើនត្រឹមតែ ៦,៩ ភាគរយ បើធៀបនឹងឆ្នាំ ២០១៣ អត្រាកំណើននេះមានចំនួន ១៧,៥ ភាគរយ។ វិស័យកសិកម្ម ដែលជួយដល់ ប្រជាជនក្រីក្រក្នុងប្រទេសកម្ពុជា ដែលមានកំណើនខ្លាំងនាពេលកន្លងមក ដោយសារតែការដាំដំណាំ ជាពិសេសស្រូវនោះ ថ្មីៗនេះមានការថយចុះសំខាន់

ដោយសារតែតម្លៃផលិតផលកសិកម្មមានការថយចុះ ហើយការបង្កើនទិន្នផល មានភាពយឺតយ៉ាវ។

**វិស័យទូទាត់ក្រៅប្រទេស នៅតែមានស្ថិរភាព ដោយសារតែ លំហូរវិនិយោគផ្ទាល់ពីបរទេសមានភាពប្រសើរ ដែលទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។** ដោយសារតែការនាំចេញមានការថយចុះ ឱនភាពគណនីចរន្ត (មិនគិតការបង្វែរផ្លូវការ) បានកើនឡើងបន្តិចទៅដល់ តាមការប៉ាន់ស្មាន ១១,២ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ ដែលបានទទួលហិរញ្ញប្បទានជា ចម្បងមកពីការវិនិយោគផ្ទាល់ពីបរទេសដែលភាគ ច្រើននៅក្នុងវិស័យទេសចរណ៍ កាត់ដេរសម្លៀកបំពាក់ និងសំណង់។ ទុនបម្រុងអន្តរជាតិដុលមានការកើនឡើងរហូតដល់កម្រិតមួយ ដែលមិនធ្លាប់មានកន្លងមកគឺ ៤,៦ ពាន់លានដុល្លាអាមេរិក ឬប្រហែលជា ៤ខែនៃការនាំចូល គិតត្រឹមបំណាច់ឆ្នាំ២០១៤។

**ការកំណត់អត្រាប្តូរប្រាក់ បន្តគាំទ្រស្ថិរភាពតម្លៃ។** យ៉ាងណាក៏ដោយ ការកំណត់អត្រាប្តូរប្រាក់ជាមួយដុល្លារូបនីយកម្ម បានកាត់បន្ថយភាពប្រកួតប្រជែងនៃការនាំចេញទៅទីផ្សារអឺរ៉ុប[1]។ នៅពេលដែលប្រាក់ដុល្លាអាមេរិកកើនតម្លៃ ប្រាក់រៀលកម្ពុជាក៏កើនតម្លៃដែរ ដោយគ្រាន់តែថយតម្លៃបន្តិចបើធៀបនឹងដុល្លាអាមេរិក ដោយ ១ ដុល្លាអាមេរិក ប្តូរបាន ៤.០៧៥ រៀល នៅចុងឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ២០១៣វិញ ១ ដុល្លាអាមេរិកប្តូរបានតែ ៣.៩៩៥ រៀលប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ តម្លៃប្រាក់រៀលកើនឡើងប្រមាណ ១៧ ភាគរយ តាំងពីខែកក្កដា ឆ្នាំ២០១៤ មកបើធៀបនឹងប្រាក់អឺរ៉ូ។

**អតិផរណាបានធ្លាក់ចុះយ៉ាងខ្លាំង ដោយតម្លៃម្ហូបអាហារនៅតែបន្តថយចុះ និងការធ្លាក់ចុះតម្លៃប្រេងនាពេលថ្មីៗនេះ។ អតិផរណាបានថយចុះមកត្រឹម ១,២ ភាគរយ នៅចុងឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ ២០១៣ អត្រាអតិផរណា មានប្រមាណ ៤,៦ ភាគរយ។ ចំពោះសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់** សន្ទស្សន៍តម្លៃពីមួយឆ្នាំទៅមួយឆ្នាំនៃទំនិញក្រៅពីគ្រឿងឧបភោគបរិភោគ ដូចជា ថ្លៃផ្ទះ ទឹកភ្លើង និងការធ្វើដំណើរ បានចូលទៅកម្រិតអវិជ្ជមាន ខណៈពេលដែលសន្ទស្សន៍ នៃគ្រឿងឧបភោគបរិភោគបានថយចុះថែមទៀត។ អតិផរណាក្នុងតំបន់ និងនៅប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត នៅតែមានភាពប្រសើរដដែល។

**ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ នៅតែបន្តមានដែលបានជួយគាំទ្រដល់ ការលូតលាស់ផ្នែកសេដ្ឋកិច្ច ដោយសារតែកំណើនប្រាក់បញ្ញើ និងឥណទានមានការកើនឡើងយ៉ាងលឿនក្នុងឆ្នាំ២០១៤។** ប្រាក់បញ្ញើរបស់វិស័យឯកជនមាន ចំនួនរហូតដល់ ៨,៨១ ពាន់លានដុល្លាអាមេរិក ឬមានកំណើន ៣០,៦ ភាគរយ ត្រឹមចុងឆ្នាំ ២០១៤ ធៀបនឹងចុងឆ្នាំ២០១៣ ប្រាក់បញ្ញើក្នុងវិស័យឯកជនមាន៦,៨៨

[1] ការកំណត់អត្រាប្តូរប្រាក់តម្រូវឲ្យធនាគារជាតិនៃកម្ពុជាទិញ (ឬលក់) ប្រាក់ដុល្លាអាមេរិក ដើម្បីរក្សាអត្រាប្តូរប្រាក់រៀល ហើយប្រាក់ដុល្លាអាមេរិកឲ្យនៅថេរ។ នៅពេលដែលលំហូរមូលធន (ប្រាក់ដុល្លាអាមេរិក) មានការកើនឡើង (ថយចុះ) នោះធនាគារជាតិនៃកម្ពុជាបញ្ចូល (ដក) ប្រាក់រៀលដោយទិញ (លក់) ប្រាក់ដុល្លាអាមេរិកដើម្បីរក្សាអត្រាប្តូរប្រាក់រៀល និងប្រាក់ដុល្លា អាមេរិកឲ្យនៅប្រហែល ៤.០០០ រៀល។ ជាលទ្ធផល ទុនបម្រុង អន្តរជាតិមានការកើនឡើង (ថយចុះ)។

ពាន់លានដុល្លាអាមេរិក ឬមានកំណើន ១៤,២ ភាគរយ។ ដោយសារតែបញ្ញើរូបិយប័ណ្ណបរទេស បន្ទាប់ពីមានការជឿទុកចិត្តឡើងវិញទៅលើប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចទាំងមូល កំណើនរូបិយវត្ថុទូទៅបានកើនឡើងទ្វេដង ដោយមានចំនួន២៩,៨ ភាគរយ នៅចុងឆ្នាំ២០១៤ បើធៀបនឹងចុងឆ្នាំ ២០១៣ កំណើននេះមានតែ ១៤,៦ ភាគរយប៉ុណ្ណោះ។ កត្តានេះធ្វើឲ្យដុល្លារូបនីយកម្ម បន្តកើនឡើងទៀត ដោយចំណែកនៃបញ្ញើរូបិយប័ណ្ណបរទេសនៅក្នុងរូបិយវត្ថុទូទៅបានកើនឡើង ដល់ ៨២,៦ ភាគរយនៅចុងឆ្នាំ ២០១៤ ដោយបរិមាណនេះមានតែ ៨២,២ ភាគរយ ប៉ុណ្ណោះនៅចុងឆ្នាំ ២០១៣។ មួយផ្នែកដោយសារតែ កំណើនលឿនក្នុងផ្នែកសំណង់ កំណើនឥណទានដែលបានថយចុះក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៤ បានកើនឡើងវិញនៅក្នុងឆមាសទីពីរក្នុងឆ្នាំនោះ ដោយមានចំនួន ៣១,៣ ភាគរយ នៅចុងឆ្នាំ ២០១៤ ហើយមានទឹកប្រាក់ឥណទាន ដែលមិនទាន់សងចំនួន ៨,៨៩ ពាន់លានដុល្លាអាមេរិក។ ជាលទ្ធផល អនុបាតរវាងប្រាក់កម្ចី និងប្រាក់បញ្ញើបានកើនឡើងពី ៨២,២ ភាគរយនៅពាក់កណ្ដាលឆ្នាំ ២០១៤ មក ៨៧,២ ភាគរយនៅចុងឆ្នាំ ២០១៤ ប៉ុន្តែថយចុះពី ៩០ ភាគរយនៅចុងឆ្នាំ ២០១៣។

**ការពង្រឹងផ្នែកសារពើពន្ធនៅតែបន្ត ហើយការប្រមូលចំណូលដែលកាន់តែប្រសើរឡើង បានផ្ដល់ហិរញ្ញវត្ថុបន្ថែម សម្រាប់កំណើនប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ និងការចំណាយជាអាទិភាព ដោយមិនធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** ដោយសារតែមានកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលក្នុងប្រទេសមានការកើនឡើងបន្ថែមទៀត ហើយត្រូវបានប៉ាន់ប្រមាណថានឹងកើនដល់ ១៦,១ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ បើធៀបនឹងដំណាច់ឆ្នាំ ២០១៣ ការប្រមូលចំណូលក្នុងប្រទេសមានចំនួន ១៥,១ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ការចំណាយនៅតែត្បិតត្បៀតទៅតាមការបែងចែកថវិកាត្រឹម ២០,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ យ៉ាងណាក៏ដោយ ឱនភាពសារពើពន្ធសរុប (រួមទាំងជំនួយឥតសំណង) មានការធ្លាក់ចុះតិចតួចប៉ុណ្ណោះហើយមានប្រមាណ ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដោយសារតែការថយចុះជំនួយឥតសំណង បើធៀបនឹងឆ្នាំ២០១៣ ឱនភាពសារពើពន្ធសរុបកើនឡើងរហូតដល់ ២,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ ហេតុដូច្នេះប្រាក់បញ្ញើរដ្ឋាភិបាលកើនឡើងរហូតដល់ ១,១ ពាន់ លានដុល្លាអាមេរិក ត្រឹមចុងឆ្នាំ ២០១៤ ធៀបនឹង ចុងឆ្នាំ២០១៣ ប្រាក់បញ្ញើរដ្ឋាភិបាលមានត្រឹមតែ ៧០០ លានដុល្លាអាមេរិកប៉ុណ្ណោះ ដោយប្រាក់នេះអាចជួយការពារសារពើពន្ធទប់ទល់ទៅនឹង ការប្រែប្រួលផ្សេងៗ។ ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលរបស់ប្រទេសកម្ពុជា ដែលត្រូវបានវាយតម្លៃដោយការវិភាគរួមគ្នារវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិពីនិរន្តរភាពបំណុល (DSA) ដែលបានធ្វើឡើងក្នុងឆ្នាំ ២០១៣ បង្ហាញថានៅមានកម្រិតទាបនៅឡើយទេ។ អនុបាតបំណុលសាធារណៈធៀបនឹងផលិតផលក្នុងស្រុកសរុបត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ៣៣,៩ ភាគរយត្រឹមចុងឆ្នាំ ២០១៤។

**ជារួម កំណើនសេដ្ឋកិច្ចបានជួយដល់ប្រជាជនក្រីក្រនាពេលថ្មីៗកន្លងមកនេះ។** អត្រាភាពក្រីក្រនៅតែបន្តធ្លាក់ចុះ។ នៅឆ្នាំ២០១២ អត្រាភាពក្រីក្រ (យោងតាមបន្ទាត់ក្រីក្រជាតិ) មានចំនួន ១៧,៧ ភាគរយ ដែលទាបជាងអត្រាភាពក្រីក្រកាលពីឆ្នាំ

២០១១ ស្មើរតែចំនួន៣ ភាគរយ[2]។ កំណើនសេដ្ឋកិច្ច ផ្តល់អត្ថប្រយោជន៍ដល់គ្រួសារ ដែលមានប្រាក់ចំណូលទាបច្រើនជាងគ្រួសារ ដែលមានប្រាក់ចំណូលខ្ពស់ជាង។ ការប្រើប្រាស់របស់អ្នកដែលស្ថិតនៅកម្រិត ៤០ ភាគរយខាងក្រោមនៃរបាយនៃការប្រើប្រាស់ បានកើនឡើងដោយមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ៧ ភាគរយ ក្នុងអំឡុងឆ្នាំ ២០០៧-២០១២ នៅខណៈដែលអត្រាកំណើនសរុបមានតែ ៣,៦ប៉ុណ្ណោះ។ នេះដោយសារតែវិស័យកសិកម្មដែលមានថាមពល។ ស្របពេលជាមួយគ្នានេះដែរ វិសមភាពមានភាពប្រសើរឡើងវិញ មេគុណ Gini ថយចុះពី៣២ ឆ្នាំ២០០៨ មក ២៨ក្នុងឆ្នាំ២០១២។ យ៉ាងណាក៏ដោយ អត្រាកំណើនសមភាព បានថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

## *ស្ថានភាពនាពេលអនាគត*

**ស្ថានភាពកំណើននាពេលអនាគតនៅតែមានភាពល្អប្រសើរដោយសារមានការជឿទុកចិត្តសាជាថ្មី។** ការធ្លាក់ចុះខ្លាំងនៃតម្លៃប្រេង នឹងជួយទប់ថ្លៃដើមផលិតកម្ម និងកែលម្អស្ថានភាពគណនីចរន្តរបស់កម្ពុជា។ កម្ពុជាត្រូវបានប៉ាន់ប្រមាណថានឹងបានចំណេញប្រមាណ ០,៥ នៃផលិតផលក្នុងស្រុកសរុបដោយសារតម្លៃប្រេងធ្លាក់ចុះនៅឆ្នាំនេះ។ កំណើនផលិតផលក្នុងស្រុកសរុបត្រូវបានប៉ាន់ប្រមាណថានឹងចុះថយបន្តិចប្រមាណ ៦,៩ ភាគរយក្នុងឆ្នាំ ២០១៥ ដោយសារតែម៉ាស៊ីនសេដ្ឋកិច្ចសំខាន់ៗមានកំណើនយឺតជាងមុន។ ទោះបីជាមានការរំពឹងទុកថា សកម្មភាពក្នុងវិស័យសំណង់នៅតែមានភាពសកម្មក៏ដោយ ក៏នៅមានសញ្ញាទន់ខ្សោយក្នុងវិស័យកាត់ដេរ និងកសិកម្មដដែល។ ការកើនឡើងនៃថ្លៃដើម ការកើនតម្លៃប្រាក់ដុល្លាអាមេរិក និងអ្នកប្រកួតប្រជែងថ្មីនឹងបន្តប៉ះពាល់ដល់កំណើននាំចេញសម្លៀកបំពាក់។ ដោយសារការថយចុះតម្លៃ ផលិតផលកសិកម្មក្នុងទីផ្សារអន្តរជាតិ និងកំណើនទិន្នផលដំណាំយឺត កំណើនវិស័យកសិកម្មនឹងនៅតែទាបដដែល។

**ហានិភ័យមួយចំនួន ដែលអាចធ្វើឲ្យប៉ះពាល់ដល់អត្រាកំណើនសេដ្ឋកិច្ចដែលបានប៉ាន់ប្រមាណ រួមមាន** បញ្ហាប្រឈមក្នុងប្រទេស ដូចជា ភាពរំជើបរំជួលនៃទីផ្សារពលកម្ម ដែលអាចកើតឡើងជាថ្មី។ បញ្ហាប្រឈមពីខាងក្រៅមានដូចជា ភាពយឺតយ៉ាវនៃការស្តារសេដ្ឋកិច្ចឡើងវិញនៅអឺរ៉ុប និងការបញ្ចេញអង្ករលក់សាជាថ្មីរបស់ប្រទេសថៃ និងមីយ៉ាន់ម៉ា ទៅក្នុងទីផ្សារនាំចេញអង្ករអន្តរជាតិការថយចុះ នៃតម្រូវការនាំចូលអង្កររបស់ប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី និងលទ្ធភាពនៃភាពមិនប្រាកដប្រជាផ្នែកនយោបាយក្នុងតំបន់។

**ក្នុងរយៈពេលពីរបីឆ្នាំខាងមុខ ភាពក្រីក្រនៅតំបន់ជនបទអាចនឹងថយចុះ ក្នុងកម្រិតមួយទាបជាងកាលពីមុន។** កំណើនទិន្នផលដំណាំទាប និងការថយចុះតម្លៃផលិតផលកសិកម្មអន្តរជាតិ នឹងធ្វើឲ្យការកាត់បន្ថយភាពក្រីក្រ នៅតំបន់ជនបទកាន់តែមានការលំបាកថែមទៀត។

**វិសមភាពទំនងនឹងមិនមានការថយចុះក្នុងអនាគតដ៏ខ្លីខាងមុខឡើយ។** ប្រភពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលខ្លី និងមធ្យម ដែលបានប៉ាន់ប្រមាណដូចជា វិស័យសំណង់ កាត់ដេរ និងទេសចរណ៍ នឹងមិនអាចផ្តល់អត្ថប្រយោជន៍ដល់គ្រួសារក្រីក្រច្រើនជាងគេនោះឡើយ។

[2] បន្ទាត់ក្រីក្រជាតិឆ្នាំ២០១២ គឺ ៤.៦៥៤,៧ រៀល (តម្លៃជាក់ស្តែង)

*បញ្ហាប្រឈមដែលលេចឡើងថ្មីៗ និងអនុសាសន៍*

បញ្ហាប្រឈមសំខាន់នាពេលខាងមុខ គឺការជំរុញវិស័យកសិកម្ម វិស័យកាត់ដេរ និង វិស័យទេសចរណ៍ ឲ្យក្លាយជាវិស័យជំរុញកំណើនសេដ្ឋកិច្ចសាជាថ្មី និងកាត់បន្ថយភាពក្រីក្របន្ថែមទៀត។

ការស្ដារឡើងវិញ នូវកំណើនវិស័យកាត់ដេរជាពិសេស កំណើនវិស័យកម្មន្តសាល នឹងក្លាយជាមធ្យោបាយដ៏សំខាន់ក្នុងការរក្សាឲ្យបាននូវកំណើនខ្ពស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ស្ថានភាពនេះអាចសម្រេចទៅបាន ក្នុងរយៈពេលខ្លីរហូតដល់រយៈពេលមធ្យម។ ទីមួយ ដើម្បីបន្តពង្រឹង និងធ្វើពិពិធកម្មទំនិញនាំចេញ ប្រការសំខាន់ត្រូវរក្សាឲ្យបាននូវស្ថិរភាពទីផ្សារការងារ ដើម្បីទទួលបានអត្ថប្រយោជន៍ពីការប្ដូរទីតាំងឧស្សាហកម្ម ពីប្រទេសចិន។ ទីពីរ ប្រការចាំបាច់ត្រូវកែលម្អបរិយាកាសធុរកិច្ចតាមរយៈការសម្រួល និងការធ្វើស្វ័យប្រវត្តិកម្មដល់ដំណើរការចុះបញ្ជីពាណិជ្ជកម្ម និងការសម្របសម្រួលពាណិជ្ជកម្ម និងការពង្រឹងច្បាប់វិនិយោគ(សូមមើលការវាយតម្លៃទៅលើបរិយាកាសនៃការវិនិយោគ របស់ធនាគារពិភពលោក ឆ្នាំ ២០១៤)។ ចុងក្រោយ ផ្ដើមចេញពីទស្សនវិស័យរយៈពេលមធ្យម ការដោះស្រាយបញ្ហាចំណាយខ្ពស់លើអគ្គិសនី ដោយបង្កើនកិច្ចសហការក្នុងការផ្គត់ផ្គង់អគ្គិសនីបន្ថែម ដែលបានពីរោងចក្រវារីអគ្គិសនី និងរោងចក្រដើរដោយថាមពលធ្យូងថ្ម ធ្វើឲ្យមានការកែលម្អប្រកបដោយប្រសិទ្ធភាព និងពង្រឹងតម្លាភាពក្នុងការចែកចាយថាមពល ហើយការផ្គង់ផ្គង់ថាមពលក៏នឹង មានលក្ខណៈវិជ្ជមានផងដែរ។

ដោយសារផ្ទៃដីដាំដុះមានកម្រិត កំណើនផលិតកម្មស្រូវ ដែលកន្លងមកអាស្រ័យលើការពង្រីកផ្ទៃដីដាំដុះ នឹងត្រូវពឹងផ្អែកកាន់តែខ្លាំងលើការបង្កើនទិន្នផល និងគុណភាពស្រូវ។ ជោគជ័យក្នុងការស្ដារកំណើនវិស័យកសិកម្ម ដែលទ្រទ្រង់ដល់ប្រជាជនក្រីក្រ នឹងអាចសម្រេចបានភាគច្រើនក្នុងក្របខ័ណ្ឌរយៈពេលមធ្យម ដោយសារតែការធ្លាក់ចុះតម្លៃផលិតផលកសិកម្ម ខណៈដែលការឆ្លើយតបនឹងការផ្គត់ផ្គង់ អាចត្រូវចំណាយពេលយូរ។ ទីមួយ ការកាត់បន្ថយចំណាយលើផ្នែកភស្តុភារ (ជាមួយនឹង ការបង្កើតក្រុមការងារផ្នែកភស្តុភារសម្រាប់ កិច្ចសហប្រតិបត្តិការអន្តរក្រសួង) និងការចំណាយលើការធ្វើធុរកិច្ច (ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ ដែលធ្វើឲ្យអង្ករកម្ពុជាបាត់បង់ភាពប្រកួតប្រជែង ដែលវាមាននៅពេលប្រមូលផល) អាចធ្វើឡើងក្នុងរយៈពេលដ៏ខ្លី តាមរយៈការខិតខំប្រឹងប្រែងបំផុត។ ទីពីរ ការបន្តបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់អ្នកផលិតស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីបង្កើនបរិមាណអង្ករដែលកិនបាន និងកាត់បន្ថយចំណាយលើថ្លៃកិនស្រូវ ទាមទារពេលវេលាខ្លីទៅមធ្យម។ ចុងក្រោយ ការបង្កើនការវិនិយោគសាធារណៈលើសេវាផ្ដល់ប្រឹក្សាផ្នែកកសិកម្ម ការអភិវឌ្ឍពូជ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការទប់ទល់ទៅនឹងការប្រែប្រួលយ៉ាងលឿន និងការបើកទីផ្សារថ្មី នឹងទទួលផលច្រើន ប៉ុន្តែត្រូវចំណាយពេល និងធនធានយ៉ាងច្រើន។ សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអនុសាសន៍នានា សូមអានការសិក្សារបស់ធនាគារពិភពលោក ស្ដីពី "អន្តរកាលនៃវិស័យកសិកម្ម" ដែលនឹងបោះពុម្ពផ្សាយក្នុងពេលឆាប់ៗនេះ។

**ដើម្បីបង្កើនកំណើនវិស័យទេសចរណ៍ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនពេលវេលា និង ចរិកាដែលភ្ញៀវទេសចរបានចំណាយក្នុងប្រទេសកម្ពុជា។** កិច្ចការនេះអាចធ្វើឡើងតាមរយៈការកែលម្អការដឹកជញ្ជូនតាមផ្លូវគោក (ការផ្សារភ្ជាប់ព្រំដែន ខេត្តសៀមរាប តំបន់ឆ្នេរសំខាន់ៗ និងទីក្រុងភ្នំពេញ)បូករួមនឹងការវិនិយោគកាន់តែច្រើន និង ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋាន វិស័យឯកជន និងសហគមន៍មូលដ្ឋាន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងជួយជំរុញដល់ ការបង្កើនតំបន់ទាក់ទាញភ្ញៀវទេសចរ ក្រៅពីតំបន់ប្រាង្គប្រាសាទបុរាណអង្គរ។ ការបង្កើនតំបន់ទាក់ទាញភ្ញៀវទេសចរក្នុងតំបន់ និងការរៀបចំដំណើរកំសាន្ត ក៏នឹងជួយឲ្យកម្ពុជាចាប់យកចំណែកយ៉ាងធំនៃទីផ្សារទេសចរណ៍ពិភពលោកដែលកំពុងតែ មានការលូតលាស់ផងដែរ។

**ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុដែលកំពុងតែមានការរីកលូតលាស់យ៉ាងលឿន នឹងជំរុញឲ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។** ការពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារ នៅក្នុងវិស័យហិរញ្ញវត្ថុដែលទើបតែចាប់ផ្តើ ប៉ុន្តែមានការរីកលូតលាស់យ៉ាងលឿននេះ នឹងជួយទប់ស្កាត់កុំឲ្យមានពពុះកកើតឡើងក្នុងវិស័យសំណង់ អចលនទ្រព្យក្នុងពេលជាមួយគ្នានោះដែរ ពង្រឹងការទប់ទល់របស់ប្រទេសទៅនឹងការប្រែប្រួលក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ តាមរយៈកិច្ចសហប្រតិបត្តិការអន្តរក្រសួងដ៏រឹងមាំ និងការខិតខំប្រឹង ប្រែង ជោគជ័យក្នុងវិស័យនេះអាចសម្រេចបាន ក្នុងរយៈពេលខ្លីដោយសារតែសមត្ថភាពបច្ចេកទេស និងសមត្ថភាពគ្រប់គ្រងរបស់អាជ្ញាធររូបិយវត្ថុ និងសេដ្ឋកិច្ចត្រូវបានពង្រឹងឡើងវិញបន្ទាប់ពីទទួលបានជោគជ័យជាបន្តបន្ទាប់អស់រយៈពេលជាច្រើនឆ្នាំកន្លងមក។

**ប្រទេសកម្ពុជា នឹងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីការវិនិយោគ និងប្រសិទ្ធភាពចំណាយក្នុងវិស័យសុខាភិបាល អប់រំ និងកិច្ចគាំពារសង្គម ដែលនឹងជួយបង្កើនផលិតភាព និងសុខុមាលភាពយ៉ាងច្រើនទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង។** ទោះបីជាប្រទេសកម្ពុជា មានការកែលម្អសំខាន់ៗនៃកម្រិតគ្រប់ដណ្តប់សេវាក៏ដោយ ក៏កម្រិតការសិក្សាទាប និងកង្វះអាហារូបត្ថម្ភ នៅតែមានច្រើនក្នុងចំណោមប្រជាជនក្រីក្រដដែល។ ទោះបីជាប្រទេសកម្ពុជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏គ្រួសារភាគច្រើនដែលរួចផុតពីភាពក្រីក្រ ចេញផុតពីបន្ទាត់នៃភាពក្រីក្រតែបន្តិចប៉ុណ្ណោះ និងនៅតែស្ថិតនៅក្បែរភាពក្រីក្រនោះដែលធ្វើឲ្យគាត់ងាយរងគ្រោះ។ ការផ្តួចផ្តើមនាពេលថ្មីៗដោយមានការណែនាំ និងផ្តល់មូលនិធិលើមូលនិធិសមធម៌សុខាភិបាល និងសោធននិវត្តន៍ គឺជាវិធានការត្រឹមត្រូវដែលត្រូវអនុវត្ត។ យ៉ាងណាក៏ដោយ ការយល់ដឹងបានល្អអំពីយន្តការដោះស្រាយ ដែលមានសម្រាប់គ្រួសារដែលងាយរងគ្រោះ និងប្រសិទ្ធភាពនៃយន្តការនេះ នឹងជួយកាត់បន្ថយហានិភ័យរបស់ពួកគេក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រជាថ្មីម្តងទៀត។

**ការបន្តពង្រីកមូលដ្ឋានប្រមូលពន្ធ និងការពង្រឹងការគ្រប់គ្រងពន្ធ នឹងជួយបង្កើនការប្រមូលពន្ធដើម្បីផ្តល់ហិរញ្ញប្បទានដល់ការចំណាយលើការអភិវឌ្ឍចាំបាច់ ខណៈដែលកំណើនប្រាក់បៀវត្សរ៍យ៉ាងលឿនទាមទារឲ្យមានការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់។** ការបង្កើនការវិនិយោគសាធារណៈដើម្បីពង្រឹងវិស័យកសិកម្ម និងទេសចរណ៍ ព្រម

ទាំងជួយដល់កំណែទម្រង់រចនាសម្ព័ន្ធរួម ដែលបានលើកឡើងខាងដើម ទាមទារឲ្យមានការពង្រឹងប្រសិទ្ធភាពលើចំណាយសាធារណៈ និងធនធានហិរញ្ញវត្ថុបន្ថែម។ ដូច្នេះប្រការសំខាន់ត្រូវបន្តពង្រឹងការប្រមូលពន្ធក្នុងប្រទេស តាមរយៈការបន្តពង្រីកមូលដ្ឋានប្រមូលពន្ធ និងពង្រឹងការគ្រប់គ្រងពន្ធ។ ការពង្រឹងការប្រមូលពន្ធ នៅតែធ្វើឡើងជាបន្តបន្ទាប់ ហើយប្រការសំខាន់ត្រូវរក្សាឲ្យបាននូវកិច្ចខិតខំប្រឹងប្រែងដើម្បីបន្តពង្រឹងការគ្រប់គ្រង និងអភិបាលកិច្ចល្អ។ ទោះជាការដំឡើងប្រាក់បៀវត្សរ៍ជួយលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការដែលបច្ចុប្បន្នមានប្រាក់បៀវត្សរ៍ទាបក្តី ក៏ប្រាក់បៀវត្សរ៍តែមួយមុខមិនទាន់គ្រប់គ្រាន់ សម្រាប់ការលើកកម្ពស់ ការផ្តល់សេវាសាធារណៈឡើយ។ សំខាន់ត្រូវផ្សារភ្ជាប់ការបង្កើនប្រាក់បៀវត្សរ៍ជាមួយនឹងការកែលម្អការគ្រប់គ្រងធនធានមនុស្ស និងលទ្ធផលការងារ។ លើសពីនេះទៀត ការតម្លើងប្រាក់បៀវត្សរ៍ ទាមទារឲ្យមានការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ដើម្បីធានាថាការដំឡើងប្រាក់បៀវត្សរ៍នេះ រដ្ឋាភិបាលនៅតែមានលទ្ធភាពអាចផ្តល់ឲ្យបាន។

# ខឿ្សនភាពផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗនេះ

## ១ វិស័យផលិតកម្ម

១ **ប្រទេសកម្ពុជា នៅតែបន្តមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំដដែល បើទោះបីជាមានល្បឿនកំណើនយឺតជាងមុនបន្តិចក៏ដោយ។** កំណើនពិតក្នុងឆ្នាំ ២០១៤ ត្រូវបានប៉ាន់ស្មានថានឹងកើនដល់ ៧,០ ភាគរយ (រូបលេខ ១)។ ការនាំចេញសម្លៀកបំពាក់ នៅតែជាម៉ាស៊ីនមួយក្នុងចំណោមម៉ាស៊ីនសំខាន់ៗ ដែលជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាដដែល។ ទោះបីជាកំពុងបន្តរីកចម្រើន និងទាក់ទាញការវិនិយោគបន្ថែមទៀតនោះ ក៏វិស័យកាត់ដេរសម្លៀកបំពាក់នេះ កំពុងប្រឈមនូវបញ្ហាជាច្រើន។ ការប្រឈមទាំងនោះរួមមាន កំណើនតម្លៃប្រាក់ដុល្លាអាមេរិកជាបន្ត ការលេចឡើងនៃអ្នកប្រកួតប្រជែង ក្នុងតំបន់ដែលផ្តល់ប្រាក់ឈ្នួលទាបជាពិសេស ប្រទេសមីយ៉ាន់ម៉ា[3] ហើយនឹងផលប៉ះពាល់យូរ អង្វែងនៃភាពរំជើបរំជួលទីផ្សារពលកម្មកាលពីពេលកន្លងមកលើការបញ្ជាទិញ។ ការនាំចេញសម្លៀកបំពាក់ បានថយចុះមកត្រឹមចំនួនកំណើនប្រចាំឆ្នាំ ៩,២ ភាគរយ គិតជាតម្លៃ និង ១១,២ ភាគរយ គិតជាបរិមាណក្នុងឆ្នាំ ២០១៤ បើធៀបទៅនឹងឆ្នាំ ២០១៣ ចំនួនកំណើនមាន ១៧,៦ ភាគរយ គិតជាតម្លៃ និង ១៣,៤ ភាគរយគិតជាបរិមាណ។ វិស័យសំណង់នៅតែមានភាពរឹងមាំ ដោយទទួលបានទំនុកចិត្តធុរកិច្ច ដោយសារតែស្ថិរភាពនយោបាយក្នុងប្រទេសមានភាព ប្រសើរឡើងវិញ។ អត្រាកំណើននៃភ្ញៀវទេសចរក្នុងឆ្នាំ ២០១៤ មានការថយចុះ ដោយមានអត្រាកំណើនត្រឹមតែ ៦,៩ ភាគរយប៉ុណ្ណោះ ហើយបើធៀបនឹងឆ្នាំ ២០១៣ អត្រាកំណើននេះមានចំនួន ១៧,៥ ភាគរយ។ វិស័យកសិកម្មដែលធ្លាប់តែមានកំណើនយ៉ាងខ្លាំង រហូតដល់ពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានថយចុះនាពេលថ្មីៗនេះ ដោយសារតែការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្ម និងកំណើនទិន្នផលយឺត។

២ **ស្ថានភាពកំណើននាពេលអនាគត នៅតែល្អប្រសើរដដែល ដោយសារតែការទទួលបានទំនុកចិត្តឡើងវិញ។** ការធ្លាក់ចុះយ៉ាងលឿននៃតម្លៃប្រេងនឹងជួយកាត់បន្ថយតម្លៃផលិតកម្ម បង្កើនចំណូលរបស់អ្នកប្រើប្រាស់ និងធ្វើឲ្យស្ថានភាពគណនីចរន្តរបស់ប្រទេស មានភាពប្រសើរឡើង។ តាមការព្យាករណ៍ឆ្នាំនេះប្រទេសកម្ពុជានឹងចំណេញបានប្រមាណ ០,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប[4]ពីការធ្លាក់ចុះថ្លៃប្រេង។ តាមការរំពឹងទុកប្រទេសកម្ពុជាក៏នឹងក្លាយទៅជា ប្រទេសមានចំណូលមធ្យមកម្រិតទាប (សូមមើលប្រអប់លេខ ១)។ ទោះបីជាយ៉ាងណាក៏ដោយតាមការព្យាករណ៍កំណើនផលិតផលក្នុងស្រុកសរុប នឹងថយចុះតិចតួចមកត្រឹម ៦,៩ ភាគរយក្នុងឆ្នាំ ២០១៥ ដោយសារតែការកើនឡើងតិចជាងមុន នៃម៉ាស៊ីនសេដ្ឋកិច្ច

[3] ផ្អែកលើការវិភាគការនាំចេញសម្លៀកបំពាក់ និងផលិតកម្មសម្លៀកបំពាក់ក្នុងឆមាសទីមួយឆ្នាំ ២០១៤ ប្រទេសមីយ៉ាន់ម៉ាបច្ចុប្បន្នមានលទ្ធភាពនាំផលិតផលសម្លៀកបំពាក់ចេញចំនួន ១,៧ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ ២០១៤។ ចំនួននេះស្ទើរតែស្មើនឹងចំនួនទ្វេដងនៃចំណូលពីការនាំចូលក្នុងរយៈពេលពីរឆ្នាំ។ ការនាំចេញសម្លៀកបំពាក់មានចំណូលចំនួន ១,២ ពាន់លានដុល្លាអាមេរិកក្នុងឆ្នាំ ២០១៣ ដោយនៅក្នុងឆ្នាំ ២០១២ ចំណូលនេះមានតែជាង ៩០០ លានដុល្លាអាមេរិកប៉ុណ្ណោះ។

[4] បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៥។

សំខាន់ៗមួយចំនួន។ ទោះបីជាសកម្មភាពរស់រវើកក្នុងវិស័យសំណង់ត្រូវបានគេ រំពឹងថានឹងបន្តមាន ហើយវិស័យទេសចរណ៍ ទំនងជាងើបឡើងវិញខ្លះៗ ក៏កត្តាទាំងនេះនៅតែ មិនគ្រប់គ្រាន់ក្នុងការធ្វើឲ្យមានតុល្យភាពជាមួយ នឹងការបន្ថយល្បឿននៃវិស័យកាត់ដេរ និង កសិកម្មនោះទេដែលធ្វើឲ្យមានកំណើនយឺតបន្តិច។ ការកើនឡើងនៃតម្លៃផលិតកម្ម កំណើនតម្លៃប្រាក់ដុល្លាអាមេរិក និង អ្នកប្រកួតប្រជែងថ្មីៗ នឹងបន្តប៉ះពាល់ដល់កំណើននៃការនាំចេញសម្លៀកបំពាក់។ វិស័យកសិកម្មទំនងជានឹងបន្តមានកំណើនតិចតួច ដោយសារតែការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្ម នៅលើទីផ្សារអន្តរជាតិ និងកំណើនទិន្នផលដំណាំយឺត។

**៣ មានហានិភ័យ ចំពោះការព្យាករណ៍អំពីកំណើន។** ហានិភ័យក្នុងប្រទេសរួមមាន ភាពរំជើបរំជួលទីផ្សារពលកម្ម ដែលនឹងអាចកើតមានសាជាថ្មី។ ហានិភ័យក្រៅប្រទេស មានភាពយឺតយ៉ាវក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ចនៅអឺរ៉ុប និងការចូលជាថ្មីម្តងទៀតរបស់ប្រទេសថៃ និងប្រទេសមីយ៉ាន់ម៉ាក្នុងទីផ្សារនាំចេញស្រូវអន្តរជាតិ ជាមួយនឹងការរំពឹងទុកថានឹង មានការធ្លាក់ចុះតម្រូវការនាំចូលអង្ករនៅប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី ក៏ដូចជាភាពមិនប្រាកដប្រជាផ្នែកនយោបាយក្នុងតំបន់ដែរ។

**រូបលេខ ១** ទោះបីជាកំណើននៅតែមានភាពរឹងមាំ ក៏មានសញ្ញានៃការថយចុះ។ ការរួមចំណែកចំពោះកំណើនពិត (ជាភាគរយ)




e=ការប៉ាន់ស្មាន p=ការព្យាករណ៍

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភព

**ប្រអប់លេខ ១**

## កម្ពុជាកំពុងតែនៅលើគន្លងដែលអាចក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥

ធនាគារពិភពលោកបានធ្វើចំណាត់ថ្នាក់សេដ្ឋកិច្ចដោយផ្អែកលើចំណូលជាតិសរុប (GNI) សម្រាប់មនុស្សម្នាក់។ ចំណូលជាតិសរុបជាតម្លៃសរុបនៃទំនិញ និងសេវាកម្មដែល ផលិតក្នុងប្រទេសមួយ (ឧទាហរណ៍ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេស) បូកជាមួយនឹងចំណូលដែលទទួលបានពីប្រទេសផ្សេងទៀត (បានពីប្រាក់ចំណេញ និងប្រាក់ឈ្នួលពីបរទេស) ដកនឹងការចំណាយស្រដៀងគ្នាទៅឲ្យប្រទេសផ្សេងទៀតដែលរកស៊ីនៅក្នុងស្រុកប្រទេសនោះឯង។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនកម្ពុជាមួយដែលប្រតិបត្តិការនៅបរទេសបញ្ជូនផលចំណេញរបស់ខ្លួនមកប្រទេសកម្ពុជា នោះវានឹងធ្វើឲ្យមានកំណើនចំណូលជាតិសរុបរបស់កម្ពុជាកើនឡើង។ ចំណូលជាតិសរុបត្រូវបានចាត់ទុកថាជាសូចនាករដ៏ល្អបំផុតដែលបង្ហាញពីសមត្ថភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ទោះបីជាមានការទទួលស្គាល់ថា ចំណូលជាតិសរុបនេះមិនវាស់វែងពីសុខុមាលភាព ឬភាពជោគជ័យក្នុងការអភិវឌ្ឍក៏ដោយ។ ដូចនេះ ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ជាលក្ខណវិនិច្ឆ័យពិសេសរបស់ធនាគារពិភពលោកក្នុងការធ្វើចំណាត់ថ្នាក់ប្រទេសទៅជាក្រុមប្រាក់ចំណូល។

ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥ ធនាគារពិភពលោកបានបង្កើតកម្រិតកំណត់ក្រុមរកប្រាក់ចំណូល (តារាង B1.1)។ ប្រទេសដែលមានប្រាក់ចំណូលទាបគឺជាប្រទេសដែលមានចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ចំនួន ១.០៤៥ ដុល្លាអាមេរិក ឬតិចជាងនេះក្នុងឆ្នាំ២០១៣ (គណនាដោយប្រើប្រាស់វិធីសាស្ត្រ Atlas)។ ប្រទេសដែលមានប្រាក់ចំណូល មធ្យមកម្រិតទាបគឺជាប្រទេសដែលមានចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ច្រើនជាង ១.០៤៥ ដុល្លាអាមេរិក ប៉ុន្តែតិចជាង ៤.១២៥ ដុល្លាអាមេរិក។ ប្រទេសដែលមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់គឺជាប្រទេសដែលមានចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ច្រើនជាង ៤.១២៥ ដុល្លាអាមេរិក ប៉ុន្តែតិចជាង ១២.៧៤៦ ដុល្លាអាមេរិក ចំណែកប្រទេសដែលមានប្រាក់ចំណូលខ្ពស់គឺជាប្រទេសដែលមានចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ចំនួន ១២.៧៤៦ ដុល្លាអាមេរិក ឬច្រើនជាងនេះ។ អត្រាប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ត្រូវបានធ្វើបច្ចុប្បន្នភាពនៅខែកក្កដារៀងរាល់ឆ្នាំដើម្បីបញ្ចូលផលប៉ះពាល់នៃអតិផរណាអន្តរជាតិ។

តារាង B1.1 ៖ អត្រាចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់សម្រាប់ចំណាត់ថ្នាក់ក្រុមប្រាក់ចំណូលនៅខែកក្កដា ឆ្នាំ២០១៤ (ប្រាក់ដុល្លាអាមេរិកថេរនៅឆ្នាំ២០១៣) ៖

| | | |
|---|---|---|
| | ចំណូលទាប | < $1,045 |
| $1,045 < | ចំណូលមធ្យមកម្រិតទាប | < $4,125 |
| $4,125 < | ចំណូលមធ្យមកម្រិតខ្ពស់ | < $12,746 |
| $12,746 < | ចំណូលខ្ពស់ | |

ប្រភព ៖ http://data.worldbank.org/news/2015-country-classifications?print

កំណត់សម្គាល់ ៖ កម្រិតកំណត់ត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ខែកក្កដា។ សម្រាប់កម្រិតកំណត់ថ្មីបំផុត សូមចូលទៅកាន់គេហទំព័រ ៖ http://data.worldbank.org/about/country-and-lending-groups

ដោយសារតែកម្រិតកំណត់នៅថេរដដែលក្នុងរយៈពេលមួយ កំណើនត្រូវអនុវត្តពិនិត្យក្នុងតម្លៃប្រាក់ដុល្លាអាមេរិកថេរឆ្នាំ២០១៣។ ដើម្បីវាយតម្លៃក្រុមប្រាក់ចំណូលដែលនឹងប្រទេសកម្ពុជាស្ថិតនៅក្នុងនោះ កំណើនសេដ្ឋកិច្ចរបស់ប្រទេសនេះត្រូវបានព្យាករជាប្រាក់ដុល្លាអាមេរិកថេរក្នុងឆ្នាំ២០១៣ និងចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ត្រូវបានប្រៀបធៀបជាមួយកម្រិតកំណត់ដែលមាននៅក្នុងតារាង B 3.1។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាទំនងនឹងឈានដល់ កម្រិតប្រាក់ចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៥ ហើយកម្រិតនេះនឹងត្រូវបានកត់ត្រាជាផ្លូវការក្នុងខែកក្កដា ឆ្នាំ២០១៦។ តាមរយៈកំណើនផលិតផលក្នុងស្រុកសរុបដែលបានព្យាករថាមានប្រមាណ ៦,៩ ភាគរយក្នុងឆ្នាំ២០១៥ និងកំណើនប្រជាជនប្រចាំឆ្នាំចំនួន ១,២ ភាគរយ ប្រទេសកម្ពុជាទំនងនឹងសម្រេចបានចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ចំនួន ១.០៩៦ ដុល្លាអាមេរិក (វាស់វែងជាប្រាក់ដុល្លាអាមេរិកថេរក្នុងឆ្នាំ២០១៣) ក្នុងឆ្នាំ២០១៥ ដែលលើសពីកម្រិតកំណត់ដែលមាន ១.០៤៥ ដុល្លាអាមេរិក (តារាង B1.1 និង B1.2)។ ដោយសារធនាគារពិភពលោកធ្វើបច្ចុប្បន្នភាពសមាជិកក្រុមប្រាក់ចំណូលក្នុងខែកក្កដា ឋានៈប្រាក់ចំណូលមធ្យមកម្រិតទាបរបស់ប្រទេសកម្ពុជាទំនងនឹងត្រូវកត់ត្រាជាផ្លូវការក្នុងខែកក្កដា ឆ្នាំ២០១៦។

តារាង B1.2 ៖ ការកំណត់កាលបរិច្ឆេទ និងអត្រាកំណើនដែលប្រទេសកម្ពុជានឹងកែប្រែស្ថានភាពអភិវឌ្ឍន៍របស់ខ្លួន

| កំណើនផលិតផលក្នុងស្រុកសរុប ប្រាក់ដុល្លាអាមេរិកថេរ | ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ ប្រាក់ដុល្លាអាមេរិកថេរឆ្នាំ២០១៣ | | | |
|---|---|---|---|---|
| | 2014 | 2015 | 2030 | 2050 |
| 4.9% | 1,035 | 1,075 | 1,908 | 4,101 |
| 6.9% | 1,035 | 1,096 | 2,589 | 8,148 |
| 9% | 1,035 | 1,117 | 3,544 | 16,521 |

ប្រភព ៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោកដោយផ្អែកតាម WDI, Atlas និងទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កំណត់សម្គាល់ ៖ ការប៉ាន់ស្មានដោយផ្អែកលើចំណូលជាតិសរុបចំនួន ៩៥០ ដុល្លាអាមេរិកក្នុងឆ្នាំ២០១៣។ កំណើនផលិតផលក្នុងស្រុកសរុបដែលបានព្យាករត្រូវប្រើជារង្វាស់សម្រាប់កំណើនចំណូលជាតិសរុប។ កំណើនប្រជាជនប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថាមានចំនួន ១ ភាគរយរៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៥ តទៅ។

តាមសេណារីយ៉ូកំណើនមូលដ្ឋានដែលមាន ៦,៩ ភាគរយនៃកំណើនផលិតផលក្នុងស្រុកសរុបពិតប្រចាំឆ្នាំ ប្រទេសកម្ពុជានឹងមានកម្រិតប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣៩។ ការសម្រេចបានកម្រិតប្រាក់ចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ នឹងទាមទារឲ្យមានអត្រាកំណើនផលិតក្នុងស្រុកសរុបពិតចំនួន ៩ ភាគរយ (តារាង B1.2) ដែលស្មើនឹង ៨ ភាគរយ នៃអត្រាកំណើនប្រាក់ចំណូលសម្រាប់មនុស្សម្នាក់។ តាមការវិភាគពីបទពិសោធន៍កំណើនរបស់ប្រទេសពីមុនមកតាំងពីឆ្នាំ១៩៥០ ការរក្សាបាននូវអត្រាកំណើននេះនឹងទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងខ្លាំងខុសពីធម្មតា។ ប្រទេសដែលរីកចម្រើនលឿនបំផុតកាលពី ២ ទសវត្សរ៍កន្លងមក សម្រេចបានអត្រាកំណើនចំណូលប្រចាំឆ្នាំជាមធ្យមសម្រាប់មនុស្សម្នាក់ចំនួន ៨,៩ ភាគរយ (ចិន) និង ៦,១ ភាគរយ (អាមេនី)។ យ៉ាងណាក៏ដោយ ការសម្រេចបានកម្រិតប្រាក់ចំណូលមធ្យមកម្រិតខ្ពស់មុនឆ្នាំ២០៥០ គឺអាចប្រសិនបើកំណើនផលិតផលក្នុងស្រុកសរុបលើសពីសេណារីយ៉ូករណីទាបចំនួន ៤,៩ ភាគរយ។ តាមទិន្នន័យមូលដ្ឋាននៃកំណើនផលិតផលក្នុងស្រុកចំនួន ៦,៩ ភាគរយ ប្រទេសកម្ពុជានឹងសម្រេចបានអត្រានេះត្រឹមឆ្នាំ២០៣៩។

សូមមើល៖ http://data.worldbank.org/indicator/NY.GNP.PCAP.CD and http://www.investordictionary.com/definition/gross-national-income

## ក)　វិស័យកាត់ដេរ

**៤　ចំនួននៃការនាំចេញសម្លៀកបំពាក់បន្តកើនឡើង ប៉ុន្តែក្នុងល្បឿនយឺតជាងមុនខណៈដែលមានការធ្វើពិពិធកម្មគោលដៅនាំចេញ** (រូបលេខ ២)។ វិស័យនេះ បន្តទាក់ទាញការវិនិយោគបន្ថែមទៀត ទោះបីជាភាពរំជើបរំជួលទីផ្សារពលកម្ម ដែលបានកើតមាននាពេលកន្លងមកត្រូវបានគេ មើលឃើញថាបានបង្កើនភាពមិនប្រាកដប្រជាក្នុងការសម្រេចការងារតាមការបញ្ជាទិញក៏ដោយ ដែលបញ្ហានេះធ្វើឲ្យម៉ាកសំខាន់ៗមួយចំនួន បង្វែរការបញ្ជាទិញរបស់ពួកគេ ទៅកាន់អ្នកប្រកួតប្រជែងដែលផ្តល់ប្រាក់ឈ្នួលទាបផ្សេងៗទៀត។ លើសពីនេះទៀតមានការទទួលបានជោគជ័យមួយចំនួន ក្នុងការធ្វើពិពិធកម្មគោលដៅនាំចេញ។ ក្នុងឆ្នាំ ២០១៤ ក្នុងចំណោមការនាំចេញសម្លៀកបំពាក់សរុបចំនួន ៥,៥ ពាន់លានដុល្លាអាមេរិក ការនាំចេញផលិតផលសម្លៀកបំពាក់ចំនួន ១,៤ ពាន់លានដុល្លាអាមេរិក ឬ ២៦ ភាគរយ ត្រូវបានបញ្ជូនទៅទីផ្សារខាងក្រៅសហរដ្ឋអាមេរិក និង អឺរ៉ុប ហើយបើធៀបនឹងឆ្នាំ ២០០៥ ចំនួននេះ មានតែ ៨,២ ភាគរយប៉ុណ្ណោះ។ ទីផ្សារធំបំផុតក្រៅពីអឺរ៉ុប និងសហរដ្ឋអាមេរិក គឺប្រទេសជប៉ុន ដោយការនាំចេញទៅប្រទេសនេះមានចំនួន ៦ ភាគរយនៃចំនួននាំចេញសរុប។ ភាគរយនៃការនាំចេញផលិតផលសម្លៀកបំពាក់ទៅកាន់ប្រទេសជា សមាជិកអាស៊ាននៅតែមានកម្រិតទាបដដែល គឺត្រឹមតែ ១,៣ ភាគរយប៉ុណ្ណោះ។ យុទ្ធសាស្ត្រនៃ ការនាំចេញផលិតផលសម្លៀកបំពាក់ដែលមាន គុណភាពខ្ពស់ទៅកាន់អឺរ៉ុបដើម្បីទទួលបាននូវ អត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះ "អ្វីៗគ្រប់យ៉ាងលើកលែងអាវុធ" របស់អឺរ៉ុប នៅតែបន្ត ទោះជាមានការប្រកួតប្រជែងផ្នែកតម្លៃខ្លាំងជាងមុន ដោយសារតែការធ្លាក់ចុះនៃតម្លៃប្រាក់អឺរ៉ូធៀបនឹង ប្រាក់ដុល្លារអាមេរិកក៏ដោយ។ ចំនួនទឹកប្រាក់នៃការនាំចេញរបស់កម្ពុជា ក៏ដូចជាការចំណាយទៅលើវត្ថុធាតុដើម ត្រូវបានគិតជាដុល្លាអាមេរិកដោយសារតែដុល្លារូបនីយកម្ម។ គិតជាចំនួនទឹកប្រាក់ ចំណែកនៃការនាំចេញសម្លៀកបំពាក់ទៅកាន់អឺរ៉ុបបានកើនឡើងដល់ ៤០ ភាគរយនៃចំនួនទឹកប្រាក់នៃការនាំចេញសម្លៀកបំពាក់សរុប ពេលដែលចំណែកនៃការនាំចេញទៅកាន់សហរដ្ឋអាមេរិក បានធ្លាក់ចុះថែមទៀតមកត្រឹម ៣៤ ភាគរយចាប់តាំងពីឆ្នាំ ២០១៤ នោះ។ បើគិតជាបរិមាណ ភាគរយនៃការនាំចេញសម្លៀកបំពាក់ទៅកាន់អាមេរិកបានថយចុះ ប៉ុន្តែនៅតែខ្ពស់ជាងគេបំផុតដោយមានចំនួន ៤៤ ភាគរយ នៃការនាំចេញសម្លៀកបំពាក់សរុប ចំណែកភាគរយនាំចេញសម្លៀកបំពាក់ទៅកាន់អឺរ៉ុបបានកើនឡើងដល់ ៣៦ ភាគរយ។

រូបលេខ ២ តម្លៃនៃការនាំចេញសម្លៀកបំពាក់បន្តកើនឡើង ប៉ុន្តែកំណើននោះយឺតជាងមុនៗមានការធ្វើពិពិធកម្មគោលដៅនាំចេញសម្លៀកបំពាក់ (គិតជាលានដុល្លារអាមេរិក)




ប្រភព៖ អាជ្ញាធរកម្ពុជា

## ខ)　វិស័យសំណង់ និងអចលនទ្រព្យ

**៥　វិស័យសំណង់ នៅតែមានភាពរឹងមាំ ដោយសារតែការទទួលបានមកវិញនូវ ទំនុកចិត្ត ដោយ ស្ថិរភាពនយោបាយក្នុងប្រទេសមានភាព**

**ប្រសើរឡើងវិញ។** សកម្មភាពវិស័យសំណង់នៅតែមានភាពសកម្ម ដោយតម្លៃអចលនទ្រព្យនៅតែបន្តកើនឡើងរហូតដល់ ២០ ភាគរយក្នុងមួយឆ្នាំ។ គម្រោងសាងសង់ ដែលទទួលបានការអនុញ្ញាតក្នុងឆ្នាំ ២០១៤ មានចំនួនទឹកប្រាក់រហូតដល់ ៣,២ ពាន់លានដុល្លាអាមេរិក (រូបលេខ ៣) ឬ ១៧,៥ ភាគរយ ខ្ពស់ជាងចំនួនទឹកប្រាក់គម្រោងសាងសង់ដែលទទួលបានការអនុញ្ញាតកាលពីឆ្នាំ២០១៣[5]។ ពាក់កណ្តាលនៃគម្រោងដែលត្រូវបានអនុម័តគឺជាគម្រោងសាងសង់នៅតាមខេត្ត។ ចំនួនទឹកប្រាក់នៃគម្រោងអចលនទ្រព្យ និងទេសចរណ៍ (ទ្រព្យអកម្ម) ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តនៅបន្តកើនឡើងរហូតដល់ ១,៥ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ១១ ភាគរយក្នុងឆ្នាំ ២០១៤។ ទោះជាយ៉ាងនេះក្តី ការរស់នៅ និងកាន់កាប់ មិនបានទាន់ ជាមួយនឹងកំណើនយ៉ាងលឿននៃវិស័យសំណង់ឡើយ។ កំណើននៃវិស័យសំណង់ និងសេវាកម្ម នៅពេលដែលកំណើនវិស័យផលិតកម្មបានថយចុះបន្តិច (វិស័យទេសចរណ៍ វិស័យកាត់ដេរ និង វិស័យកសិកម្ម) ធ្វើឲ្យមានហានិភ័យដែលអាចនឹងកើតមាន។ ហានិភ័យសំខាន់ៗបណ្តាលមកពីការបន្តកំណើននៃវិស័យសំណង់រួមមាន (១) វដ្តដែលមានក្នុងវិស័យសំណង់ និងអចលនទ្រព្យ (២) ភាគរយខ្ពស់នៃការវិនិយោគផ្ទាល់ពីបរទេសធ្វើឲ្យវិស័យសំណង់ងាយរងគ្រោះ ប្រសិនបើការវិនិយោគផ្ទាល់ពីបរទេសថយចុះវិញ (៣) ពពុះបង្កដោយការឡើងថ្លៃ ដែលមានភាពប្រថុយប្រថាន និង (៤) បញ្ហាប្រឈមនៃគោលនយោបាយដីធ្លី (ការគ្រប់គ្រងដីធ្លីប្រកបដោយតម្លាភាព ការគ្រប់គ្រងការតាំងទីលំនៅ។ល។) ដែលប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងការរីកចម្រើនជារួម។ បទពិសោធន៍អន្តរជាតិបង្ហាញឲ្យឃើញថា កំណើនវិស័យសំណង់មានលក្ខណៈផុយស្រួយ និងមិនសូវមានសមធម៌ឡើយ។ ហេតុនេះ ត្រូវមានការទប់ទល់ទៅនឹងកំណើនវិស័យសំណង់ដែលមិនមាននិរន្តរភាព។

រូបលេខ ៣ ការបន្តកំណើនក្នុងវិស័យសំណង់ក្នុង ឆ្នាំ ២០១៤
គម្រោងសាងសង់ដែលទទួលបានការអនុញ្ញាត
(YTD គិតជាលានដុល្លាអាមេរិក)




ប្រភព៖ អាជ្ញាធរកម្ពុជា

## គ) វិស័យទេសចរណ៍

**៦ វិស័យទេសចរណ៍មានកំណើនយឺត។** ចំនួនសរុបនៃភ្ញៀវទេសចរ ដែលចូលទស្សនាប្រទេសកម្ពុជាមានកំណើនយឺត ដោយមានភ្ញៀវទេសចរសរុបចំនួន ៤,៥ លានអ្នក ឬមានអត្រាកំណើនតែ ៦,៩ ភាគរយក្នុងឆ្នាំ ២០១៤ ប្រៀបធៀបនឹងចំនួន ៤,២ លាននាក់ ឬកំណើន ១៧,៥ ភាគរយក្នុងឆ្នាំ ២០១៣។ មូលហេតុចម្បងនៃកំណើនយឺតនេះ បណ្តាលមកពីកំណើនភ្ញៀវទេសចរពីទីផ្សារធំបំផុតពីរ គឺប្រទេសវៀតណាម និងប្រទេសចិន។ ចំនួនភ្ញៀវទេសចរ ដែលធ្វើដំណើរតាមផ្លូវគោកមានកំណើនយឺត (៤០ ភាគរយនៃភ្ញៀវទេសចរមកតាមផ្លូវគោកពីប្រទេសវៀតណាម) ដែលមានចំនួន

[5] ត្រូវពិនិត្យលើការប្រែប្រួលលើការអនុម័តការវិនិយោគដោយប្រុងប្រយ័ត្ន ដោយសារតែការអនុម័តទាំងនេះអាចប្រែប្រួលដោយសារតែការអនុម័តនាពេលថ្មីលើគម្រោងដ៏ធំមួយ។

ប្រហែលជាពាក់កណ្តាល នៃភ្ញៀវទេសចរសរុប ដែលធ្វើឲ្យចំនួនភ្ញៀវទេសចរ សរុបមានការថយចុះបន្តិច ខណៈដែលភ្ញៀវទេសចរតាមផ្លូវអាកាសនៅមានអត្រាកំណើនពីរខ្ទង់ដដែល (តារាងលេខ ១)។ ប្រទេសវៀតណាមក៏មានការថយចុះចំនួនភ្ញៀវទេសចរចូលមកទស្សនាខ្លាំងផងដែរ ចំណែកប្រទេសថៃមានអត្រាកំណើនភ្ញៀវទេសចរអវិជ្ជមាន ដែលផ្ទុយទៅនឹងនិន្នាការទេសចរណ៍សកលលោក ដែលរំពឹងថា នឹងមានចំនួនភ្ញៀវទេសចរច្រើនមិនធ្លាប់មានពីមុននោះ[6]។

**៧ វិស័យទេសចរណ៍ក្នុងឆ្នាំ ២០១៤ មានការកើនឡើងដោយសារតែ ចំនួនភ្ញៀវទេសចរមកពីប្រទេសអាស៊ាន និងប្រទេសចិន។** ក្នុងឆ្នាំ២០១៤ បើទោះជាចំនួនភ្ញៀវទេសចរ ពីប្រទេសវៀតណាម និងប្រទេសចិន នៅតែមានចំនួនច្រើនជាងគេទីមួយ និងទីពីរ ដោយមានចំនួនប្រមាណ ២០,១ ភាគរយ និង ១២,៤ ភាគរយនៃភ្ញៀវទេសចរសរុប ក៏ចំនួនភ្ញៀវទេសចរពីប្រទេសកូរ៉េ (កូរ៉េខាងត្បូង) មានការថយចុះ ដោយចំនួនភ្ញៀវទេសចរមកពីប្រទេសឡាវ មានច្រើនជាងចំនួនភ្ញៀវទេសចរមកពីប្រទេសកូរ៉េខាងត្បូងដែលមានចំនួន ១០,២ ភាគរយនៃភ្ញៀវទេសចរសរុប[7]។ ចំនួនភ្ញៀវពីប្រទេសជប៉ុនបន្តកើនឡើង ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ទោះបីជាទំនុកចិត្តរបស់អ្នកវិនិយោគទុន ជប៉ុនចំពោះប្រទេសកម្ពុជានៅតែវិជ្ជមានក្តី[8]។

**តារាងលេខ១** នៅក្នុងឆ្នាំ ២០១៤ ចំនួនភ្ញៀវទេសចរមកប្រទេសកម្ពុជា និងប្រទេសវៀតណាម បានថយចុះ ខណៈពេលដែលកំណើនភ្ញៀវទេសចរនៅប្រទេសថៃមានកម្រិតអវិជ្ជមាន

ចំនួនភ្ញៀវទេសចរមកទស្សនា

| | កម្ពុជា | | ថៃ | | វៀតណាម | |
|---|---|---|---|---|---|---|
| | 2014 | 2013 | 2014 | 2013 | 2014 | 2013 |
| ចំនួនភ្ញៀវសរុប (ជាលាន) | 4.50 | 4.21 | 25.02 | 26.55 | 7.83 | 7.54 |
| ការប្រែប្រួល (ឆ្នាំ ភាគរយ) | 6.9% | 17.5% | -6.1% | 18.8% | 3.8% | 12.5% |
| ចំនួនភ្ញៀវមកតាមផ្លូវអាកាស | 2.27 | 2.02 | 15.52 | 15.37 | 6.22 | 5.98 |
| ការប្រែប្រួល (ឆ្នាំ ភាគរយ) | 12.7% | 17.2% | 1.0% | 8.7% | 3.9% | 6.8% |

ប្រភព៖ ក្រសួងទេសចរណ៍ អាជ្ញាធរទេសចរណ៍ប្រទេសថៃ ក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ប្រទេសវៀតណាម

## ឃ) វិស័យកសិកម្ម

**៨ វិស័យកសិកម្មរបស់កម្ពុជា ដែលជួយដល់ប្រជាជនក្រីក្រ មានការរីកចម្រើនយ៉ាងពិសេស ជំរុញដោយផលិតផលស្រូវ ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ប៉ុន្តែវិស័យកសិកម្មបានបន្ថយល្បឿនក្នុងពេលបច្ចុប្បន្នដោយសារតែតម្លៃផលិតផលកសិកម្ម ធ្លាក់ចុះហើយទិន្នផលកើនឡើងយឺត។** កំណើនវិស័យកសិកម្មនៅតែមានកម្រិតទាប ដោយសារតែការពង្រីកផ្ទៃដីដាំដុះ និងទិន្នផល ជាពិសេសចំពោះដំណាំស្រូវមានការយឺតយ៉ាវ។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីច្រូតកាត់ស្រូវវស្សាមានការកើនឡើង បើធៀបនឹងឆ្នាំ ២០១៣ ទោះបីជាផ្ទៃដីច្រូតកាត់ មានការថយចុះបន្តិចក្តី។ យ៉ាងណាក៏ដោយ ផលិតកម្មស្រូវវស្សាថយចុះ ២,៥ ភាគរយ ហើយទិន្នផលស្រូវថយចុះ ៣ ភាគរយដែរ (រូបលេខ ៤ក)។ តម្លៃស្រូវក៏បានធ្លាក់ចុះក្នុងឆ្នាំ ២០១៤ (រូបលេខ ៤ខ)។ ដោយសារផ្ទៃដីមានកម្រិត កំណើនផលិតកម្មស្រូវដែលត្រូវបានជំរុញតាមរយៈការពង្រីកផ្ទៃដីដាំ

6 ទេសចរណ៍អន្តរជាតិនឹងមានចំនួនច្រើនបំផុតមិនធ្លាប់មាននៅចុងឆ្នាំ ២០១៤ ដោយមានភ្ញៀវទេសចរអន្តរជាតិជាង ១,១ ពាន់លាននាក់ដែលធ្វើដំណើរជុំវិញពិភពលោកក្នុងឆ្នាំតែមួយ។ សារព័ត៌មាន UNWTO ខែធ្នូ ឆ្នាំ២០១៤។

7 ភ្ញៀវទេសចរអន្តរជាតិដែលចូលមកក្នុងប្រទេសកម្ពុជាប្រហែល ៩៥ ភាគរយ បានរាយការណ៍ថា ចូលមកក្នុងគោលបំណងធ្វើទេសចរណ៍។

8 ការអង្កេតរបស់ JETRO ឆ្នាំ២០១៤ ស្តីពីលក្ខខណ្ឌធុរកិច្ចរបស់ក្រុមហ៊ុនសម្ព័ន្ធជប៉ុនក្នុង Asia និង Oceania Janpanse។ គេហទំព័រ ៖ (http://www.jetro.go.jp/en/reports/survey/pdf/2015_01_biz.pdf)។

ដុះនោះ ពីពេលនេះទៅនឹងត្រូវពឹងផ្អែកលើការបង្កើនទិន្នផលស្រូវ។ តាមការរំពឹងទុកតម្លៃផលិតផលកសិកម្ម នឹងមិនកើនឡើងទេនាពេលខាងមុខ ដោយសារការប្រែប្រួលតម្លៃនៅលើទីផ្សារអន្តរជាតិចំពោះទំនិញភាគច្រើនបានត្រឡប់ទៅជាតម្លៃធម្មតាពីមុន។ តម្លៃអាហារលើពិភពលោកបានធ្លាក់ចុះជាបណ្តើរៗ ហើយទីផ្សារអង្ករពិភពលោកកាន់តែមានភាពប្រកួតប្រជែង ដោយការចូលរួមជាថ្មីម្តងទៀតរបស់ប្រទេសថៃ និងប្រទេសមីយ៉ាន់ម៉ា។

រូបលេខ ៤ក ស្រូវស្សា (ផលិតកម្ម និងទិន្នផល) ដែលមានចំនួនស្ទើរតែ ៨០ ភាគរយ នៃផលិតកម្ម ស្រូវសរុប បានថយចុះក្នុងឆ្នាំ២០១៤។




ប្រភព៖ នាយកដ្ឋានកម្ពុជា

រូបលេខ ៤ខ តម្លៃស្រូវលក់ដុំក្នុងទីផ្សារមួយចំនួនបានថយចុះក្នុងឆ្នាំ ២០១៤




ប្រភព៖ អង្គការ FAO ផ្អែកលើទិន្នន័យពីប្រព័ន្ធព័ត៌មានទីផ្សារកសិកម្មកម្ពុជា។
http://www.fao.org/giews/countrybrief/country.jsp?code=KHM

## ២ វិស័យទូទាត់ក្រៅប្រទេស

**៩ ស្ថានភាពក្នុងវិស័យទូទាត់ក្រៅប្រទេសនៅតែមានស្ថិរភាព ដោយសារតែលំហូរវិនិយោគទុនផ្ទាល់ពីបរទេសមានភាពល្អ ដែលកំពុងគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។** ឱនភាពគណនីចរន្ត (មិនគិតការបង្វែរផ្លូវការ) ត្រូវបានប៉ាន់ប្រមាណថានឹងកើនឡើងបន្តិចបន្តួចដល់កម្រិត ១១,២ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ ហើយកំណើនឱនភាពនេះមានចំនួន ១០,៧ ភាគរយកាលពីឆ្នាំ២០១៣ហើយបន្តទទួលបានហិរញ្ញប្បទានភាគច្រើនពីការវិនិយោគផ្ទាល់ពីបរទេស (រូបលេខ ៥)។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសបន្តមានប៉ុន្តែត្រូវបានគេប៉ាន់ប្រមាណថា មានកម្រិតទាបជាងឆ្នាំ ២០១៣ ដោយភាគច្រើនមកពីវិស័យទេសចរណ៍ និងវិស័យសំណង់ ចំណែកឯវិស័យសម្លៀកបំពាក់វិញទទួលការកើនឡើងតិចជាងមុន។ ទុនបម្រុងអន្តរជាតិដុលមាន ការកើនឡើងខ្ពស់ដោយមានចំនួន ៤,៦ ពាន់លានដុល្លាអាមេរិក ឬប្រហែល ៤ ខែនៃការនាំចូលដែលរំពឹងទុក[9] គិតត្រឹមដំណាច់ឆ្នាំ២០១៤ ដែលចំនួននេះមិនធ្លាប់មាននាពេលកន្លងមកទេ។

[9] ការនាំចូលទំនិញ និងសេវាកម្មដែលរំពឹងទុក។

**រូបលេខ ៥** ដោយសារតែកំណើននៃការនាំចេញមានការថយចុះ ជាងតម្រូវការនៃការនាំចូលដែលមានការថយចុះ ឱនភាពពាណិជ្ជកម្មនៅតែបន្តថយចុះ។ (គិតជាលានដុល្លាអាមេរិក)




e=ការប៉ាន់ស្មាន p=ការព្យាករណ៍

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

## ក) ការនាំចេញ

**១០** កំណើននៃការនាំចេញបន្តមាន ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ដោយសារតែកំណើនតិចជាងមុននៃ វិស័យកាត់ដេរ និងឧស្សាហកម្មស្បែកជើង (រូបលេខ ៦)។ តម្លៃនៃផលិតផលនាំចេញផ្សេងទៀត សំខាន់ផលិតផលកសិកម្ម បានជួបប្រទះបញ្ហាដោយសារតែការធ្លាក់ចុះតម្លៃទំនិញ ទោះបី ជាបរិមាណនៃការនាំចេញបានកើនឡើងក្តី។ ទោះបីជាលក្ខខណ្ឌខាងក្រៅនៅតែអំណោយផលក៏ដោយ ក៏សម្ពាធក្នុងប្រទេស ដូចជា ទីផ្សារការងារកាន់តែតឹងតែង និងកំណើនប្រាក់ឈ្នួលព្រមទាំងប្រាក់ដុល្លាអាមេរិកមានតម្លៃខ្ពស់ ជាមួយនឹងសេដ្ឋកិច្ចដុល្លារូបនីយកម្មកម្ពុជាអាចបាន និងកំពុងបន្តដាក់សម្ពាធលើកម្រិតប្រាក់ចំណេញ និងការលក់នៃវិស័យកាត់ដេរ (សូម មើលប្រធានបទពិសេសស្តីអំពី "បញ្ហាដុល្លារូប នីយកម្ម៖ គុណសម្បត្តិ គុណវិបត្តិ និងកិច្ចការបន្ទាប់" សម្រាប់ផលប៉ះពាល់នៃដុល្លារូបនីយកម្ម និងសូមមើលផងដែរប្រអប់លេខ២ ស្តីអំពីកំណែទម្រង់ពាណិជ្ជកម្មដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តដើម្បីកែ

**ប្រអប់លេខ ២**

### ឧស្សាហកម្មនៅកម្ពុជាកំពុងតែមានកំណែទម្រង់

**កំណែទម្រង់តាមព្រំដែន និងពន្ធគយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តួចផ្តើមកាលពីទសវត្សរ៍កន្លងមក បានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់។** បច្ចុប្បន្ននេះ នីតិវិធីពន្ធគយត្រូវបានធ្វើឡើងតាមកុំព្យូទ័រនៅប៉ុស្តិ៍ត្រួតពិនិត្យព្រំដែនចំនួន ២១។ រយៈពេលនៃការជម្រះពន្ធគយបានថយចុះពី ៥,៩ ថ្ងៃក្នុងឆ្នាំ ២០១០ មកត្រឹម ១,៤ ថ្ងៃ ក្នុងឆ្នាំ២០១៤។ ការពិនិត្យមើលទំនិញផ្ទាល់បានធ្លាក់ចុះពី ២៩ ភាគរយក្នុងឆ្នាំ២០១០ មកត្រឹម ១៧ ភាគរយក្នុងឆ្នាំ២០១៤។ ការកែលម្អទាំងនេះ បានរួមចំណែកធ្វើឲ្យប្រទេសកម្ពុជាផ្លោះលំដាប់លេខរៀងចំនួន ៤៦ ត្រឹមរយៈពេលតែ ៤ ឆ្នាំប៉ុណ្ណោះក្នុងសូចនាករការងារភស្តុភាររបស់ធនាគារពិភពលោក(LPI)ដែលធ្វើចំណាត់ថ្នាក់ប្រព័ន្ធភស្តុភារពាណិជ្ជកម្មរបស់ប្រទេស។

**ទោះបីជាមានវឌ្ឍនភាពក៏ដោយ ក៏នៅតែមានការងារជាច្រើនទៀតដែលត្រូវអនុវត្តដើម្បីកែលម្អចំណាយពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ចរបស់ប្រទេសកម្ពុជា។** ចំណាយពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាមានប្រហែល ៤០ ភាគរយខ្ពស់ជាងចំណាយជាមធ្យមក្នុងតំបន់។ បរិយាកាសធុរកិច្ចរបស់ប្រទេសមិនសូវអំណោយផលដល់ការអភិវឌ្ឍវិស័យឯកជន ដូចប្រទេសជាច្រើនផ្សេងទៀតឡើយ។ នៅក្នុងការធ្វើចំណាត់ថ្នាក់នៅក្នុងភាពងាយស្រួលនៃការធ្វើធុរកិច្ចរបស់ធនាគារពិភពលោកអំពីការធ្វើធុរកិច្ចឆ្នាំ ២០១៥ (Ease of Doing Business of the World Bank Doing Business) កម្ពុជាជាប់លំដាប់ថ្នាក់ទី ១៣៥ ក្នុងចំណោមប្រទេសទាំង ១៨៩ ហើយសម្រាប់ចំណាត់ថ្នាក់ក្នុងការចាប់ផ្តើមធុរកិច្ច (Starting a Business) កម្ពុជាស្ទើរតែស្ថិតនៅបាតតារាង ពោលគឺលេខរៀងទី ១៨៤។

**ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមកំណែទម្រង់ថ្មីៗចាប់តាំងពីដើមឆ្នាំ ២០១៤មក។** កំណែទម្រង់សំខាន់ៗទាំងបីក្នុងផ្នែកសម្របសម្រួលពាណិជ្ជកម្មមាន ៖

១. **ការចុះបញ្ជីក្រុមហ៊ុនកំពុងតែធ្វើឲ្យមានលក្ខណៈងាយស្រួល និងស្វ័យប្រវត្តិ ៖** គោលបំណងនៃការធ្វើបែបនេះគឺដើម្បីអនុញ្ញាតឲ្យអ្នកស្នើសុំចុះបញ្ជីក្រុមហ៊ុនថ្មីតាមបណ្តាញអ៊ីនធើណិតដោយប្រើរយៈពេលដ៏ខ្លីដោយកាត់បន្ថយការទាក់ទងដោយផ្ទាល់។

២. **ស្វ័យប្រវត្តិកម្មនៃលិខិតបញ្ជាក់ពីប្រទេសកំណើត (COO)៖** នៅដំណាក់កាលដំបូង ក្រសួងពាណិជ្ជកម្មអនុវត្តប្រព័ន្ធបណ្តោះអាសន្ន ដែលអាចត្រូវបានប្រើប្រាស់ពីក្រសួង។ ប្រព័ន្ធនេះកំពុងត្រូវបានធ្វើស្វ័យប្រវត្តិកម្មដើម្បីអាចឲ្យក្រុមហ៊ុនដាក់ពាក្យស្នើសុំវិញ្ញាបនប័ត្រ តាមប្រព័ន្ធអេឡិចត្រូនិក។ ប្រព័ន្ធ COO ថ្មីគឺសម្រាប់ប្រើប្រាស់ជាកន្លែងទូទាត់ចំណាយតាមប្រព័ន្ធអេឡិចត្រូនិក និងផ្តល់លទ្ធភាពទូទាត់ចំណាយតាមអ៊ីនធើណិតជាលើកដំបូង (ដោយមានចុះហត្ថលេខាតាមអ៊ីនធើណិត) សម្រាប់ការប្រើប្រាស់សេវារបស់រដ្ឋាភិបាល។

៣. **ការផ្លាស់ប្តូររបស់កាំកុងត្រូល ទៅជាទីភ្នាក់ងារការពារអតិថិជន និងសុវត្ថិភាពស្បៀងអាហារទំនើប៖** ចំណុចនេះសំដៅលើកកម្ពស់កម្រិតរួមនៃសុវត្ថិភាពស្បៀងអាហារក្នុងប្រទេសកម្ពុជា និងកាត់បន្ថយកិច្ចការជដែលៗជាមួយអគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជា (GDCE)។

**រាជរដ្ឋាភិបាលកម្ពុជា បានស្នើឲ្យវិស័យឯកជនជួយគាំទ្រកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយចំណាយក្រៅផ្លូវការ។ ដើម្បីជាការឆ្លើយតប ថ្មីៗនេះ ក្រុមហ៊ុនធំៗចំនួន ១៧ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដែលក្រុមហ៊ុនចំនួន ៩ មានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ)។**

លម្អស្ថានភាពពាណិជ្ជកម្ម)[10]។ ការនាំចេញផលិតផលកសិកម្ម ដូចជា អង្ករ និងកៅស៊ូ រងការប៉ះពាល់កាន់តែខ្លាំងឡើង ដោយសារតែការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្មក្នុងពិភពលោក។ ក្នុងឆ្នាំ ២០១៤ តម្លៃនាំចេញសរុបគិតជាដុល្លាអាមេរិក ត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងប្រហែលជា ១០ ភាគរយ ដែលជាចំនួនកំណើនមួយទាបជាងកាលពីឆ្នាំ ២០១៣ ដែលមានចំនួន ២២,៣ ភាគរយ។

## ខ) ការនាំចូល

**១១ កំណើនផលិតផលនាំចូលសំខាន់បំផុតភាគច្រើនមានការថយចុះនៅក្នុងឆ្នាំ ២០១៤ លើកលែងតែការនាំចូលសម្ភារសំណង់ ដែលត្រូវបានជំរុញតាមរយៈកំណើនយ៉ាងឆាប់រហ័ស នៃវិស័យសំណង់។** តម្រូវការក្នុងប្រទេសក្នុងអំឡុងឆមាសទីពីរក្នុងឆ្នាំ ២០១៤ មានការថយចុះជាងការស្មានទុកពីមុន ដោយសារតែសកម្មភាពសេដ្ឋកិច្ចពិតខ្សោយជាងមុន លើកលែងតែនៅក្នុងវិស័យសំណង់ដែលមានការកើនឡើងយ៉ាងលឿន។ កត្តា នេះធ្វើឲ្យកំណើននៃការនាំចូល មានកម្រិតទាបជាងមុន ទោះបីជាកំពុងមានការទទួលបានមកវិញនូវទំនុកចិត្តលើសេដ្ឋកិច្ចក៏ដោយ។ តម្លៃប្រេងទាបនឹងជួយទប់ការនាំចូលក្នុងឆ្នាំ ២០១៥ ដោយសារតែប្រទេសកម្ពុជាគឺជាប្រទេសដែលនាំចូលប្រេង។

**រូបលេខ ៦** ដោយសារតែកំណើននៃការនាំចេញថយចុះជាងតម្រូវការនៃការនាំចូលដែលមានការថយចុះ ឱនភាពពាណិជ្ជកម្មនៅតែបន្តធ្លាក់ចុះ។
(គិតជាលានដុល្លាអាមេរិក)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

### ៣ អតិផរណា

**១២ អត្រាអតិផរណា បានថយចុះយ៉ាងខ្លាំងដោយតម្លៃអាហារមានការធ្លាក់ចុះជាលំដាប់ និងការធ្លាក់ចុះតម្លៃប្រេងនាពេលថ្មីៗនេះ។** អតិផរណាបានធ្លាក់ចុះមកត្រឹម ១,២ ភាគរយនៅចុងឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ ២០១៣ អត្រាអតិផរណាមានប្រមាណ ៤,៦ ភាគរយ (រូបលេខ ៧)។ នៅក្នុងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ សន្ទស្សន៍តម្លៃគ្រឿងមិនមែនឧបភោគបរិភោគសំខាន់ៗ ដូចជា លំនៅដ្ឋាន ថ្លៃទឹកភ្លើងប្រើប្រាស់ និងមធ្យោបាយដឹកជញ្ជូន ស្ថិតក្នុងកម្រិតអវិជ្ជមាន ចំណែកឯសន្ទស្សន៍តម្លៃគ្រឿងឧបភោគបរិភោគ ក៏បន្តថយចុះថែមទៀត។ អត្រាអតិផរណារបស់ប្រទេសក្នុងតំបន់ និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត បានធ្លាក់ចុះ ចាប់តាំងពីត្រីមាសទីពីរក្នុងឆ្នាំ ២០១៤ មកម្លេះ។ ការធ្លាក់ចុះនេះបង្ហាញអំពីអតិផរណាទាបក្នុងប្រទេសចិន ស្របជាមួយនឹងកំណើនដ៏យឺតរបស់ប្រទេសនេះ។ ការធ្លាក់ចុះតម្លៃផលិតផលបានជួយសម្រួលដល់អតិផរណាក្នុងចំណោមប្រទេសដែលមានចំណូលទាប ចំណែកការពង្រឹងគោលនយោបាយ ក៏រួមចំណែកសម្រាលដល់អតិផរណាផងដែរ។ ហានិភ័យនៃតម្លៃគ្រឿងឧបភោគបរិភោគដោយសារតែស្ថានភាពអាកាសធាតុ El Nino ដែលបានប្រមើលទុកជាមុននោះ មិនបានកើតមានទេ។

---

[10] វៀតណាម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីសហភាពអឺរ៉ុប នឹងត្រូវចុះហត្ថលេខានៅដើមឆ្នាំនេះ នឹងបង្កើនការប្រកួតប្រជែងសម្រាប់ទីផ្សារអឺរ៉ុបដែលជាទីផ្សារនាំចេញប្រមាណពាក់កណ្តាលនៃទីផ្សារសរុបរបស់ប្រទេសកម្ពុជា។

**រូបលេខ ៧** ការថយចុះអតិផរណានៅក្នុងប្រទេសកម្ពុជា និងប្រទេសក្នុងតំបន់ នៅតែបន្ត (ការប្រែប្រួលគិតជា % ធៀបនឹងឆ្នាំ)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**រូបលេខ ៨** កំណើនរូបិយវត្ថុទូទៅកើនឡើងទ្វេដង ចំណែកប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសនៅតែបន្តកើនឡើង




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤ វិស័យរូបិយវត្ថុ

### ក) រូបិយវត្ថុសរុប អត្រាការប្រាក់ និងអត្រាប្តូរប្រាក់

**១៣ ដោយសារទទួល បានទំនុកចិត្តឡើងវិញ កំណើនរូបិយវត្ថុទូទៅ បានកើនឡើងខ្លាំងក្នុងឆ្នាំ ២០១៤ ដែលពង្រឹងវិស័យធនាគារ និងហិរញ្ញវត្ថុ។** កំណើន រូបិយវត្ថុទូទៅបានកើនដល់ ១០,៤ ពាន់លានដុល្លា អាមេរិក ឬ ៦២,៩ ភាគរយនៃផលិតផលក្នុងស្រុក សរុបនៅចុងឆ្នាំ ២០១៤ បើធៀបនឹងដំណាច់ឆ្នាំ ២០១៣ រូបិយវត្ថុទូទៅមានចំនួន ៨,២ ពាន់លានដុល្លា អាមេរិក ឬ ៥៣,៤ ភាគរយនៃផលិតផលក្នុងស្រុក សរុប។ កំណើនរូបិយវត្ថុទូទៅមានការកើនឡើងយ៉ាង លឿនក្នុងឆ្នាំ ២០១៤ ដោយសារមានទំនុកចិត្តសាជាថ្មី លើប្រព័ន្ធធនាគារ។ កំណើនរូបិយវត្ថុទូទៅមានការកើនឡើងទ្វេដងរហូតដល់ ២៩,៨ ភាគរយនៅត្រឹមចុងឆ្នាំ ២០១៤ បើធៀបនឹងបំណាច់ឆ្នាំ ២០១៣ មាន ត្រឹមតែ ១៤,៦ ភាគរយ (រូបលេខ ៨)។

**១៤ កំណើនរូបិយវត្ថុទូទៅនៅតែត្រូវបានជំរុញដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។** ចំណែកនៃប្រាក់បញ្ញើ ជារូបិយប័ណ្ណបរទេសក្នុងរូបិយវត្ថុទូទៅកើនដល់ ៨៣ ភាគរយនៅបំណាច់ឆ្នាំ២០១៤ បើធៀបនឹងឆ្នាំ ២០១៣ ដែលមានតែ ៨២ភាគរយ ហើយនេះឆ្លុះបញ្ចាំងពីកំណើនដុល្លារូបនីយកម្ម។ តួនាទីរូបិយប័ណ្ណជាតិពោលគឺ ប្រាក់រៀល នៅតែបន្តមានភាពទន់ខ្សោយ ដែលធ្វើឲ្យគោលនយោបាយរូបិយវត្ថុ នៅតែមានការពិបាកក្នុងការអនុវត្ត។ សូមមើលប្រធានបទពិសេសស្តីពីគុណសម្បត្តិ និងគុណវិបត្តិនៃដុល្លារូបនីយកម្ម។ ក្នុងចំណោមអត្រាកំណើនរូបិយវត្ថុទូទៅ ២៩,៨ ភាគរយ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសរួមចំណែក ២៥,១ ភាគរយ ប្រាក់រៀលដែលចរាចរណ៍រួមចំណែក ៣,៥ ភាគរយ ចំណែកប្រាក់បញ្ញើជាប្រាក់រៀលរួមចំណែកតែ ១,៣ ភាគរយប៉ុណ្ណោះ (រូបលេខ ៨ និង ៩)។

**រូបលេខ ៩** **កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសកំពុងកើនឡើងដោយសារទទួលបានទំនុកចិត្តសាជាថ្មីលើវិស័យធនាគារ**
ការរួមចំណែកដល់កំណើនរូបិយវត្ថុទូទៅ (ការប្រែប្រួលគិតជា % ធៀបនឹងឆ្នាំ)



ប្រភព៖ អាជ្ញាធរកម្ពុជា

**១៥** ទុនបម្រុងអន្តរជាតិដុល បានកើនឡើងរហូតដល់កម្រិតមួយខ្ពស់មិនធ្លាប់មាន ដោយមានលំហូរវិនិយោគទុនផ្ទាល់ពីបរទេស ដែលមានភាពល្អប្រសើរ ដែលគាំទ្រដល់លទ្ធភាពរបស់ធនាគារជាតិក្នុងការធ្វើឲ្យវិស័យធនាគារ និងហិរញ្ញវត្ថុមានស្ថិរភាព។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់កម្រិតមួយខ្ពស់ ដែលមិនធ្លាប់មានដោយមានទឹកប្រាក់ប្រមាណ ៤,៦ ពាន់លានដុល្លាអាមេរិក ឬប្រហែល ៤ ខែនៃការនាំចូល គិតត្រឹមបំណាច់ឆ្នាំ ២០១៤។ កត្តានេះបន្តពង្រឹងលទ្ធភាពរបស់ធនាគារជាតិក្នុងការទ្រទ្រង់ ឱនភាពគណនីចរន្តក្នុងអំឡុងពេលមានការប្រែប្រួលពីខាងក្រៅ ដែលធ្វើឲ្យមានការខ្វះខាតប្រាក់ដុល្លាអាមេរិក។ ទោះជាយ៉ាងណា អត្រាទុនបម្រុងអន្តរជាតិដុលបច្ចុប្បន្ននៅតែមានកម្រិតទាប បើធៀបនឹងស្តង់ដាក្នុងតំបន់ (សូមមើលតារាងលេខ២) ហើយគ្របដណ្តប់តែ ៥៣ ភាគរយនៃប្រាក់បញ្ញើរបស់វិស័យឯកជននៅបំណាច់ឆ្នាំ ២០១៤ ដែលធ្លាក់ចុះពី ១០៣ ភាគរយនៅបំណាច់ឆ្នាំ ២០០៥។ ដូច្នេះ លទ្ធភាពរបស់ធនាគារជាតិក្នុងការទ្រទ្រង់ឱនភាពគណនីចរន្ត នៅតែត្រូវពង្រឹងបន្ថែមទៀត។ ត្រូវតែបង្កើនលទ្ធភាពរបស់ធនាគារជាតិ ជាពិសេសក្នុងបរិបទដែលធនាគារជាតិមិនអាចដើរតួជាអ្នកផ្តល់កម្ចីចុងក្រោយដោយសារដុល្លារូបនីយកម្ម។

| តារាងលេខ ២<br>ទុនបម្រុងអន្តរជាតិដុល | ចិន | ឥណ្ឌូនេស៊ី | ម៉ាឡេស៊ី | ហ្វីលីពីន | វៀតណាម | ឡាវ |
|---|---|---|---|---|---|---|
| គិតជាពាន់លានដុល្លា | 216.6 | 111.9 | 116.1 | 87.7 | 38.0 | 0.75 |
| ជាចំនួនខែនៃការនាំចូលទំនិញ និងសេវាកម្មនាពេលខាងមុខ | 9.2 | 7.2 | 5.6 | - | 2.6 | 1.1 |
| ប្រភព៖ អត្ថបទទី IV របាយការណ៍បុគ្គលិក IMF (ឆ្នាំ ២០១៣ និង ២០១៤) | | | | | | |

**១៦** **អត្រាប្រាក់កម្ចី មានការកើនឡើងបន្តិចដោយសារតែមានកំណើនឥណទានក្នុងប្រទេសយ៉ាងលឿនសាជាថ្មីម្តងទៀត**[11]។ អត្រាការប្រាក់ជាមធ្យមរបស់ប្រាក់ដុល្លាអាមេរិក ក្នុងប្រទេស អត្រាប្រាក់កម្ចីក្នុងរយៈពេល ១២ ខែ បានកើនឡើងរហូតដល់ ១១,៥១ ភាគរយក្នុងមួយឆ្នាំនៅបំណាច់ឆ្នាំ ២០១៤ បើធៀបនឹងបំណាច់ឆ្នាំ២០១៣ អត្រាប្រាក់កម្ចីមានតែ ១១,៣ភាគរយ(រូបលេខ១០)។

**រូបលេខ ១០** **អត្រាប្រាក់កម្ចីជាមធ្យមគិតជាដុល្លាអាមេរិកមានការកើនឡើង។**
អត្រាការប្រាក់ជាប្រាក់ដុល្លាអាមេរិកក្នុងរយៈពេល ១២ខែ (ភាគរយក្នុងមួយឆ្នាំ)



ប្រភព៖ អាជ្ញាធរកម្ពុជា

11 ធនាគារកណ្តាលអាមេរិក (US Federal Reserve) បញ្ចប់គោលនយោបាយរូបិយវត្ថុគាំទ្រ (Quantitative easing) ខែតុលា ឆ្នាំ ២០១៤។

យ៉ាងណាក៏ដោយ អត្រាការប្រាក់បញ្ញើមានកាលកំណត់របស់ប្រាក់ដុល្លារអាមេរិក (ជាមធ្យម ១២ ខែ) នៅតែមានកម្រិតត្រឹម ៤,២ ភាគរយក្នុងមួយឆ្នាំ។ ដោយសារតែមានការប្រកួត ប្រជែងកាន់តែខ្លាំងក្នុងចំណោមធនាគារ គំលាតអត្រាការប្រាក់ (ភាពខុសគ្នារវាងអត្រាប្រាក់កម្ចីជាក់ស្តែង និង អត្រាប្រាក់បញ្ញើ) បានធ្លាក់ចុះនៅចន្លោះឆ្នាំ ២០១០ និង ២០១២ ទោះបីជានៅ តែមានគម្លាតធំក៏ដោយ។

**១៧ ការកំណត់អត្រាប្តូរប្រាក់នៅតែជួយទ្រទ្រង់ដល់ស្ថិរភាពតម្លៃ។** ប្រាក់រៀលកម្ពុជាមានតម្លៃឋិតក្នុងរង្វង់ប្រមាណ ៤.០០០ រៀលក្នុង ១ ដុល្លារអាមេរិកអស់រយៈពេលជាច្រើនឆ្នាំមកទល់ ពេលនេះ។ ដោយសារមានការកើនឡើងតម្លៃប្រាក់ដុល្លាអាមេរិក តម្លៃប្រាក់រៀលកម្ពុជាក៏មានការកើនឡើងដែរ ដោយតម្លៃប្រាក់រៀលបានថយចុះតិចតួចប៉ុណ្ណោះធៀបនឹងប្រាក់ដុល្លារអាមេរិកដោយ ១ ដុល្លាអាមេរិក ប្តូរបាន ៤.០៧៥ រៀល នៅចុងឆ្នាំ ២០១៤ បើធៀបនឹងចុងឆ្នាំ ២០១៣ ១ ដុល្លារអាមេរិកប្តូរបាន ៣.៩៩៥ រៀល។ យ៉ាងណាក៏ដោយការកំណត់អត្រាប្តូរប្រាក់ ការចងភ្ជាប់រវាងតម្លៃប្រាក់រៀលនឹងប្រាក់ដុល្លាអាមេរិក មិនបានជំរុញឲ្យមានការបន្ថយដុល្លារូបនីយកម្មឡើយ។ លើសពីនេះទៀត ដោយសារតែតម្លៃរូបិយប័ណ្ណក្នុងតំបន់ មានការធ្លាក់ចុះធៀបនឹងប្រាក់ដុល្លារអាមេរិក ដុល្លារូបនីកម្មបានធ្វើឲ្យការ នាំចេញរបស់ប្រទេសកម្ពុជា មិនសូវមានការប្រកួតប្រជែងក្នុងទីផ្សារក្រៅប្រទេសអាមេរិកទេ។ យ៉ាងណាក៏ដោយ អត្រាប្តូរប្រាក់ជាក់ស្តែង និង អត្រាប្តូរប្រាក់ពិតមានការធ្លាក់តម្លៃបន្តិច(រូបលេខ១១)។ សន្ទស្សន៍អត្រាប្តូរប្រាក់ជាក់ស្តែង កើនឡើងរហូតដល់ ១០៥,២ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ដោយកើនពី ១០៣,៨ នៅបំណាច់ឆ្នាំ ២០១៣ ចំណែកសន្ទស្សន៍អត្រាប្តូរប្រាក់ពិតក៏ មានការកើនឡើងរហូតដល់ ១១១,៩ ដោយកើនពី ១០៩,៧ ក្នុងអំឡុងពេលដូចគ្នានេះដែរ។

រូបលេខ១១ អត្រាប្តូរប្រាក់ជាក់ស្តែង (NEER) និងអត្រាប្តូរប្រាក់ពិត (REER) បានថយចុះ: (សន្ទស្សន៍ឆ្នាំ ២០១០ = ១០០)



ប្រភព៖ IFS

## ខ) វិស័យធនាគារ

**១៨ ភាពស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុនៅតែបន្តដោយសារតែកំណើនប្រាក់បញ្ញើ និងឥណទានមានការកើនឡើងយ៉ាងលឿនក្នុងឆ្នាំ ២០១៤ ដែលបង្កើនអន្តរការីហិរញ្ញវត្ថុ និងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច។** ប្រាក់បញ្ញើរបស់វិស័យឯកជនបានកើនឡើងដល់ ៨,៨១ ពាន់លានដុល្លាអាមេរិក ឬកើនឡើង ៣០,៦ ភាគរយ នៅបំណាច់ឆ្នាំ ២០១៤ ធៀបនឹងបំណាច់ឆ្នាំ២០១៣ ប្រាក់បញ្ញើក្នុងវិស័យឯកជនមាន ៦,៨៨ ពាន់លានដុល្លា អាមេរិក ឬកើនឡើង ១៤,២ ភាគរយ។ កំណើនឥណទានដែលបានធ្លាក់ចុះមកត្រឹម ២០ ភាគរយក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ ២០១៤ បានកើនឡើងម្តងទៀត ដោយកើនរហូតដល់ ៣១,៣ ភាគរយនៅបំណាច់ឆ្នាំ ២០១៤ ដោយមានឥណទានមិនទាន់ទូទាត់សងចំនួន ៨,៨៩ ពាន់លានដុល្លារអាមេរិក។ ជាលទ្ធផល អនុបាតឥណទានធៀបនឹងប្រាក់

បញ្ញើ បានកើនឡើងពី ៨២,២ ភាគរយនៅពាក់កណ្តាលឆ្នាំ ២០១៤ ទៅ ៨៧,២ ភាគរយនៅបំណាច់ឆ្នាំ ២០១៤ ប៉ុន្តែទាបជាង ៩០ ភាគរយនៅបំណាច់ឆ្នាំ ២០១៣ (រូបលេខ ១២)។

**រូបលេខ១២ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើកំពុងមានការកើនឡើង**
អនុបាតឥណទានធៀបនឹង ប្រាក់ បញ្ញើ (គិតជាភាគរយ)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**១៩** វិស័យនានា ដែលទទួលបានការបង្កើនឥណទានច្រើនបំផុតនាពេលថ្មីៗនេះ រួមមានការលក់រាយ ការលក់ដុំ សំណង់ អចលនទ្រព្យ និងកសិកម្ម។ ដោយគាំទ្រវិស័យសេវាកម្មដែលកំពុងមានកំណើននោះ ការផ្តល់ឥណទានដល់អាជីវកម្មលក់ដុំ និងលក់រាយ មានការកើនឡើងបន្ថែមទៀត ដោយមានចំនួន ៣៥,៩ ភាគរយនៃឥណទានសរុបត្រឹមខែតុលា ឆ្នាំ២០១៤ បើធៀបនឹងបំណាច់ឆ្នាំ ២០១៣ ការផ្តល់ឥណទាននេះមានត្រឹមតែ ៣៤,៣ ភាគរយប៉ុណ្ណោះ។ វិស័យសំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ បានស្រូបយកឥណទានចំនួន ១៩,០ ភាគរយនៃ ឥណទានសរុបបើធៀបនឹង បំណាច់ឆ្នាំ ២០១៣ វិស័យទាំងនេះបានស្រូបយកឥណទានត្រឹមតែ ១៧,២ ភាគរយប៉ុណ្ណោះ។ ការផ្តល់ឥណទានដល់វិស័យកសិកម្មក៏មានការកើនឡើងដែរ ដោយមានឥណទានចំនួន ១០,៤ ភាគរយនៃឥណទានសរុប ដែលកើនពី ១០,១ ភាគរយក្នុងឆ្នាំ ២០១៣ (រូបលេខ ១៣)។

**រូបលេខ១៣ វិស័យលក់រាយ និងលក់ដុំ នៅតែបន្តស្រូបយកឥណទានច្រើនជាង ១ ភាគ ៣ នៃឥណទានសរុប (គិតជាភាគរយ)**




ប្រភព ៖ អាជ្ញាធរកម្ពុជា

**២០** ទោះជាការមានធនាគារច្រើន ជួយពង្រឹងការប្រកួតប្រជែង និងបង្កើនប្រសិទ្ធភាពក៏ដោយ ក៏កង្វះខាតមាត្រដ្ឋាន ធ្វើឲ្យធនាគារភាគច្រើនទទួលបានចំណូលតិចពីការវិនិយោគ[12]។ ដូច្នេះ ចាំបាច់ត្រូវបន្តពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុបន្ថែម ទៀត ដោយពង្រឹងការសម្របសម្រួលអន្តរស្ថាប័ន លើកកម្ពស់សមត្ថភាពគ្រប់គ្រង កែលម្អការអនុវត្តក្នុងការគ្រប់គ្រងហានិភ័យក្នុងវិស័យធនាគារ និងបង្កើនគុណភាពទ្រព្យរបស់ធនាគារ។

## ៥ ចរិតស័យសារពើពន្ធ

**២១** ការពង្រឹងផ្នែកសារពើពន្ធ នៅតែបន្តដោយសារតែការប្រមូលចំណូល ដែលមានភាពប្រសើរឡើង ហើយការចំណាយ ដែលមានកម្រិតកំណត់ ជួយកែលម្អឱនភាពសារពើពន្ធជារួម និងរក្សាស្ថិរភាពម៉ាក្រូសារពើពន្ធ។ ចំណូលដែលកើនឡើងជាងមុន បានផ្តល់ជាធនធានបន្ថែមទៀតដល់ការផ្តល់ហិរញ្ញប្បទានក្នុងការដំឡើងប្រាក់វេតន៍ និងការចំណាយជាអាទិភាព។ ដោយសារតែកម្មវិធី

[12] ធនាគារនៅកម្ពុជា ៖ ឱកាសកំណើនខ្ពស់ធៀបនឹងការទទួលបានការចំណេញតិចពី Equity conundrum ដៃគូជាយុទ្ធសាស្ត្រទន្លេមេគង្គ ខែវិច្ឆិកា ឆ្នាំ២០១៤។

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូល ក្នុងប្រទេសបានកើនឡើងបន្ថែមទៀត ហើយត្រូវបានប៉ាន់ស្មានថាកើនដល់ ១៦,១ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ បើធៀបនឹងឆ្នាំ ២០១៣ ចំណូលក្នុងប្រទេសមានចំនួនតែ ១៥,១ ភាគរយនៃផលិតផលក្នុងស្រុកសរុបប៉ុណ្ណោះ។ ការចំណាយនៅតែដដែលត្រឹម ២០,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ យ៉ាងណាក៏ដោយ ឱនភាពសារពើពន្ធសរុប (រួមទាំងជំនួយឥតសំណង) មានភាពប្រសើរឡើងបន្តិច ដោយមានចំនួន ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដោយសារតែការថយចុះនៃជំនួយឥតសំណង បើធៀបនឹងឆ្នាំ ២០១៣ ឱនភាពសារពើពន្ធសរុបមានចំនួន ២,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប។

## ក) សមាសភាគចំណូល

**២២** ចំណូលក្នុងស្រុកសរុប របស់រដ្ឋាភិបាល **ត្រូវបានប៉ាន់ស្មានថាមានចំនួន ១៦,១ ភាគរយនៃផលិតផលក្នុងស្រុកសរុប ឬ ២,៦៨ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៤ ដោយសារតែមានការពង្រឹងការគ្រប់គ្រងចំណូល ដែលបានកែលម្អស្ថានភាពសារពើពន្ធ** (រូបលេខ ១៤)។ ចំណូលនេះមានចំនួន ១,០ ភាគរយ នៃការកើនឡើងនៃផលិតផលក្នុងស្រុកសរុប ដោយលើសពីការកំណត់ ០,៥ ភាគរយនៃកំណើនផលិតផលក្នុងស្រុកសរុបក្នុងមួយឆ្នាំៗ ដែលកំណត់ក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដើម្បីបន្តពង្រឹងការប្រមូលចំណូលថ្មីៗនេះអាជ្ញាធរបានអនុវត្តយុទ្ធសាស្ត្រប្រមូលពន្ធឆ្នាំ ២០១៤-១៨ រយៈពេលមធ្យម (សម្រាប់ព័ត៌មានលម្អិត សូមមើលប្រអប់លេខ ៣)។

ប្រអប់លេខ ៣

### យុទ្ធសាស្ត្រប្រមូលប្រាក់ចំណូល ឆ្នាំ ២០១៤-២០១៨

- **គោលការណ៍សំខាន់ៗ ៖** (១) សក្តានុពលពេញលេញ (២) មិនមានការយកពន្ធថ្មី (៣) មិនមានការដំឡើងអត្រាពន្ធ និង (៤) ងាយស្រួល សមធម៌ ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- **សសរស្តម្ភទាំង ៣៖** (១) ការគ្រប់គ្រងការប្រមូលប្រាក់ចំណូល (២) គោល នយោបាយប្រមូលប្រាក់ចំណូល និង (៣) ការពិនិត្យតាមដាន និងការ វាយតម្លៃ។
- **គោលដៅ ៖** ០,៥ ភាគរយនៃកំណើនប្រាក់ចំណូលបច្ចុប្បន្នពីផលិតផលក្នុង ស្រុកសរុបក្នុងមួយឆ្នាំ។ ការពិនិត្យគោលនយោបាយ ៖ ពន្ធអាករពន្ធតម្លៃ បន្ថែម មូលដ្ឋានគិតពន្ធ (ប្រភេទរបប)ការបន្ថយពន្ធ ពន្ធលើទ្រព្យ សម្បត្តិ។ ការសិក្សាពន្ធលើប្រាក់ចំណូល និងពង្រាងច្បាប់ស្តីពីទ្រព្យសម្បត្តិរដ្ឋ។

ចំណុចដៅប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន

| អគ្គនាយកដ្ឋាន | 2014b | 2015p | 2016p | 2017p | 2018p |
|---|---|---|---|---|---|
| | គិតជាភាគរយនៃផសស | | | | |
| GDCE | 6.85 | 7.08 | 7.24 | 7.39 | 7.54 |
| *ប្រែប្រួល* | | *0.23* | *0.16* | *0.15* | *0.15* |
| GDT | 5.87 | 6.26 | 6.62 | 6.97 | 7.29 |
| *ប្រែប្រួល* | | *0.39* | *0.36* | *0.35* | *0.32* |
| ចំណូលមិនមែនសារពើពន្ធ | 2.48 | 2.35 | 2.40 | 2.45 | 2.51 |
| *ប្រែប្រួល* | | *-0.13* | *0.05* | *0.05* | *0.06* |
| សរុប | 15.20 | 15.69 | 16.26 | 16.81 | 17.34 |

GDEC ៖ អគ្គនាយកដ្ឋានពន្ធគយ និងរដ្ឋាករកម្ពុជា
GDT ៖ អគ្គនាយកដ្ឋានពន្ធដា
b=ថវិកា p=ការព្យាករណ៍

**ផ្នែកសំខាន់ៗ**

| អគ្គនាយកដ្ឋាន | **វង្វាស់ ឬវិស័យសំខាន់ៗ** |
|---|---|
| GDCE | ចុះក្នុងបញ្ជីដោយស្វ័យប្រវត្តិ ការគ្រប់គ្រងហានិភ័យ សវនកម្មក្រោយការជម្រះបញ្ជី ការប្រឆាំងការជួញដូរ ការិយាល័យច្រកចេញចូលតែមួយ ស្ថាប័នធនធានមនុស្ស និងការពង្រឹងសវនកម្ម |
| GDT | ការចុះបញ្ជី សេវាកម្ម សវនកម្មពន្ធ បំណុល អង្គភាព ធនធានមនុស្ស និងបច្ចេកវិទ្យា |
| ចំណូលមិនមែនសារពើពន្ធ | ប្រព័ន្ធចេញវិក្ក័យបត្រ អាកាសចរណ៍ស៊ីវិល ទេសចរណ៍ ទិដ្ឋាការ ទូរគមនាគមន៍ ការជួល សហគ្រាសសាធារណៈ កាស៊ីណូ និងឯកជន ភាវូបនីយកម្ម |

ប្រភព ៖ អាជ្ញាធរកម្ពុជា

យុទ្ធសាស្ត្រនេះត្រូវបានរំពឹងថា នឹងដោះស្រាយចំណុចខ្សោយផ្សេងៗ ក្នុងការគ្រប់គ្រងការប្រមូលពន្ធ ដោយគាំទ្រដល់ការពង្រីកមូលដ្ឋានប្រមូលពន្ធ ដោយនៅពេលជាមួយគ្នានោះ រក្សាឲ្យបានប្រភេទពន្ធ និងអត្រាពន្ធដែលមានស្រាប់។

**រូបលេខ ១៤ ចំណូលមានការកើនឡើងដោយសារតែការប្រមូលពន្ធដោយប្រយោល** (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)




e=ការប៉ាន់ស្មាន b=ថវិកា
ប្រភព ៖ អាជ្ញាធរកម្ពុជា

## ខ) សមាសភាគចំណាយ

**២៣** ចំណាយទូទៅ សរុបរបស់រដ្ឋាភិបាលត្រូវបានប៉ាន់ស្មានថា នៅតែមានភាពស្របទៅនឹងថវិកា ដែលបានគ្រោងទុកចំនួន ២០,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ ឬ ៣,៤ ពាន់លានដុល្លារអាមេរិក ដែលជួយដល់ស្ថានភាពរបស់អាជ្ញាធរក្នុងការពង្រឹងទ្រនាប់ទប់ទល់សារពើពន្ធ (រូបលេខ ១៥)។ ការចំណាយនេះស្មើនឹង ១ ភាគរយនៃផលិតផលក្នុងស្រុកសរុប ទាបជាងការចំណាយក្នុងឆ្នាំ ២០១៣ ដែលមានចំនួន ២១,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប។ អាជ្ញាធរហាក់មានការត្បិតត្បៀតលើការចំណាយ ពិសេសការចំណាយមូលធនក្នុងអំឡុង ពេលក្រោយការជំរុញសារពើពន្ធ ដោយសារមានការពង្រឹងបន្ថែមលើប្រសិទ្ធភាពនៃការចំណាយ។ យ៉ាងណាក៏ដោយ ការបន្តពង្រីកលំហសារពើពន្ធរបស់ប្រទេសអាចជួបប្រទះបញ្ហា ដោយសារតែកំណើនប្រាក់បៀវត្សរ៍យ៉ាងលឿននេះ។

**រូបលេខ ១៥ ប្រាក់បៀវត្សរ៍កើនឡើង នៅពេលដែលការចំណាយមូលធនមានកម្រិតកំណត់ (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)**




ប្រភព៖ អាជ្ញាធរកម្ពុជា

## គ) គុណភាពសារពើពន្ធ

**២៤** កំណើនការប្រមូលចំណូលជួយលើកតម្កើងការអនុវត្តសារពើពន្ធ ប្រកបដោយនិរន្តរភាព ចំណែកការកែលម្អប្រសិទ្ធភាពចំណាយ ក៏ជួយពង្រឹងការផ្តល់សេវា របស់វិស័យសាធារណៈដែរ។ ឱនភាពសារពើពន្ធសរុប(រួមទាំងជំនួយឥតសំណង) ត្រូវបានប៉ាន់ស្មានថានឹង មានភាពប្រសើរឡើងថែមទៀត ដោយមានចំនួន ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបឆ្នាំ ២០១៤ បើធៀបនឹងឆ្នាំ២០១៣ ឱនភាពសារពើពន្ធសរុប នេះមានចំនួន ២,៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប (រូបលេខ ១៦)។ ឱនភាពនេះនៅ តែទទួលបានហិរញ្ញប្បទានពីមូលនិធិពីខាងក្រៅ (រូបលេខ ១៧)។ ហេតុដូច្នេះ ប្រាក់បញ្ញើរដ្ឋាភិបាលកើនឡើងរហូតដល់ ១,១៣ ពាន់លានដុល្លាអាមេរិក ត្រឹមបំណាច់ឆ្នាំ ២០១៤ ធៀបនឹងបំណាច់ឆ្នាំ ២០១៣ ប្រាក់

បញ្ញើនេះមានត្រឹម តែ ៧០០ លាន ដុល្លាអាមេរិក ប៉ុណ្ណោះ។ ប្រាក់បញ្ញើរដ្ឋាភិបាលពិតជាមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ដោយសារប្រាក់បញ្ញើទាំងនោះអាចត្រូវបាន យកមកប្រើប្រាស់ជាការជំរុញដល់សារពើពន្ធ ដើម្បីទប់ទល់ជាមួយនឹងការប្រែប្រួលពីខាងក្រៅ ដោយមិនចាំបាច់ ធ្វើការខ្ចីបន្ថែមទេ។ សូមកត់សម្គាល់ថា ដូចបាន ពន្យល់នៅផ្នែកវិស័យរូបិយវត្ថុខាងលើ គោលនយោបាយរូបិយវត្ថុរបស់ប្រទេសមានកម្រិត ដោយសារតែដុល្លារូបនីយកម្ម។

**រូបលេខ ១៦** **ឱនភាពសារពើពន្ធសរុបមានភាពប្រសើរឡើងក្នុងឆ្នាំ ២០១៤ (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)**




e=ការប៉ាន់ស្មាន b=ថវិកា
ប្រភព ៖ អាជ្ញាធរកម្ពុជា

**រូបលេខ ១៧** **មូលនិធិពីខាងក្រៅនៅតែបន្តផ្តល់ហិរញ្ញប្បទានទប់ទល់នឹងឱនភាពសារពើពន្ធ** (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**២៥** ការវិភាគរួមគ្នា រវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិអំពីនិរន្តរភាពបំណុល (DSA) ដែលបានធ្វើក្នុងឆ្នាំ២០១៣ បានបង្ហាញថា ចំណាត់ថ្នាក់ ភាពតានតឹងផ្នែកបំណុលរបស់ប្រទេសកម្ពុជានៅមានកម្រិតទាប ដោយសូនាករស្តីពីបន្ទុកបំណុលទាំងអស់ត្រូវបានព្យាករថា ស្ថិតនៅក្រោមកម្រិតកំណត់ នៃសូចនាករស្តីពីបន្ទុកបំណុលទាំងនោះ[13]។ បរិមាណបំណុលបរទេសរបស់កម្ពុជា (រួមទាំងបំណុលដែលមិនទាន់បានបង់តាមកាលកំណត់) ត្រូវបានព្យាករថានឹងកើនដល់ ៥,៦ ពាន់លានដុល្លាអាមេរិក ឬ ៣៣,៩ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៥។

[13] គិតមកត្រឹមពេលសរសេរឯកសារស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែមេសា ឆ្នាំ២០១៥ ការធ្វើការវាយតម្លៃ DSA ថ្មី មិនទាន់បានអនុវត្តនៅឡើយទេ។

## ឃ) ថវិកាឆ្នាំ ២០១៥

**២៦ កំណែទម្រង់ថវិកាក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានពង្រឹងទំនាក់ទំនងរវាងច្បាប់ថវិកា ឆ្នាំ២០១៥ និងអាទិភាពផ្សេងៗ។** ហេតុដូច្នេះ ការរៀបចំសមាហរណកម្ម និងតម្លាភាពនៃថវិកា មានការរីកចម្រើនយ៉ាងខ្លាំង។ ទាំងថវិកាដែលទទួលហិរញ្ញប្បទានក្នុងប្រទេស និងពីក្រៅប្រទេស ត្រូវបានរៀបចំគ្រប់គ្រាន់សម្រាប់គ្រប់ក្រសួងទាំងអស់ ដែលគាំទ្រដល់ការ ធ្វើសមាហរណកម្មថវិកាពេញលេញមួយ និងជួយដល់អាជ្ញាធរ ក្នុងការរៀបចំថវិកាផ្អែកលើកម្មវិធី និងលទ្ធផលការងារ ដែលផ្សារភ្ជាប់ទៅ នឹងយុទ្ធសាស្ត្រថ្នាក់ជាតិ និងថ្នាក់តំបន់ ក៏ដូចជាចំណុចអាទិភាពផ្សេងៗដែរ។ ភាពប្រសើរឡើងនេះក៏ផ្តល់ជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការអនុវត្តដ៏ជោគជ័យនៃ ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុផងដែរ (សម្រាប់ព័ត៌មានលម្អិត សូមមើលប្រអប់លេខ៤)។

**២៧ ក្នុងថវិកាឆ្នាំ ២០១៥ ចំណូលថវិកាអាចត្រូវបានពង្រឹងបន្តទៀត។** គោលដៅប្រាក់ចំណូលដែលមានលក្ខណៈអភិរក្ស ជាមួយនឹងការធ្លាក់ចុះជំនួយឥតសំណង បានធ្វើឲ្យឱនភាពរួមកើនឡើង (រួមទាំងជំនួយឥតសំណង) ដែលត្រូវបានប៉ាន់ស្មានថាមានចំនួន ៣,៨ ភាគរយ នៃផលិតផលក្នុងស្រុកសរុបឆ្នាំ ២០១៥ បើធៀបនឹងឆ្នាំ ២០១៤ ឱនភាពរួមនេះមានចំនួនតែ ២,៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបប៉ុណ្ណោះ(រូបលេខ ១៦)។ ចំណូលក្នុងប្រទេស ដែលត្រូវបានកំណត់សម្រាប់សារពើពន្ធឆ្នាំ ២០១៥ ដែលមានចំនួន ១៥,៩ ភាគរយនៃផលិតផលក្នុងស្រុកសរុប ហាក់មានកម្រិត

### ប្រអប់លេខ ៤ ថវិកាប្រចាំឆ្នាំ២០១៥ និងកំណែទម្រង់ថវិកា

កំណែទម្រង់ថវិកាសំខាន់ៗជាច្រើនត្រូវបានអនុវត្តឡើងក្នុងថវិកាប្រចាំឆ្នាំ២០១៥។

**បច្ចុប្បន្ននេះ ថវិកាដែលទទួលហិរញ្ញវត្ថុពីរដ្ឋាភិបាល ឬហិរញ្ញវត្ថុក្នុងស្រុកសម្រាប់ចំណាយមូលធន មានការកើនឡើងសម្រាប់ក្រសួងទាំងអស់។** រហូតមកដល់ឆ្នាំ២០១៤ វិភាជន៍ថវិកាមូលធនត្រូវបានធ្វើឡើងសម្រាប់តែក្រសួងចំនួន ៤ ប៉ុណ្ណោះ រួមមាន ក្រសួងធនធានទឹក និង ឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងគ្រប់គ្រងដែនដី សំណង់ និងនគរូបនីយកម្ម។ ខុសពីឆ្នាំមុនៗ វិភាជន៍ថវិកាពេញលេញសម្រាប់ឆ្នាំ២០១៥ មិនបានទុកឲ្យការសម្រេចចិត្តផ្នែកថវិកា តាមឆន្ទានុសិទ្ធិហួសពីការគ្រប់គ្រងរបស់ក្រសួង ដែលបង្កើនការគ្រប់គ្រង និងតម្លាភាពវិភាជន៍ថវិកាមូលធន។

**បច្ចុប្បន្ននេះ សមាសភាគថវិកាដែលទទួលបានហិរញ្ញវត្ថុពីម្ចាស់ជំនួយ ឬហិរញ្ញវត្ថុពីខាងក្រៅ ត្រូវបានបែងចែកសម្រាប់ក្រសួងទាំងអស់។** ពីមុនដោយសារតែការបែងចែកការគ្រប់គ្រងថវិកាដែលញែកដាច់សមាសភាគដែលទទួលបានហិរញ្ញវត្ថុពីម្ចាស់ជំនួយពីសមាសភាគដែលទទួលបានហិរញ្ញវត្ថុពីរដ្ឋាភិបាល ក្រសួងមិនអាចព្យាករបានពេញលេញពីថវិការបស់ខ្លួនឡើយ។ ការកើនឡើងថវិកាប្រចាំឆ្នាំ២០១៥ ជួយដល់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ថវិកាឆ្នាំ២០១៣-២០១៨ និងស្របតាមវិសហាមជ្ឈការនៃការគ្រប់គ្រងថវិកា ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងកាន់តែប្រសើររវាងថវិកាប្រចាំឆ្នាំ និងអាទិភាពគោលនយោបាយ ព្រមទាំងទទួលបានគណនេយ្យភាព និងលទ្ធផល។

**បញ្ហាដែលមិនទាន់បានដោះស្រាយក្នុងការធ្វើបុរេប្រទានសាច់ប្រាក់ក្នុងចំនួនដ៏ច្រើនកំពុងត្រូវបានដោះស្រាយ។** ការធ្វើបុរេប្រទានសាច់ប្រាក់មានចំណែកធ្វើឲ្យក្នុងរបាយការណ៍ ហិរញ្ញវត្ថុបំណាច់ឆ្នាំមិនត្រូវបានបញ្ចប់ឲ្យទាន់ពេលវេលា។ ហេតុដូច្នេះទើបធ្វើឲ្យមានភាពយឺតយ៉ាវដល់សវនកម្មថវិកាប្រចាំឆ្នាំ។ ថវិកាឆ្នាំ២០១៥ ចំនួន ២៧៦,៥០០ លានរៀល (៦៩ លានដុល្លារអាមេរិក) ត្រូវបានបែងចែកដើម្បីបញ្ចប់ការធ្វើបុរេប្រទានសាច់ប្រាក់នៅអំឡុង ឆ្នាំ២០០៤-២០១៤ ដើម្បីចាប់ផ្តើមតុល្យភាពថវិកា "ថ្មីស្រឡាង" ក្នុងឆ្នាំ២០១៥ សម្រាប់អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) កំពុងតែជួយកាត់បន្ថយ និងលុបបំបាត់ការធ្វើបុរេប្រទានសាច់ប្រាក់ក្នុងចំនួនដ៏ច្រើនតាមរយៈការរៀបចំដំណើរការការងារ និងការទូទាត់។

**សារាចរថវិកាឆ្នាំ២០១៥ លើកឡើងពីអាទិភាពកំណែទម្រង់សំខាន់ៗ។** អាទិភាពសម្រាប់ការគ្រប់គ្រងទូទៅកំពុងតែពង្រឹងការគ្រប់គ្រងដីធ្លី និងកំណែទម្រង់តុលាការ ដោយផ្សាភ្ជាប់ការដំឡើងប្រាក់បៀវត្សរ៍ និងកំណែទម្រង់បញ្ជីប្រាក់បៀវត្សរ៍ តាមកំណែទម្រង់រដ្ឋបាលសាធារណៈ (PAR) និងលើកកម្ពស់អន្តរវិស័យតាម PFMRP PAR និងការប្រឆាំងអំពើពុករលួយ។ អាទិភាពវិស័យសង្គមមានដូចជា គុណភាពការអប់រំ ការបណ្តុះបណ្តាលបច្ចេកទេស ជំនាញ សេវាសុខាភិបាល មូលនិធិសមធម៌សុខាភិបាល មូលនិធិសោធននិវត្តន៍ និងបណ្តាញសុវត្ថិភាពសង្គម។ អាទិភាពវិស័យសេដ្ឋកិច្ចផ្តោតលើការពង្រឹងការគ្រប់គ្រងសម្បទានដីធ្លី និងធនធានធម្មជាតិ ការបង្កើនតម្លៃបន្ថែមវិស័យទេសចរណ៍ និងការពង្រីក និងការជួសជុលប្រព័ន្ធផ្លូវថ្នល់ និងធារាសាស្ត្រ។

ទាប ហើយទាបជាងបន្តិចពីការប្រមូលចំណូលដែលបានប៉ាន់ស្មាននៅឆ្នាំ ២០១៤ ថាមានចំនួន ១៦,១ ភាគរយនៃផលិតផលក្នុងស្រុកសរុបនោះ។ យ៉ាងណាក៏ដោយ ភាគរយនេះមានកម្រិតខ្ពស់ជាងមុន ១៥,៥ ភាគរយនៃផលិត ផលក្នុងស្រុកសរុប ដែលគ្រោងទុកក្នុងថវិកា សម្រាប់ឆ្នាំ ២០១៤។ គោលដៅចំណូលឆ្នាំ ២០១៥ នៅតែបន្តពឹងផ្អែកលើពន្ធប្រយោល។ ចំណូលមិនមែនពន្ធចំនួន ១,៩៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដែលគ្រោងសម្រាប់ឆ្នាំ ២០១៥ ទាបជាងគោលដៅ ២,៣៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រប្រមូលចំណូល។ ការចំណាយទូទៅសរុបរបស់រដ្ឋាភិបាលត្រូវបានគ្រោងថានៅតែមានចំនួន ២០,៥ ភាគរយ

រូបលេខ ១៨ ការកើនឡើងនៃប្រាក់បៀវត្សរ៍ទាមទារឲ្យមានការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ចំណែកសមាសភាគដែលមិនមែនប្រាក់បៀវត្សរ៍គួរតែផ្តល់លទ្ធភាពសម្រាប់ប្រតិបត្តិការ និងថវិកាតម្រូវគ្រប់គ្រាន់ (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)




នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៥។ ដូច្នេះ ឱនភាពសារពើពន្ធ ដោយមិនរាប់បញ្ចូលជំនួយឥតសំណង មានការកើនឡើងបន្តិចត្រឹម ៤,៦ ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៥ បើធៀបនឹងឆ្នាំ ២០១៤ ឱនភាពនេះមានចំនួន ៤,៣ ភាគរយ។

**២៨ ការដំឡើងប្រាក់បៀវត្សរ៍ យ៉ាងលឿននឹងទាមទារឲ្យមាន ការពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់។** ដោយសារមានគោលដៅដំឡើងប្រាក់បៀវត្សរ៍អប្បបរមា សម្រាប់វិស័យសាធារណៈឲ្យមានចំនួន ១ លានរៀល (ឬប្រហែល ២៥០ ដុល្លាអាមេរិក) ក្នុងមួយខែ ត្រឹមឆ្នាំ ២០១៨ កំណើនប្រាក់បៀវត្សរ៍ប្រចាំឆ្នាំ (រូបលេខ ១៨) ទាមទារឲ្យមាន ការពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់[14]។ ដើម្បីសម្រេចបានគោលដៅនេះ ការប៉ាន់ស្មានមួយចំនួនបានបង្ហាញពីកំណើនប្រាក់បៀវត្សរ៍សរុបប្រចាំឆ្នាំ (មន្ត្រីស៊ីវិល សន្តិសុខ និយោជា) រហូតដល់ ២០ ភាគរយ ដែលខ្ពស់ជាងកំណើនចំណូលក្នុងប្រទេសប្រចាំឆ្នាំ ដែលមានចំនួនប្រហែលជា ១៥ ភាគរយ ដែលត្រូវបានព្យាករនៅក្នុងយុទ្ធសាស្ត្រប្រមូលចំណូល។ សមាសភាគមិនមែនប្រាក់បៀវត្សរ៍នៅតែបានតឹ្បតត្បៀត ដោយមិនបានកើនឡើងជាភាគរយនៃផលិតផល ក្នុងស្រុកសរុប តាំងពីឆ្នាំ ២០១១។ ហេតុដូច្នេះ ជាការសំខាន់ត្រូវធានាថា ចំណាយអាទិភាព រួមទាំងថវិកាសម្រាប់ប្រតិបត្តិការ និងការថែរក្សា (ក្រោមសមាសភាគមិនមែនប្រាក់បៀវត្សរ៍) ទទួលបានហិរញ្ញប្បទានគ្រប់គ្រាន់។

**២៩ ដោយសារតែ ការរឹតត្បិតថវិកាមូលធន ការថែរក្សា តម្រូវការវិនិយោគមូលធននឹងធ្វើទៅបានដោយការពង្រឹងប្រសិទ្ធភាពចំណាយ និង ការគ្រប់គ្រងគុណភាព វិនិយោគសាធារណៈកាន់តែប្រសើរឡើង** (រូបលេខ ១៩)។ ដើម្បីរក្សា ការវិនិយោគសាធារណៈ ឲ្យមានស្ថានភាពប្រសើរចាំបាច់ត្រូវមាន ការបែងចែកថវិកាបន្ថែមសម្រាប់ប្រតិបត្តិការ និងការថែរក្សា។ ការពង្រឹងការគ្រប់គ្រងគុណភាពនៃការវិនិយោគសាធារណៈ ជា

[14] វេទិកាសាធារណៈស្តីពីច្បាប់ថវិកាថ្មីឆ្នាំ២០១៥ (ផ្នែកស្តីពីហានិភ័យ និងបញ្ហាប្រឈម) ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ពិសេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ នឹងជួយបង្កើនប្រសិទ្ធភាពចំណាយ និងបង្កើនប្រាក់សន្សំ ដូចជាករណីថវិកាឱសថដែលពិភាក្សា ខាងក្រោម។

**រូបលេខ ១៩** **ចំណាយមូលធនមានកម្រិតកំណត់ នៅពេលដែលមូលធនដែលត្រូវបានផ្តល់ ហិរញ្ញប្បទានពីខាងក្រៅ ថយចុះ:** (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**៣០ ចំណាយលើវិស័យសង្គមមានការកើនឡើង គួរឲ្យកត់សម្គាល់លើចំណុចពីរ ៖ កំណើននៃការបែងចែកថវិកា និងកំណើនប្រសិទ្ធភាព។** ការបែងចែកថវិកាសម្រាប់វិស័យអប់រំបានកើនដល់ ២,១៧ ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងថវិកាឆ្នាំ ២០១៥ ដោយកើនពី ១,៩៧ ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងថវិកាឆ្នាំ ២០១៤ (រូបលេខ ២០)។ ដោយមានប្រាក់សន្សំចំនួន ៤០ ភាគរយពីថវិកាឱសថ ដោយសារតែការកែលម្អផ្នែកលទ្ធកម្ម ការបែងចែកថវិកាសម្រាប់វិស័យសុខាភិបាលគិតជាភាគរយនៃ ផលិតផលក្នុងស្រុកសរុបបានធ្លាក់ចុះមកត្រឹម ១,៣៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប នៅក្នុងថវិកាឆ្នាំ ២០១៥ ដោយថយចុះពី ១,៤៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០១៤។ ថវិកាសុខាភិបាលមានការកើនឡើងជាបរិមាណ ដោយមានចំនួន ១០២៣ ពាន់លានរៀលក្នុងឆ្នាំ ២០១៥ ដោយកើនពី ៩៧៨ ពាន់ លានរៀល ក្នុងឆ្នាំ ២០១៤។ ប្រាក់សន្សំពី ថវិកាឱសថ នឹងត្រូវប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់មូលនិធិសមធម៌សុខាភិបាល។

**រូបលេខ ២០** **ចំណាយដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលសម្រាប់ក្រសួងអប់រំ នៅតែបន្តកើនឡើង** (គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)




ប្រភព ៖ អាជ្ញាធរកម្ពុជា

**ប្រអប់លេខ៥** **និន្នាការភាពក្រីក្រវាស់វែងតាមសមាមាត្រកម្លាំងទិញអន្តរជាតិប្រមាណ ១,២៥ ដុល្លារអាមេរិក/ថ្ងៃ**

ភាពក្រីក្រនៅប្រទេសកម្ពុជាក្រោមរង្វាស់សមាមាត្រកម្លាំងទិញ ១,២៥ ដុល្លារអាមេរិក/ថ្ងៃ (ដែលផ្តល់លទ្ធភាពឲ្យមានការប្រៀបធៀបជាអន្តរជាតិ) មានចំនួន ៦,០ ភាគរយក្នុងឆ្នាំ២០១២ បើធៀបនឹងប្រទេសឡាវមានចំនួន ២៨,៨ ភាគរយ ប្រទេសហ្វីលីពីនមានចំនួន ១៥,៤ ភាគរយ ហើយប្រទេសឥណ្ឌូនេស៊ីមានចំនួន ១០,៩ ភាគរយ ដែលប្រទេសទាំងអស់នេះសុទ្ធតែមានផលិតផលក្នុងស្រុកសម្រាប់មនុស្សម្នាក់លើសពីប្រទេសកម្ពុជាយ៉ាងហោចណាស់ ១,៥ ដង។ ខណៈដែលភាពក្រីក្រវាស់វែង តាមសមាមាត្រកម្លាំងទិញអន្តរជាតិប្រមាណ ១,២៥ ដុល្លាអាមេរិក/ថ្ងៃ មានការធ្លាក់ចុះមធ្យមប្រចាំឆ្នាំដ៏ច្រើនចំនួន ៥,៨ ភាគរយនៅចន្លោះឆ្នាំ២០០៧ និង ២០០៩ អត្រានេះបានធ្លាក់ចុះមកត្រឹម ១,៣៦ ភាគរយនៅចន្លោះឆ្នាំ២០១០ និង ២០១២។ ល្បឿននៃការកាត់បន្ថយភាពក្រីក្រមានភាពយឺតយ៉ាវក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែការធ្លាក់ ចុះនៃវិស័យកសិកម្មដែលប្រជាពលរដ្ឋក្រីក្រពឹងផ្អែកជាចម្បង។

## ៦ ការកាត់បន្ថយភាពក្រីក្រ

**៣១ ភាពក្រីក្របានបន្តថយចុះ ប៉ុន្តែក្នុងល្បឿនយឺតជាងមុន។** គិតត្រឹមឆ្នាំ ២០១២ អត្រាចំនួនប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ (យោងតាមបន្ទាត់ភាពក្រីក្រជាតិ) មានចំនួន ១៧,៧ ភាគរយ ស្ទើរតែ ៣ ភាគរយទាបជាងឆ្នាំ ២០១១ ដែលនេះគឺជាល្បឿនកាត់បន្ថយភាពក្រីក្រមួយយ៉ាងខ្លាំង

បើទោះជាយឺតជាងក្នុងអំឡុងឆ្នាំ ២០០៧ និង ២០០៩ ក៏ដោយ (រូបលេខ ២១)[15]។

រូបលេខ ២១ អត្រាប្រជាជនក្រោមបន្ទាត់ក្រីក្របន្តថយចុះ ប៉ុន្តែមានល្បឿនយឺតជាងមុន




បន្ទាត់ក្រីក្រឆ្នាំ ២០០៤ ស្មើនឹង ០,៦៣ ដុល្លារអាមេរិកក្នុងមួយថ្ងៃសម្រាប់ម្នាក់ៗ

បន្ទាត់ក្រីក្រឆ្នាំ ២០១២ ស្មើនឹង ១,២០ ដុល្លារអាមេរិកក្នុងមួយថ្ងៃសម្រាប់ម្នាក់

ប្រភព ៖ អង្គការកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**៣២ ជារួម កំណើនសេដ្ឋកិច្ចបានជួយដល់ប្រជាជនក្រីក្រ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។** ៤០ ភាគរយដែលស្ថិតនៅខាងក្រោមបំផុតនៃរបាយ នៃការប្រើប្រាស់ បានកើនក្នុងកម្រិតអត្រាកំណើនមធ្យមប្រចាំឆ្នាំចំនួន ៧ ភាគរយក្នុងអំឡុងពេល ចន្លោះពីឆ្នាំ ២០០៧ និង ២០១២ ដែលកើនឡើងស្ទើរតែទ្វេដងនៃអត្រាកំណើនចំនួន ៣,៦ ភាគរយសម្រាប់ប្រជាជនសរុប។ មូលហេតុចម្បងនៃកំណើននេះ បណ្តាលមកពីកំណើនក្នុងវិស័យកសិកម្ម។ វិសមភាពបានថយចុះយ៉ាងច្រើនដោយផលគុណ Gini បានថយពី ៣២ ក្នុងឆ្នាំ ២០០៨ មកនៅត្រឹម ២៨ ក្នុងឆ្នាំ២០១២។ យ៉ាងណាក៏ដោយ កំណើននៃសមភាពបានថយ ចុះក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។ ភាពក្រីក្រក្នុងប្រទេសកម្ពុជា ដែលគិតត្រឹមចំនួនក្រោម ១,២៥ ដុល្លាក្នុងម្នាក់ក្នុងមួយថ្ងៃ (ដែលអនុញ្ញាតឲ្យមានការប្រៀបធៀបជាអន្តរជាតិ) មានចំនួន ៦,០ ភាគរយក្នុងឆ្នាំ ២០១២ (សម្រាប់ព័ត៌មានលម្អិត សូមមើលប្រអប់លេខ៥)។

**៣៣ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត ភាពក្រីក្រនៅជនបទ ទំនងជាថយចុះក្នុងល្បឿនមួយយឺតជាងពីមុន។** នៅទីជនបទ ការកាត់បន្ថយភាពក្រីក្របន្ថែមទៀតនឹងជាការលំបាកជាងមុន ដោយសារតែការបង្កើនទិន្នផលដំណាំ មានល្បឿនយឺតជាងមុន និងការធ្លាក់ចុះនៃតម្លៃផលិតផលកសិកម្មនៅលើទីផ្សារអន្តរជាតិ។

**៣៤ ដូចក្នុង អំឡុងប៉ុន្មានឆ្នាំកន្លងទៅនេះដែរ វិសមភាព ទំនងនឹងថយចុះក្នុងល្បឿនមួយយឺតជាងមុននៅកម្ពុជា ក្នុងពេលអនាគតខាងមុខ។** ប្រភពកំណើនសេដ្ឋកិច្ច ដែលត្រូវបានព្យាករសម្រាប់រយៈពេលខ្លី និងរយៈពេលមធ្យម ដែលមាន វិស័យសំណង់ វិស័យកាត់ដេរ និង វិស័យទេសចរណ៍ ទំនងជាមិនផ្តល់ផលវិជ្ជមានដល់ប្រជាជនក្រីក្រច្រើនជាងគេ។

**៣៥ ចំពោះប្រទេសកម្ពុជា ឥទ្ធិពលនៃការធ្លាក់ចុះតម្លៃប្រេងថ្មីៗនេះ ដែលរំពឹងថានឹងមានចំពោះការកាត់បន្ថយភាពក្រីក្រ ហាក់ដូចជាមានកម្រិតទាបណាស់។** ការធ្លាក់ចុះតម្លៃនេះនឹងផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់អ្នកប្រើប្រាស់ ដោយសារតែមិនមានការគ្រប់គ្រងតម្លៃ។ ការធ្លាក់ចុះ ២០ ភាគរយនៃតម្លៃក្នុងស្រុកយ៉ាងច្រើនបំផុត តំណាងឲ្យការចំណេញតែ ១,៥ ភាគរយនៃការប្រើប្រាស់សម្រាប់គ្រួសារមធ្យមក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ ប៉ុន្តែ អត្ថប្រយោជន៍នេះមានកាន់តែតិចខ្លាំងទៅទៀតសម្រាប់គ្រួសារដែលក្រីក្រ ដោយសារតែប្រេងឥន្ធនៈ (និងទំនិញភាគច្រើនទៀតដែលមានទំនាក់ទំនងជាមួយនឹងប្រេង) មានចំណែកដ៏តូចមួយនៃថវិកាគ្រួសាររបស់ពួកគេ។

[15] បន្ទាត់ភាពក្រីក្រជាតិសម្រាប់ឆ្នាំ ២០១២ គឺ ៤.៦៥៤,៧ រៀល (តម្លៃជាក់ស្តែង)។

## សារគន្លឹះ និងអនុសាសន៍

**៣៦ បញ្ហាប្រឈមសំខាន់ នាពេលខាងមុខគឺការជំរុញវិស័យកសិកម្ម វិស័យកាត់ដេរ និងវិស័យទេសចរណ៍ ឲ្យក្លាយជាវិស័យជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រឲ្យបានច្រើនថែមទៀត។**

**៣៧ ការស្តារឡើងវិញនូវកំណើនវិស័យកាត់ដេរ ជាពិសេសកំណើនវិស័យកម្មន្តសាល នឹងក្លាយជាមធ្យោបាយដ៏សំខាន់ក្នុងការរក្សាឲ្យបាននូវកំណើនខ្ពស់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** គោលដៅនេះអាចសម្រេចបាន ក្នុងរយៈពេលខ្លីរហូតដល់រយៈពេលមធ្យម។ ទីមួយ ដើម្បីបន្តពង្រឹង និងធ្វើពិពិធកម្មទំនិញនាំចេញ សំខាន់ត្រូវរក្សាឲ្យបាននូវស្ថិរភាពទីផ្សារការងារ ដើម្បីទទួលបានប្រយោជន៍ពីការប្តូរទីតាំងនៃឧស្សាហកម្មពីប្រទេសចិន។ ទីពីរ ចាំបាច់ត្រូវ កែលម្អបរិយាកាសធុរកិច្ចតាមរយៈការផ្តល់ភាពងាយស្រួល និងធ្វើស្វ័យប្រវត្តិកម្មដំណើរការចុះបញ្ជីពាណិជ្ជកម្ម ការសម្រប សម្រួលពាណិជ្ជកម្ម និងការពង្រឹងច្បាប់វិនិយោគ (សូមមើលការវាយតម្លៃបរិយាកាសវិនិយោគរបស់ធនាគារពិភពលោក ឆ្នាំ២០១៤)។ ចុងក្រោយ ផ្តើមចេញពីទស្សនវិស័យរយៈពេលមធ្យម ការដោះស្រាយបញ្ហាចំណាយខ្ពស់លើអគ្គិសនី ដោយបង្កើនកិច្ចសហការក្នុងការផ្គត់ផ្គង់អគ្គិសនីបន្ថែមដែលបានពីរោងចក្រវារីអគ្គិសនី និងរោងចក្រដើរដោយថាមពលធ្យូងថ្ម ធ្វើឲ្យមានការកែលម្អប្រកបដោយប្រសិទ្ធភាព និងពង្រឹងតម្លាភាពក្នុងការចែកចាយថាមពល ហើយការផ្គត់ផ្គង់ថាមពលក៏នឹងមានលក្ខណៈវិជ្ជមានផងដែរ។

**៣៨ ដោយសារផ្ទៃដីដាំដុះ មានកម្រិតកំណើនផលិតកម្មស្រូវ ដែលកន្លងមកអាស្រ័យលើការពង្រីកផ្ទៃដីដាំដុះ នឹងត្រូវពឹងផ្អែកកាន់តែខ្លាំងលើការបង្កើនទិន្នផល និងគុណភាពស្រូវ។** ជោគជ័យក្នុងការស្តារកំណើនវិស័យកសិកម្ម ដែលទ្រទ្រង់ដល់ប្រជាជនក្រីក្រ នឹងអាចសម្រេចបានភាគច្រើនក្នុងក្របខណ្ឌរយៈពេលមធ្យម ដោយសារតែការធ្លាក់ចុះតម្លៃផលិតផលកសិកម្ម ខណៈដែលការឆ្លើយតបនឹងការផ្គត់ផ្គង់ អាចត្រូវចំណាយពេល។ ទីមួយ ការកាត់បន្ថយចំណាយលើផ្នែកភស្តុភារ (ជាមួយនឹង ការបង្កើតក្រុមការងារផ្នែកភស្តុភារសម្រាប់កិច្ចសហប្រតិបត្តិការអន្តរក្រសួង) និងចំណាយលើការធ្វើធុរកិច្ច (ដើម្បីលើកឡើងនូវមូលហេតុសំខាន់ៗ ដែលធ្វើឲ្យអង្ករកម្ពុជាបាត់បង់ការប្រកួតប្រជែង ដែលមាននៅពេលដែលប្រមូលផល) អាចធ្វើឡើងក្នុងរយៈពេលដ៏ខ្លី តាមរយៈការខិតខំប្រឹងប្រែងបំផុត។ ទីពីរ ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុបន្ថែមទៀតសម្រាប់អ្នកផលិតស្រូវ និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីបង្កើនបរិមាណអង្ករដែលកិនបាន និងកាត់បន្ថយចំណាយលើថ្លៃកិនស្រូវ ទាមទារឲ្យមានការឆ្លើយតបក្នុងរយៈពេលខ្លី និងមធ្យម។ ចុងក្រោយ ការបង្កើនការវិនិយោគសាធារណៈ លើសេវាផ្តល់ប្រឹក្សាលើផ្នែកកសិកម្ម ការអភិវឌ្ឍពូជ និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីពង្រឹងលទ្ធភាពទប់ទល់ទៅនឹងការប្រែប្រួលយ៉ាងលឿន ការបើកទីផ្សារថ្មី នឹងទទួលផល និងត្រូវចំណាយពេល និងធនធានយ៉ាងច្រើន។ សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងអនុសាសន៍នានា សូមអានការសិក្សា របស់ធនាគារពិភពលោកស្តីពី

"អន្តរកាលនៃវិស័យកសិកម្ម" ដែលនឹងបោះពុម្ពផ្សាយក្នុងពេលឆាប់ ៗនេះ។

**៣៩ ដើម្បីបង្កើន កំណើនវិស័យទេសចរណ៍ ចាំបាច់ត្រូវមាន កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនពេលវេលា និងថវិកាដែលភ្ញៀវទេសចរចំណាយក្នុងប្រទេសកម្ពុជា។** គោលដៅនេះអាចសម្រេចទៅបានតាមរយៈ ការកែលម្អការដឹកជញ្ជូនតាមផ្លូវគោក (ការផ្សារភ្ជាប់ព្រំដែន ខេត្តសៀមរាប តំបន់ឆ្នេរសំខាន់ៗ និងទីក្រុងភ្នំពេញ) បូករួមនឹងការវិនិយោគកាន់តែច្រើន និងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងមូលដ្ឋាន វិស័យឯកជន និងសហគមន៍មូលដ្ឋាន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងជួយជំរុញដល់ការបង្កើនតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ក្រៅពីតំបន់ប្រាង្គប្រាសាទបុរាណអង្គរ។ ការបង្កើនការទាក់ទាញភ្ញៀវទេសចរ និងការរៀបចំដំណើរកំសាន្តជាតំបន់ ក៏នឹងជួយឲ្យកម្ពុជាចាប់យកចំណែកធំជាងមុននៃទីផ្សារទេសចរណ៍ពិភព លោកដែលកំពុងតែមានការលូតលាស់ផងដែរ។

**៤០ ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុដែលកំពុងតែមានការរីកលូតលាស់យ៉ាងលឿន នឹងជំរុញឲ្យមានកំណើនសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាព។** ការពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារនៅក្នុងវិស័យហិរញ្ញវត្ថុ ដែលទើបតែចាប់ផ្តើម ប៉ុន្តែមានការរីកលូតលាស់យ៉ាងលឿននេះ នឹងជួយទប់ស្កាត់ការប្រែប្រួលក្នុងវិស័យសំណង់ និងអចលនទ្រព្យ និង ពង្រឹងការទប់ទល់របស់ប្រទេសទៅនឹងការប្រែប្រួលខ្លាំងក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ តាមរយៈកិច្ចសហប្រតិបត្តិការអន្តរក្រសួងដ៏រឹងមាំ និងការខិតខំប្រឹងប្រែង ជោគជ័យក្នុងវិស័យនេះអាចសម្រេចបានក្នុងរយៈពេលខ្លី ដោយសារតែសមត្ថភាពបច្ចេកទេស និងសមត្ថភាពគ្រប់គ្រងរបស់អាជ្ញាធររូបិយវត្ថុ និងសេដ្ឋកិច្ចត្រូវបានពង្រឹងឡើងវិញបន្ទាប់ពីទទួលបានជោគជ័យជាបន្តបន្ទាប់អស់រយៈពេលជាច្រើនឆ្នាំកន្លងមក[16]។

**៤១ ប្រទេសកម្ពុជា ក៏នឹងទទួលបានប្រយោជន៍យ៉ាងច្រើនពីការវិនិយោគ និងប្រសិទ្ធិភាពចំណាយក្នុងវិស័យសុខាភិបាល អប់រំ និងកិច្ចគាំពារសង្គម ដែលនឹងជួយបង្កើនផលិតភាព និងសុខុមាលភាពយ៉ាងច្រើន ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង។** ទោះបីជា ប្រទេសកម្ពុជាមានការកែលម្អសំខាន់ៗលើកម្រិតគ្រប់ដណ្តប់ក្នុងការផ្តល់សេវា ក៏ដោយ ក៏កម្រិតការសិក្សាទាប និងកង្វះអាហារូបត្ថម្ភ នៅតែមានច្រើនក្នុងចំណោមប្រជាជនក្រីក្រ។ ទោះបីជាប្រទេសកម្ពុជា មានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏គ្រួសារភាគច្រើនដែលរួចផុតពីភាពក្រីក្រ ចេញផុតពីបន្ទាត់នៃភាពក្រីក្រតែបន្តិចប៉ុណ្ណោះ និងនៅតែក្បែរ "ក្រ" ដែលធ្វើឲ្យពួកគេប្រឈមនឹងភាពងាយរងគ្រោះយ៉ាងខ្លាំង។ គំនិតផ្តួចផ្តើមនាពេលថ្មីៗនេះក្នុងការប្រើប្រាស់ និងផ្តល់មូលនិធិសមធម៌សុខាភិបាល និងមូលនិធិសោធននិវត្តន៍គឺជាវិធានការដ៏ត្រឹមត្រូវ។ យ៉ាងណាក៏ដោយ ការយល់ដឹងបានល្អអំពីយន្តការដោះស្រាយ ដែលមានសម្រាប់គ្រួសារដែលងាយរងគ្រោះ និងប្រសិទ្ធភាពនៃយន្តការនេះ នឹងជួយកាត់បន្ថយហានិភ័យរបស់ពួកគេក្នុងការធ្លាក់ចូលទៅក្នុងភាពក្រីក្រជាថ្មីម្តងទៀត។

---

[16]កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារ អាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមតែ ធនាគារជាតិកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មការមូលប័ត្រកម្ពុជា។

**៤២ ការបន្តពង្រីកមូលដ្ឋានប្រមូលពន្ធ និងការពង្រឹងការគ្រប់គ្រងពន្ធ នឹងជួយបង្កើនការប្រមូលពន្ធដើម្បីផ្តល់ហិរញ្ញប្បទានដល់ការចំណាយលើការអភិវឌ្ឍចាំបាច់ ខណៈដែលកំណើនប្រាក់បៀវត្សរ៍យ៉ាងលឿនទាមទារឲ្យមានការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់។** ការបង្កើនការវិនិយោគសាធារណៈដើម្បីពង្រឹងវិស័យកសិកម្ម និងទេសចរណ៍ព្រមទាំងជួយដល់ កំណែទម្រង់រចនាសម្ព័ន្ធរួមដែលបានលើកឡើងខាងដើម ទាមទារឲ្យមានការពង្រឹងប្រសិទ្ធភាពលើចំណាយសាធារណៈ និងធនធានហិរញ្ញវត្ថុបន្ថែម។ ដូច្នេះ សំខាន់ត្រូវបន្តពង្រឹងការប្រមូលពន្ធក្នុងប្រទេស តាមរយៈការបន្តពង្រីកមូលដ្ឋានប្រមូលពន្ធ និងពង្រឹងការគ្រប់គ្រងពន្ធ។ ការពង្រឹងការប្រមូលពន្ធនៅតែធ្វើឡើងជាបន្តបន្ទាប់ ហើយសំខាន់ត្រូវរក្សាឲ្យបាននូវកិច្ចខិតខំប្រឹងប្រែងដើម្បីបន្តពង្រឹងការគ្រប់គ្រង និងអភិបាលកិច្ចល្អ។

ទោះជាការដំឡើងប្រាក់បៀវត្សរ៍ ជួយលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការ ដែលបច្ចុប្បន្នមានប្រាក់បៀវត្សរ៍ទាបក្តី ក៏ប្រាក់បៀវត្សរ៍តែមួយមុខមិនទាន់គ្រប់គ្រាន់សម្រាប់ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈឡើយ។ សំខាន់ត្រូវផ្សារភ្ជាប់ការបង្កើនប្រាក់បៀវត្សរ៍ជាមួយ នឹងការកែលម្អការគ្រប់គ្រងធនធានមនុស្ស និងលទ្ធផលការងារ។ លើសពីនេះ ការដំឡើងប្រាក់បៀវត្សរ៍ទាមទារ ឲ្យមានការត្រួតពិនិត្យ យ៉ាងយកចិត្តទុកដាក់ដើម្បីធានាថា ការដំឡើងប្រាក់បៀវត្សរ៍នេះរដ្ឋាភិបាលនៅតែមានលទ្ធភាពអាចផ្តល់ឲ្យបាន។

# ប្រធានបទពិសេស ៖ បញ្ហាដុល្លារូបនីយកម្ម ៖ គុណសម្បត្តិ គុណវិបត្តិ និងកិច្ចការបន្ទាប់

## ១ ការជំរុញទឹកចិត្ត

គោលបំណងនៃប្រធានបទពិសេសស្តីពីបញ្ហាដុល្លារូបនីយកម្ម ៖ គុណសម្បត្តិ គុណវិបត្តិ និងកិច្ចការបន្ទាប់" គឺសំដៅផ្តល់ទស្សនៈ និងបទពិសោធន៍មួយចំនួន ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តឡើង ដើម្បីពង្រឹងការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក គឺប្រាក់រៀលកម្ពុជានេះឯង។

## ២ សាវតារ

កាលពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសកម្ពុជាត្រូវធ្វើហិរញ្ញប្បទានធនាគារក្នុងប្រទេសដើម្បីដោះស្រាយឱនភាពសារពើពន្ធ ដែលធ្វើឲ្យមានអត្រាអតិផរណាខ្ពស់[17]។ ការធ្វើបែបនេះហាក់ជំរុញឲ្យមានការប្រើប្រាស់រូបិយប័ណ្ណផ្សេងៗទៀត ដូចជា ប្រាក់ដុល្លាអាមេរិក (និងប្រាក់បាតថៃជាដើម) ដើម្បីជំនួសឲ្យរូបិយប័ណ្ណក្នុងស្រុក។

រូបលេខ S1-1 ភាគរយនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសក្នុងរូបិយវត្ថុទូទៅ កើនឡើងយ៉ាងលឿនដោយភាពការពិតដែលថាប្រាក់ដុល្លាត្រូវបានអនុញ្ញាតឲ្យធ្វើចរាចរណ៍ដោយសេរី (គិតជាភាគរយ)




ការប្រើប្រាស់ប្រាក់ដុល្លាអាមេរិកជំនួសឲ្យប្រាក់រៀលបានចាប់ផ្តើមក្នុងឆ្នាំ ១៩៩២ នៅពេលដែលមានលំហូរប្រាក់ដុល្លាជាច្រើន ដែលផ្តល់ជាមូលនិធិដល់ការបោះឆ្នោតជាសកលលើកទីមួយ ត្រូវបានអនុញ្ញាតដើម្បីប្រើប្រាស់មុខងារប្រាក់ទាំងអស់ ជាមួយប្រាក់រៀល[18]។ តាមរយៈការបន្តលំហូរប្រាក់ដុល្លាដោយសេរី ដោយសារតែប្រទេសបើកចំហរដើម្បីទទួលជំនួយ និងវិនិយោគិនបរទេស ភាគរយប្រាក់បញ្ញើរូបិយប័ណ្ណបរទេស (ភាគច្រើនជាប្រាក់ដុល្លាអាមេរិក) ក្នុងរូបិយវត្ថុទូទៅ មានការកើនឡើងយ៉ាងលឿនពី ៣៦ភាគរយ (៣០,៧ លានដុល្លាអាមេរិក) នៅបំណាច់ឆ្នាំ ១៩៩៣ រហូតដល់ ៦៣ ភាគរយ (១៩៥,៨ លានដុល្លាអាមេរិក) នៅបំណាច់ឆ្នាំ ១៩៩៦ ដែលធ្វើឲ្យប្រាក់រៀលដែលជារូបិយប័ណ្ណសំខាន់ក្លាយជារូបិយប័ណ្ណបន្ទាប់បន្សំក្នុងរយៈពេលតែ ៣ ឆ្នាំប៉ុណ្ណោះ[19]។

[17]ការបោះពុម្ពក្រដាសប្រាក់។

[18]Tal Nay Im និង Michel Debadie ឆ្នាំ២០០៧ ដុល្លារូបនីយកម្មក្នុងប្រទេសកម្ពុជា។

[19]ដោយមិនមានវិធានការគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិដើម្បីស្រូបយកលំហូរប្រាក់ដុល្លាអាមេរិក។

ការប្រើប្រាស់ប្រាក់ដុល្លាអាមេរិកទូទៅរបស់ប្រជាជនក្នុងប្រទេស គឺជាបាតុភូតមួយដែលហៅថាដុល្លារូបនីយកម្ម។ តាំងពីឆ្នាំ២០០៧ ភាគរយរូបិយប័ណ្ណបរទេសក្នុងរូបិយវត្ថុទូទៅបិតក្នុងរង្វង់ប្រហែល ៨០ ភាគរយ ហើយសេដ្ឋកិច្ចកម្ពុជាក្លាយជាសេដ្ឋកិច្ចដុល្លារូបនីយកម្ម (រូបលេខ S1-1)។ ភាគរយប្រាក់បញ្ញើជាប្រាក់ដុល្លាអាមេរិកនៅក្នុងប្រាក់បញ្ញើសរុប មានការឡើងចុះនៅចន្លោះ ៩២ ភាគរយ និង ៩៨ ភាគរយក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយ។ ត្រឹមខែធ្នូ ឆ្នាំ២០១៤ ប្រាក់បញ្ញើជាប្រាក់ដុល្លាអាមេរិកបានកើនស្ទើរតែរហូតដល់ ៨,៦ ពាន់លានដុល្លាអាមេរិក ដែលច្រើនជាងពាក់កណ្តាលនៃទំហំសេដ្ឋកិច្ចកម្ពុជាទាំងមូល។ យ៉ាងណាក៏ដោយ តម្លៃប្រាក់ដុល្លាអាមេរិកសរុបដែលចរាចរណ៍នៅតែមិនទាន់ដឹងនៅឡើយទេ។ កត្តាក្នុងប្រទេស និងក្រៅប្រទេសជាច្រើនកំណត់ពីចំណុចខ្លាំងនៃគុណវិបត្តិ និងគុណសម្បត្តិនៃដុល្លារូបនីយកម្ម ដូចមានពិភាក្សាខាងក្រោម។

## ៣ គុណសម្បត្តិ

សេដ្ឋកិច្ចមានការរីកចម្រើនខ្លាំងក្នុងអំឡុងពេលពីរទសវត្សរ៍កន្លងទៅនេះ។ ស្ថានភាពនេះធ្វើឲ្យមនុស្សមួយចំនួនជឿថា ដុល្លារូបនីយកម្មក្នុងប្រទេសកម្ពុជាកំពុងតែផ្តល់ផ្លែផ្កា គាំទ្រស្ថិរភាព និងកំណើនម៉ាក្រូសេដ្ឋកិច្ច ទោះបីជានៅត្រូវសិក្សាទៅលើសម្មតិកម្មនេះក្តី ។ គុណសម្បត្តិសំខាន់ៗមួយចំនួននៃដុល្លារូបនីយកម្មមាន៖

***ទីមួយ*** ដុល្លារូបនីយកម្មបង្កការរាំងស្ទះដល់រដ្ឋាភិបាលដែលខ្វះប្រាក់មិនឲ្យផ្តល់ហិរញ្ញប្បទានក្នុងប្រទេស ដែលជាមូលហេតុចម្បងធ្វើឲ្យមានអតិផរណាចេះតែកើនឡើងជាលំដាប់នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ ១៩៩០ ក្នុងប្រទេសកម្ពុជា។ ដុល្លារូបនីយកម្ម បូករួមនឹងការកំណត់អត្រាប្តូរប្រាក់ ការរក្សាតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លា ក៏អាចជួយទប់កម្រិតថ្លៃផងដែរ។ ក្នុងបរិបទដុល្លារូបនីយកម្ម និងការរក្សាតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លា ប្រជាជនគិតគូរតម្លៃដោយប្រៀបធៀបនឹងប្រាក់ដុល្លា ហើយតម្លៃទាំងអស់ដែលគិតជាប្រាក់រៀល ត្រូវបានធ្វើសន្ទស្សន៍ដោយប្រើប្រាស់អត្រាប្តូរប្រាក់។ ឧទាហរណ៍ តម្លៃផលិតផលក្នុងស្រុកហាក់មានការកើនឡើង ដូចជាតម្លៃផលិតផលនាំចូល នៅពេលដែលប្រាក់រៀលមានការធ្លាក់ចុះ (Im និង Dabadie ឆ្នាំ ២០០៧)[20]។ ហេតុដូច្នេះ អត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់ដុល្លាដែលមានស្ថិរភាព ក៏ធ្វើឲ្យមានស្ថិរភាពតម្លៃផងដែរ។

***ទីពីរ*** **ក្នុងអំឡុងមានការប្រែប្រួលពីខាងក្រៅនៅពេលដែលមានការខ្វះខាតប្រាក់ដុល្លាអាមេរិក តម្លៃប្រាក់ដុល្លាសរុបដែលចរាចរណ៍ អាចផ្តល់ហិរញ្ញប្បទានដល់ឱនភាពគណនីចរន្ត ដោយនេះគឺជាតួនាទីរបស់ទុន**

---

[20]Tal Nay Im និង Michel Dabadie ឆ្នាំ២០០៧ ដុល្លារូបនីយកម្មក្នុងប្រទេសកម្ពុជា។ តម្លៃទំនិញភាគច្រើន (និងសេវាកម្ម) ក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ឲ្យឡើង ឬចុះ ដោយអ្នកផ្គត់ផ្គង់ ដោយធៀបនឹងអត្រាប្តូរប្រាក់រៀល និងប្រាក់ដុល្លាអាមេរិក (និងអត្រាប្តូរប្រាក់រៀល និងប្រាក់បាតថៃផងដែរ)។ ឧទាហរណ៍ ក្រូចដាំក្នុងស្រុកចំនួន 1 ឡូ មានតម្លៃ 10.000 រៀល នៅពេលដែលប្រាក់ដុល្លា 1 ដុល្លា ប្តូរបាន 4.000 រៀល។ នេះមានន័យថា ក្រូច 1 ឡូ មានតម្លៃ 2.5 ដុល្លាអាមេរិក។ ប្រសិនបើប្រាក់រៀលកើនដល់ 4.100 រៀលក្នុង 1 ដុល្លា នោះក្រូច 1 ឡូនឹងមានតម្លៃស្មើ 10.250 រៀល (ឬអាចស្មើនឹង 10.300 រៀល ដោយសារតែប្រទេសកម្ពុជាលែងចរាចរណ៍ក្រដាសប្រាក់ 50 រៀលទៀតហើយ) ដូច្នេះក្រូច 1 ឡូ នឹងមានតម្លៃ 2.51 ដុល្លាអាមេរិក ដែលជាអត្រាប្តូរប្រាក់ពេញលេញ "ដែលបញ្ជូនទៅ" តម្លៃ។

ទុនបម្រុងបរទេស។ ឧទាហរណ៍ ស្ថានភាពនេះបានធ្វើឲ្យប្រទេសកម្ពុជារួចផុតពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីបូព៌ា ឆ្នាំ ១៩៩៧[21]។

**រូបលេខ S 1.2** **មិនដូចជាប្រទេសដៃគូក្នុងតំបន់ ការឡើងតម្លៃអត្រាប្តូរប្រាក់ជាក់ស្តែងរបស់ប្រទេសកម្ពុជារួមចំណែកធ្វើឲ្យឱនភាពគណនេយ្យចរន្តនៅថេរ** (ភាគរយនៃផលិតផលក្នុងស្រុកសរុប)




CAB=តុល្យភាពគណនីចរន្ត
ប្រភព ៖ ស្ថាប័នអភិវឌ្ឍន៍ពិភពលោក

*ទីបី* អ្នកគាំទ្រដុល្លារូបនីយកម្មផ្សេងទៀតជឿថា ដុល្លារូបនីយកម្ម មានអត្ថប្រយោជន៍បំផុតសម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចបើកចំហរ ហើយតូចដូចកម្ពុជា ដែលធ្វើអាជីវកម្មជាមួយដៃគូផ្សេងទៀតដែលប្រើប្រាស់ប្រាក់ដុល្លាដោយមានវដ្តនៃសេដ្ឋកិច្ចអាមេរិកនោះ។ ពួកគេយល់ថា គោលនយោបាយរូបិយវត្ថុរបស់ប្រទេសកម្ពុជាផ្តោតលើការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាជាងស្ថិរភាពរូបនីយកម្មដែលទប់ទល់នឹងវដ្តសេដ្ឋកិច្ច[22]។

*ទីបួន* តាមរយៈការលុបបំបាត់ហានិភ័យអត្រាប្តូរប្រាក់ ដុល្លារូបនីយកម្មទាក់ទាញលំហូរមូលធន និងសម្រួលឲ្យមានការបើកចំហរទីផ្សារកម្រិតខ្ពស់ ដោយជួយជំរុញពាណិជ្ជកម្មសេរីរបស់ប្រទេសកម្ពុជា និងរបបវិនិយោគ[23]។

## ៤ គុណវិបត្ត

អាជ្ញាធរកម្ពុជាបានទទួលស្គាល់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់ខ្លួនថា វិស័យសេដ្ឋកិច្ចកម្ពុជានៅតែប្រើប្រាស់ប្រាក់ដុល្លាច្រើនដដែល ដែលដាក់កំហិតដល់គោលនយោបាយរូបិយវត្ថុ។ ហេតុដូច្នេះ យុទ្ធសាស្ត្រចតុកោណសម្រេចបន្តរបបអត្រាប្តូរប្រាក់សេរីដែលមានការគ្រប់គ្រង ដើម្បីរក្សាស្ថិរភាពប្រាក់រៀល ទន្ទឹមនឹងមានការពង្រឹងការជឿទុកចិត្តរបស់សាធារណជន និងវិនិយោគិនលើរូបិយប័ណ្ណក្នុងស្រុកដើម្បីជំរុញឲ្យមានការប្រើប្រាស់កាន់តែច្រើន និងកាត់បន្ថយការប្រើប្រាស់ដុល្លាច្រើន[24]។ ផែនការ

---

[21]ក្នុងអំឡុងពេលមានវិបត្តិនេះ ប្រទេសកម្ពុជាមិនបានជួបការទម្លាក់តម្លៃទំនិញសំខាន់ៗឡើយ ខណៈដែលប្រាក់បាតថៃបានបាត់បង់តម្លៃរបស់ខ្លួន ៥៤ ភាគរយធៀបនឹងប្រាក់ដុល្លានៅចន្លោះខែមិថុនា ឆ្នាំ១៩៩៧ និងខែមករា ឆ្នាំ១៩៩៨។ អត្រាកំណើនពិតរបស់ប្រទេសកម្ពុជាមានចំនួន ៤ ភាគរយនៅឆ្នាំ ១៩៩៧ និង ៥ ភាគរយនៅឆ្នាំ ១៩៩៨ (កំណើនពីរខ្ទង់សម្រាប់រយៈពេលពីរឆ្នាំបន្តបន្ទាប់) ខណៈដែលកំណើនពិតរបស់ប្រទេសថៃមានចំនួន ២,៨ ភាគរយក្នុងឆ្នាំ ១៩៩៧ និង ៧,៦ ភាគរយក្នុងឆ្នាំ ១៩៩៩។

[22] ប្រអប់ 7.1 ៖ ដុល្លារូបនីយកម្មពេញលេញ បដិដុល្លារូបនីយកម្ម ឬតាមស្ថានភាពបច្ចុប្បន្ន? ប្រទេសកម្ពុជាកំពុងរក្សាកំណើនយ៉ាងលឿនក្នុងបរិយាកាសប្រកួតប្រជែង អនុស្សរណៈសេដ្ឋកិច្ចប្រទេស ឆ្នាំ២០០៩ ធនាគារពិភពលោក។

[23] Hellerstein និង Ryan ឆ្នាំ ២០១១ របាយការណ៍បុគ្គលិកធនាគារកណ្តាលរដ្ឋញូវយ៉ក សាច់ប្រាក់ដុល្លានៅបរទេស ខែកុម្ភៈ ឆ្នាំ ២០១១ មួយ ភាគរយខ្ពស់ជាងអនុបាតបើកចំហរ (ត្រូវបានកំណត់ជាការនាំចូល និងការនាំចេញសរុបរបស់ប្រទេសធៀបនឹង ផសស) គឺមាន ១,៣២ ភាគរយខ្ពស់ជាងលំហូរប្រាក់ដុល្លា (ទំព័រ ២២)។

[24]សូមអានទំព័រ ៧ និង ១៨ ៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ (ឯកសារជាភាសាអង់គ្លេសក្រៅផ្លូវការ) រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៣។

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤ និង ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជាក៏បានអំពាវនាវឲ្យមានការគ្រប់គ្រងកាន់តែប្រសើរលើវិស័យសេដ្ឋកិច្ច ជាពិសេសគោលនយោបាយរូបិយវត្ថុ និងចាត់ទុកថា បដិដុល្លារូបនីយកម្មគឺជាជំហានទីមួយក្នុងការសម្រេចបានគោលដៅនេះ[25]។ ជាងនេះទៅទៀត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិគាំទ្រឲ្យមានការប្រើប្រាស់ការវិនិយោគជាប្រាក់រៀល ដូចជា ប័ណ្ណរតនាគារ និង ប័ណ្ណបំណុលរដ្ឋាភិបាល[26]។ គុណវិបត្តិសំខាន់ៗនៃដុល្លារូបនីយកម្មមានដូចខាងក្រោម។

រូបលេខ S1.3 ការធ្លាក់ចុះរូបិយប័ណ្ណក្នុងតំបន់ ធៀបនឹងអត្រាប្តូរប្រាក់ដុល្លាអាមេរិក (សន្ទស្សន៍៖ ខែមេសា = ២០១០= ១០០)



ប្រភព៖ xe.com

***ទីមួយ*** **យ៉ាងហោចណាស់ ដុល្លារូបនីយកម្មធ្វើឲ្យផលិតផលនាំចេញនិងផលិតកម្មទំនិញពាណិជ្ជកម្ម របស់ប្រទេសកម្ពុជា មិនសូវមានការប្រកួតប្រជែងបើធៀបជាមួយប្រទេសដៃគូ ដែលមានប្រាក់ចំណូលទាប ដោយសារតែការឡើងថ្លៃអត្រាប្តូរប្រាក់ជាក់ស្តែង ធៀបនឹងរូបិយប័ណ្ណផ្សេងទៀត។** នៅពេលដែលមានដុល្លារូបនីយកម្ម អត្រាប្តូរប្រាក់នៅថេរហើយពាណិជ្ជកម្មសេរី និងរបបវិនិយោគ ឱនភាពគណនីចរន្តទូទៅ នៅតែបន្តកើតមាន (រូបលេខ S1.2) ធ្វើឲ្យងាយរងការប៉ះពាល់ពីការប្រែប្រួលខាងក្រៅ[27]។ លើសពីនេះទៀត រូបិយប័ណ្ណរបស់ប្រទេស ក្នុងតំបន់ភាគច្រើនមានការធ្លាក់ចុះតម្លៃធៀបនឹងប្រាក់ដុល្លាអាមេរិក ក្នុងអំឡុងប្រាំឆ្នាំចុងក្រោយ (រូបលេខS1.3) ហើយកង្វះគោលនយោបាយរូបិយវត្ថុដែលមានភាពបត់បែន នៅពេលដែលមានកំណើនថ្លៃអត្រាប្តូរប្រាក់ កំពុងធ្វើឲ្យមានការព្រួយបារម្ភ[28]។ ដូចបានពិភាក្សានៅផ្នែកផលិតកម្មខាងលើ ចំណែកនាំចេញសម្លៀកបំពាក់របស់ប្រទេសកម្ពុជាទៅកាន់សហភាពអឺរ៉ុប គិតជាតម្លៃ បានកើនឡើងរហូតដល់ ៤០ ភាគរយនៃការនាំចេញសម្លៀកបំពាក់សរុប ខណៈពេលដែលចំណែកនាំសម្លៀកបំពាក់ទៅកាន់អាមេរិកមានត្រឹមតែ ៣៤ ភាគរយប៉ុណ្ណោះក្នុងឆ្នាំ ២០១៤។ ការឡើងថ្លៃប្រាក់ដុល្លាអាមេរិកធៀបនឹងប្រាក់អឺរ៉ូបច្ចុប្បន្ន បានកាត់បន្ថយការប្រកួតប្រជែងការនាំចេញរបស់ប្រទេសកម្ពុជាធៀបនឹងទីផ្សារនាំចេញដ៏ធំបំផុតរបស់ប្រទេស គឺសហភាពអឺរ៉ុប[29]។

---

[25]សូមអានកថាខណ្ឌ ៦ នៅទំព័រ ៨ ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៤-២០១៨ (ឯកសារច្បាប់ដើមជាភាសាខ្មែរ)។

[26]សូមអានកថាខណ្ឌ ៣.៤៥ នៅទំព័រ ១៥៩ ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៤-២០១៨ (ឯកសារច្បាប់ដើមជាភាសាខ្មែរ)។

[27]ជាទូទៅ ឱនភាពគណនីចរន្តតាមរយៈឱនភាពពាណិជ្ជកម្ម ដោយសារតែតម្រូវការខ្ពស់នៃទំនិញមូលធន និងការនាំចូលវត្ថុធាតុដើម ដែលទាមទារឲ្យមានការអភិវឌ្ឍវិស័យផលិតកម្ម ដូចជា វិស័យកសិកម្ម និងកម្មន្តសាលក្នុងអំឡុងដំណាក់កាលដំបូងនៃការអភិវឌ្ឍសេដ្ឋកិច្ច មានលក្ខណៈសមស្រប។ យ៉ាងណាក៏ដោយ ឱនភាពគណនីចរន្តដែលនៅបន្តមាន ដោយសារតម្រូវការនាំចូលខ្ពស់ជាបន្តបន្ទាប់ដែលជំរុញតាមរយៈការប្រើប្រាស់ក្នុងប្រទេស ដែលរួមមានការវិនិយោគដែលមិនសូវទទួលបានផលក្នុងវិស័យមួយចំនួន ដូចជា សំណង់ ដីធ្លី និងអចលនទ្រព្យក្នុងលក្ខណៈមិនពិតប្រាកដ ពិតជាបង្កើនឲ្យមានភាពងាយរងគ្រោះទៅនឹងការប្រែប្រួលពីខាងក្រៅ។

[28] ប្រអប់ 7.1 ៖ ដុល្លារូបនីយកម្មពេញលេញ បដិដុល្លារូបនីយកម្ម ឬតាមស្ថានភាពបច្ចុប្បន្ន? ប្រទេសកម្ពុជាកំពុងរក្សាកំណើនយ៉ាងលឿនក្នុងបរិយាកាសប្រកួតប្រជែង អនុស្សរណៈសេដ្ឋកិច្ចប្រទេស ឆ្នាំ ២០០៩ ធនាគារពិភពលោក។

[29]សម្រាប់ប្រទេសកម្ពុជា ការនាំចេញសម្លៀកបំពាក់មានចំនួន ៧៥ ភាគរយនៃការនាំចេញសរុប។

***ទីពីរ*** ការប៉ាន់ស្មានមួយចំនួនបានបង្ហាញការខាតបង់ដោយសារការបោះពុម្ពក្រដាសប្រាក់នៅចន្លោះពី ១ ទៅ ២ ពាន់លានដុល្លាអាមេរិក[30]។ ការបោះពុម្ពក្រដាសប្រាក់គឺជាការចំណេញ (ឬការខាតបង់) ដោយសារការចរាចរណ៍រូបិយប័ណ្ណ ដកនឹងចំណាយក្នុងការផលិតរូបិយប័ណ្ណនោះ។ ការខាតបង់លើការបោះពុម្ពក្រដាសប្រាក់មានបីប្រភេទ (Kang ឆ្នាំ ២០០៥)[31] ៖(១) ការខាតបង់ដោយផ្ទាល់ពីការឈប់បោះពុម្ពក្រដាសប្រាក់ ដោយសារតែការអនុញ្ញាតឲ្យមានចរាចរណ៍ប្រាក់ដុល្លាអាមេរិកដោយសេរី (២) ការខាតបង់ប្រចាំឆ្នាំក្នុងការបោះពុម្ពប្រាក់ ដោយសារតែការអសមត្ថភាពក្នុងការបញ្ចូលប្រាក់ ដើម្បី "គ្មានឥទ្ធិពលដល់អតិផរណា"[32] និង (៣) ការបាត់ចំណូលពីការប្រាក់របស់ធនាគារជាតិ ដោយសារតែការមិនអាចប្រមូល ឬឲ្យខ្ចីប្រាក់ដុល្លា ដែលកំពុងធ្វើ ចរាចរណ៍។ ដើម្បីដឹងអំពីចំនួននៃការខាតបង់ពីការបោះពុម្ពក្រដាសប្រាក់ យើងត្រូវកំណត់អំពីចំនួនសាច់ប្រាក់ដុល្លាអាមេរិកដែលកំពុងចរាចរណ៍ និងមិនបានកត់ត្រាដែលបញ្ហានេះពិបាកនឹងធ្វើការប៉ាន់ស្មានឲ្យបានត្រឹមត្រូវណាស់។ ការប៉ាន់ស្មានចំនួនទឹកប្រាក់នេះមានភាពខុសៗគ្នាដូចមានបង្ហាញក្នុងតារាង S1-1 ហើយចំនួនទឹកប្រាក់ទាំងនោះមានចំនួនច្រើន។

**តារាង S1-1 – ការប៉ាន់ស្មានផ្សេងៗអំពីប្រាក់ដុល្លាអាមេរិកដែលកំពុងធ្វើចរាចរណ៍នៅកម្ពុជានៅក្នុងឆ្នាំផ្សេងៗ**

| (គិតជាពាន់លានដុល្លា) | Kang (2003) | Im and Dabadie (2006) | Feige (2006) | Article IV (2010) |
|---|---|---|---|---|
| ប្រាក់ដុល្លាអាមេរិកដែលកំពុងធ្វើចរាចរណ៍ | *1.01 | 3.5 | 2.00 | - |
| (ចេញពី) ការបាត់បង់ដោយសារតែរូបិយប័ណ្ណ | 0.75 | 2.7 | 2.02 (2010) | 1.23 |

ប្រភព៖
តើដុល្លារូបនីយកម្មល្អសម្រាប់កម្ពុជាទេ? ការពិនិត្យសេដ្ឋកិច្ចសាកល Kiwon Kang ឆ្នាំ ២០០៥
ដុល្លារូបនីយកម្មល្អនៅកម្ពុជា Tal Nay Im និង Michel Dabadie ឆ្នាំ ២០០៧
ការប៉ាន់ស្មានថ្មីៗអំពីរូបិយប័ណ្ណអាមេរិកនៅបរទេស Edgar L. Feige ឆ្នាំ ២០១១
អត្ថបទទី IV របស់បុគ្គលិក IMF (ឆ្នាំ ២០១០) ប្រអប់ទី ២ ការបាត់បង់ដោយសារតែការបោះ ពុម្ពរូបិយប័ណ្ណអាចមាននៅចន្លោះពី ៥ ទៅ ៩ ភាគរយនៃផលិតផលក្នុងស្រុកសរុប (ចំណុចកណ្តាល ១៤ ភាគរយនៃ ផសស ឬ ១,២៣ ពាន់លានដុល្លាអាមេរិក) ប៉ាន់ស្មានដោយផ្អែកលើរូបិយប័ណ្ណដែលកំពុងធ្វើចរាចរណ៍ធៀបនឹងប្រទេសដែលមាន ចំណូលទាបនៅអាស៊ី។
+ ការប្រើប្រាស់វិធីសាស្ត្ររបស់ Kang ក្នុងការប៉ាន់ស្មានអំពីដុល្លាអាមេរិកដែលកំពុង ធ្វើចរាចរណ៍ក្នុងឆ្នាំ ២០១៣

***ទីបី*** **ដុល្លារូបនីយកម្ម និងការកំណត់អត្រាប្តូរប្រាក់ អាចមិនរក្សាកម្រិតតម្លៃទំនិញ បានល្អដូចការគិតឡើយ។** អត្រាអតិផរណារបស់ប្រទេសកម្ពុជាមានការប្រែប្រួលខ្លាំង ដូចជា អត្រាអតិផរណារបស់ប្រទេសវៀតណាមដែរ (រូបលេខ S1.4) ហើយអត្រានេះមិនប្រសើរជាងប្រទេសក្នុងតំបន់ឡើយ។ នៅពេលកើតមានវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៨ អត្រាអតិផរណារបស់ប្រទេសកម្ពុជាមានការកើនឡើងយ៉ាងលឿន ដោយសារតែអតិផរណា "នាំពីខាងក្រៅ" ដែលបណ្តាលមកពីការប្រែប្រួលតម្លៃស្បៀងអាហារពិភពលោក និងតម្លៃប្រេង។ ស្ថានភាពនេះកើតឡើងដោយសារតែមានការសម្របសម្រួលដុល្លារូបនីយកម្ម (ដោយមានចរាចរណ៍ប្រាក់រៀល និងដុល្លាអាមេរិកដោយសេរី) ចំពោះតម្លៃទំនិញនាំចូលដែលគិតជាប្រាក់ដុល្លារហូតដល់តម្លៃទំនិញដែលផលិតក្នុងប្រទេសគិតជាប្រាក់រៀល។ នេះក៏ដោយសារតែអ្នកផលិតទំនិញក្នុងប្រទេសមិនត្រឹមតែ

---

[30]ការស្ទង់មតិដែលបានពិភាក្សាក្នុងរបាយការណ៍ធនាគារអាមេរិកឆ្នាំ ២០០៦ បានបង្ហាញឲ្យឃើញថា ប្រទេសកម្ពុជាកំពុងមានសាច់ប្រាក់ ២ ពាន់លានដុល្លាអាមេរិក ឬ ០,៧ ភាគរយនៃទឹកប្រាក់សរុបចំនួន ២៨១,៧ ពាន់លានដុល្លាអាមេរិកដែលត្រូវបានចាត់ទុកជា "ទឹកប្រាក់បរទេសដែលជារូបិយប័ណ្ណអាមេរិក" ចំណែកក្នុងអំឡុងឆ្នាំ១៩៩៤-២០១០ ចំណូលពន្ធបម្រុងសហព័ន្ធអាមេរិកមានចំនួន ២៨៩ ពាន់លានដុល្លាអាមេរិក (Feige ឆ្នាំ២០១១)។ ដូច្នេះ យើងសាកសន្និដ្ឋានបានថា ប្រទេសកម្ពុជានៅតែមានទឹកប្រាក់ត្រឹមតែ ០,៧ ភាគរយនៃសាច់ប្រាក់ដុល្លាអាមេរិកសរុបក្នុងឆ្នាំ ២០១០។ នេះបង្ហាញឲ្យឃើញថា ការខាតបង់ពន្ធសម្រាប់ប្រទេសកម្ពុជាមានប្រហែល ២,០២៣ ពាន់លានដុល្លាអាមេរិក (២៨៩ ដុល្លាអាមេរិក x ០,៧ ភាគរយ) ក្នុងឆ្នាំ ២០១០។

[31]K. Kang ៖ តើដុល្លារូបនីយកម្មពិតជាល្អសម្រាប់ប្រទេសកម្ពុជាមែនដែរ ឬទេ? Seowon University ៖ ប្រទេសកូរ៉េខាងត្បូង។

[32]នៅពេលដែលវិស័យសេដ្ឋកិច្ចមានការរីកចម្រើន ចំនួននៃការចរាចរណ៍រូបិយប័ណ្ណក៏មានការកើនឡើងផងដែរ។ រដ្ឋាភិបាលអាចបោះពុម្ពក្រដាសប្រាក់ដោយមិនមានអតិផរណា ដរាបណាចំនួនទឹកប្រាក់ដែលផ្គត់ផ្គង់មិនច្រើនជាងចំនួនទឹកប្រាក់ដែលចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច។

រក្សាតម្លៃធៀបនឹងប្រាក់ដុល្លាចំពោះទំនិញរបស់ខ្លួននោះទេ ថែមទាំងរក្សាកម្លាំងទិញដែលទទួលបានពីការលក់ទំនិញរបស់ខ្លួន។ ដូច្នេះ អ្នកផលិតក្នុងប្រទេសអាច "កំណត់តម្លៃឡើង ឬចុះ" នៃទំនិញដែលផលិតក្នុងស្រុករបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ដោយធៀបនឹងតម្លៃទំនិញនាំចូល និងបង្កើនតម្លៃទំនិញរបស់ខ្លួននៅពេលទំនិញនាំចូលកាន់តែមានតម្លៃថ្លៃ ទោះបីជាអត្រាប្តូរប្រាក់រវាងប្រាក់រៀល និងប្រាក់ដុល្លានៅថេរក៏ដោយ។

រូបលេខ ៩1-4 **អតិផរណាកម្ពុជប្រែប្រួលស្មើតែដូចវៀតណាមដែរ និងមិនប្រសើរជាងថៃតូក្នុងតំបន់ច្រើនទេ.**
(ការប្រែប្រួលគិតជា % ធៀបនឹងឆ្នាំ)




ប្រភព៖ អាជ្ញាធរកម្ពុជា

*ទីបួន* លក្ខណៈសំខាន់នៃដុល្លារូបនីយកម្មគឺអត្រាប្តូរប្រាក់ថេរ (ធៀបដុល្លា និងប្រាក់រៀល)[33]។ ហេតុដូច្នេះ អាជ្ញាធរកម្ពុជា មិនអាចការពារសេដ្ឋកិច្ចរបស់ខ្លួនឲ្យរួចពីការប្រែប្រួលខាងក្រៅ តាមរយៈការគ្រប់គ្រងអត្រាប្តូរប្រាក់បានឡើយ[34]។

បទពិសោធន៍ក្នុងប្រទេសអ៊ែលសាល់វ៉ាឌ័របង្ហាញថាដុល្លារូបនីយកម្ម មិនបាននាំទៅរកអត្រាកំណើនលឿនដោយស្វ័យប្រវត្តិនោះឡើយ ដោយសារវាមិនបានជួយដល់បរិយាកាសធុរកិច្ចទន់ខ្សោយ អត្រាឧក្រិដ្ឋកម្មខ្ពស់ ឬអំពើហិង្សាឡើយ[35]។

## ៥ កិច្ចការបន្ទាប់

នៅដំណាក់កាលដំបូងនៃការអភិវឌ្ឍវិស័យធនាគារ ជាមួយនឹងអាជ្ញាធររូបិយវត្ថុដែលបានបង្កើតថ្មី សមត្ថភាពធនធានមនុស្ស និងក្របខ័ណ្ឌគតិយុត្តិដែលគ្រប់គ្រងគោលនយោបាយរូបិយវត្ថុក្នុងប្រទេសកម្ពុជានៅមានភាពទន់ខ្សោយនៅឡើយ។ ហេតុដូច្នេះ អត្ថប្រយោជន៍នៃដុល្លារូបនីយកម្មមានសារៈសំខាន់ជាងគុណវិបត្តិក្នុងអំឡុងពេលនោះ។ ដុល្លារូបនីយកម្មជួយបញ្ចៀសអតិផរណាកម្រិតខ្ពស់ខ្លាំង និងជួយទ្រទ្រង់រចនាសម្ព័ន្ធពីមុននៃពាណិជ្ជកម្មអន្តរជាតិ ដែលសហរដ្ឋអាមេរិកគឺជាទីផ្សារនាំចេញដ៏សំខាន់សម្រាប់ផលិតនាំចេញដែលមានលក្ខណៈតូចចង្អៀតរបស់ប្រទេសកម្ពុជា ដូចជា សម្លៀកបំពាក់ជាដើម។ ដោយសារតែផលិតផលនាំចេញ និងទិសដៅនាំចេញរបស់ប្រទេសកម្ពុជាមានកាន់តែច្រើន ដុល្លារូបនីយកម្មបានធ្វើឲ្យមានការកាត់បន្ថយការប្រកួតប្រជែង។

---

[33]សម្រាប់សេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងលើប្រាក់ដុល្លាអាមេរិក អាជ្ញាធរក្នុងប្រទេសច្រើនតែរក្សាតម្លៃរូបិយប័ណ្ណក្នុងស្រុករបស់ខ្លួនធៀបនឹងប្រាក់ដុល្លាដោយសារតែ (១) ប្រសិនបើពួកគេទម្លាក់តម្លៃរូបិយប័ណ្ណក្នុងស្រុក នោះសេដ្ឋកិច្ចរបស់ពួកគេនឹងពឹងផ្អែកទាំងស្រុងលើប្រាក់ដុល្លា (២) ប្រសិនបើពួកគេឲ្យតម្លៃរូបិយប័ណ្ណក្នុងស្រុកហួសហេតុ នោះពួកគេនឹងបាត់បង់ទុនបម្រុងអន្តរជាតិរបស់ខ្លួន។

[34] Kang (ឆ្នាំ២០០៣) អះអាងថា បច្ចុប្បន្ននេះ ទំនិញភាគច្រើនត្រូវបានផលិត (និងនាំចូល) និងលក់ (និងនាំចេញដោយដាក់តម្លៃជាប្រាក់ដុល្លា អាមេរិក។ ក្នុងស្ថានភាពដែលប្រតិបត្តិការជាង ៧០ ភាគរយ ប្រើប្រាស់ប្រាក់ដុល្លាអាមេរិក អត្រាប្តូរប្រាក់ (ប្រាក់រៀល និងប្រាក់ដុល្លា) ហាក់បាត់បង់តម្លៃដើមរបស់ខ្លួនភាគច្រើន។

[35]សិក្ខាសាលាស្តីពីបដិដុល្លារូបនីយកម្ម (ឆ្នាំ ២០១៤) បទពិសោធន៍ដុល្លារូបនីយកម្ម និងបដិដុល្លារូបនីយកម្មក្នុង LAC. Auguste Kouame. ធនាគារពិភពលោក។

ប៉ុន្តែឧបសគ្គដែលបង្កឡើងដោយដុល្លារូបនីយកម្ម កំពុងតែមានលក្ខណៈកាន់តែច្បាស់ចំពោះការគ្រប់គ្រងវិស័យធនាគារ និងហិរញ្ញវត្ថុដែលកំពុងតែរីកចម្រើនយ៉ាងលឿនរបស់ប្រទេសកម្ពុជា។ ហេតុដូច្នេះ ប្រការសំខាន់ត្រូវស្តារសមត្ថភាពរបស់ធនាគារជាតិ ក្នុងការផ្តល់ប្រាក់កម្ចីចុងក្រោយក្នុងករណីមានការប្រែប្រួលភ្លាមៗ។ អនុបាតទុនបម្រុងអន្តរជាតិដុលធៀបនឹងប្រាក់បញ្ញើរបស់វិស័យឯកជនបានឈានដល់កម្រិតទាបបំផុតត្រឹម ៥៣ ភាគរយកាលពីខែធ្នូ ឆ្នាំ ២០១៤ ដោយថយចុះពី ១០៣ ភាគរយក្នុងខែធ្នូ ឆ្នាំ២០០៥ ដែលបានកាត់បន្ថយសមត្ថភាពរបស់ធនាគារជាតិ ក្នុងការរក្សាស្ថិរភាពប្រព័ន្ធធនាគារនៅពេលជួបវិបត្តិហិរញ្ញវត្ថុ។ ប្រទេសផ្សេងទៀតក៏បានប្រឹងប្រែងរិតត្បិតកម្រិតនៃដុល្លារូបនីយកម្មផងដែរ ដោយសារតែផលប៉ះពាល់ដែលអាចកើតមានឡើងលើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ (Kokenyne, Ley និង Veyrune ឆ្នាំ ២០១០)។

**"នៅពេលដែលដុល្លារូបនីយកម្មចាក់គ្រឹះ ភ្នាក់ងារសេដ្ឋកិច្ចមានភាពស្ទាក់ស្ទើរក្នុងការផ្លាស់ទៅរកការប្រើប្រាស់រូបិយប័ណ្ណក្នុងប្រទេស ដោយសារតែពួកគេមិនមានការជឿទុកចិត្ត ហើយការចំណាយលើប្រតិបត្តិការកំណត់តម្លៃផ្លូវការសាជាថ្មី មានកម្រិតខ្ពស់រហូតដល់ត្រូវមានការព្រមព្រៀងក្នុងចំណោមអ្នកចូលរួមក្នុងទីផ្សារលើការប្រើប្រាស់រូបិយប័ណ្ណក្នុងប្រទេស"** (Kokenyne, Ley និង Veyrune ឆ្នាំ ២០១០)។ ក្រៅពីនេះ ដំណើរការសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងការជឿទុកចិត្តរបស់វិនិយោគិន ធ្វើឲ្យមានកំណើនដុល្លារូបនីយកម្ម ជាជាងកាត់បន្ថយ ដោយសារតែកម្ពុជាទាក់ទាញឲ្យមានលំហូរមូលធនយ៉ាងច្រើន (Menon ឆ្នាំ ២០០៨ និង Duma ឆ្នាំ ២០១១)។ ទំនាក់ទំនងទន់ខ្សោយរវាងដុល្លារូបនីយកម្មនៃប្រាក់បញ្ញើ (និងដុល្លារូបនីយកម្មឥណទាន) ជាមួយអត្រាប្តូរប្រាក់រៀល នឹងប្រាក់ដុល្លាជាក់ស្តែង ក៏ជួយបញ្ជាក់ពីបញ្ហានេះដែរ[36]។ ស្ថានភាពនេះបង្ហាញថា ដុល្លារូបនីយកម្មក្នុងប្រទេសកម្ពុជានឹងនៅតែកើតមាន ប្រសិនបើមិនមានការដោះស្រាយទេនោះ។

**ការបង្កើតផែនទីចង្អុលបង្ហាញផ្លូវដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀល ដូចដែលអាជ្ញាធរបានរៀបចំផែនការនាពេលថ្មីៗនេះ គឺជាវិធានការវិជ្ជមានមួយ។** ទីមួយ ការកំណត់ (១) ក្របខ័ណ្ឌរូបិយវត្ថុ ពោលគឺការកំណត់អតិផរណា ឬការកំណត់អត្រាប្តូរប្រាក់ (សំដៅទៅរូបិយប័ណ្ណមួយចំនួនដែលត្រូវផ្តោត ទន្ទឹមនឹងការកាត់បន្ថយការគ្មានស្ថិរភាពវិស័យពាណិជ្ជកម្ម) គឺជាការសមស្របបំផុត និង (២) របៀបបង្កើនទំនុកចិត្តក្នុងក្របខ័ណ្ឌនេះ។ ទីពីរ បន្តពង្រឹងសមត្ថភាពក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុឲ្យបានត្រឹមត្រូវ។ ទីបី ការរៀនសូត្រពីបទពិសោធន៍របស់ប្រទេសមួយចំនួនដែលទទួលបានជោគជ័យ[37]។ សូមមើលតារាង S1-2

[36]ដុល្លារូបនីយកម្មមានពីរប្រភេទ ៖ (1) ដុល្លារូបនីយកម្មប្រាក់បញ្ញើដែលវាស់វែងតាមរយៈប្រាក់បញ្ញើជាប្រាក់ដុល្លាអាមេរិកជាភាគរយនៃប្រាក់បញ្ញើសរុប និង (2) ដុល្លារូបនីយកម្មឥណទានដែលវាស់វែងតាមរយៈឥណទានជាប្រាក់ដុល្លាអាមេរិកជាភាគរយនៃឥណទានសរុប ឬការទម្លាក់តម្លៃ ប្រាក់រៀលធ្វើឲ្យមានការចាប់អារម្មណ៍កាន់តែច្រើនលើប្រាក់ដុល្លាអាមេរិក និងធ្វើឲ្យមានកំណើនដុល្លារូបនីយកម្ម។ ទំនាក់ទំនងរវាងដុល្លារូបនីយកម្មប្រាក់បញ្ញើ និងដុល្លារូបនីយកម្មឥណទានជាមួយអត្រាប្តូរប្រាក់ធម្មតាដែលមានត្រឹមតែ ០,៤៧ ភាគរយនៃដុល្លារូបនីយកម្មប្រាក់បញ្ញើ និង ០,២៤ ភាគរយនៃដុល្លារូបនីយកម្មឥណទាន មានន័យថា ការប្រែប្រួលអត្រាប្តូរប្រាក់ជាក់ស្តែង (ឡើង ឬចុះ) នឹងប៉ះពាល់តែមួយផ្នែក (ចុះ ឬឡើង) លើដុល្លារូបនីយកម្មប្រាក់បញ្ញើ និងដុល្លារូបនីយកម្មឥណទាន។

[37]ប្រទេសជាច្រើននៅអាមេរិកឡាទីន និងអឺរ៉ុបខាងកើត ដូចជា ប៉េរូ ប៉ារ៉ាហ្គាយ អ៊ុយរុយហ្គាយ បូលីវី អាមេនី និងហ្សកហ្ស៊ី មានការវិវឌ្ឍជាច្រើនឆ្ពោះទៅរកបដិដុល្លារូបនីយកម្ម។

សម្រាប់ខ្លឹមសារសង្ខេបពីទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដែលជំរុញឲ្យមានបដិដុល្លាវូបនីយកម្ម[38]។ វិធានការសំខាន់ៗ ការបង្កើតទីផ្សារមូលធនរូបិយប័ណ្ណក្នុងស្រុក ជាមួយនឹងទីផ្សារប្តូរប្រាក់បរទេស និងការបង្កើនថ្លៃអត្រាប្តូរប្រាក់ ជំរុញឲ្យមានបដិដុល្លាវូបនីយកម្ម[39]។ ការធានាច្បាស់លើអត្រាប្តូរប្រាក់ដែលមានស្ថិរភាពអាចបែរជាជួយបង្កើនដុល្លាវូបនីយកម្ម តាមរយៈការជំរុញឲ្យមានកម្ចីជាប្រាក់ដុល្លាអាមេរិក។

## តារាង S1-2 ៖ កត្តាសំខាន់ៗដែលជំរុញបដិដុល្លាវូបនីយកម្ម

| ប្រទេស | ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ | បទប្បញ្ញត្តិសំខាន់ៗសម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ | បដិដុល្លាវូបនីយកម្មប្រាក់បញ្ញើ និងបដិដុល្លាវូបនីយកម្មឥណទាន |
|---|---|---|---|
| ប្រទេសប៉េរូ | • គុណភាពសារពើពន្ធមានភាពល្អប្រសើរ<br>• កាត់បន្ថយបំណុលពី ៤៨,២ ភាគរយ មកត្រឹម ១៩,៦ ភាគរយនៃផសស<br>• ការឡើងតម្លៃអត្រាប្តូរប្រាក់<br>• អន្តរាគមន៍ទីផ្សារប្តូរប្រាក់បរទេស<br>• ទុនបម្រុងអន្តរជាតិមានភាពល្អប្រសើរ<br>• ការបង្កើតទីផ្សារមូលធនជារូបិយប័ណ្ណក្នុងប្រទេស<br>• ការកំណត់អតិផរណា | • គម្លាតយ៉ាងធំរវាងលក្ខខណ្ឌទុនបម្រុងជារូបិយប័ណ្ណបរទេស និងរូបិយប័ណ្ណក្នុងប្រទេស<br>• អត្រាលាភការធៀបនឹងលក្ខខណ្ឌទុនបម្រុងមានការកើនឡើងចំពោះរូបិយប័ណ្ណក្នុងប្រទេសលើសរូបិយប័ណ្ណបរទេស<br>• ការផ្តល់លក្ខខណ្ឌតម្រូវសម្រាប់កម្ចីជារូបិយប័ណ្ណបរទេស បង្កើនទុនបម្រុងពី ០,២៥ ភាគរយ ទៅ ១ ភាគរយ នៃឥណទានជារូបិយប័ណ្ណបរទេស<br>• សន្ទនីយភាពទ្រព្យជារូបិយប័ណ្ណក្នុងប្រទេសគឺ ៨ ភាគរយ ចំណែកសន្ទនីយភាពទ្រព្យជារូបិយប័ណ្ណបរទេសគឺ ២០ ភាគរយ<br>• គោលការណ៍បើកចំហររយៈពេលវែងរបស់ធនាគារ ធ្លាក់ចុះពី ១០០ ភាគរយ មកត្រឹម ៧៥ភាគរយ នៃមូលធន | • ដុល្លាវូបនីយកម្មឥណទានចំនួន ៤០ភាគរយ (ឆ្នាំ ២០១៤) ធ្លាក់ចុះពី ៨២ ភាគរយ(ឆ្នាំ១៩៩២)<br>• ដុល្លាវូបនីយកម្មប្រាក់បញ្ញើចំនួន ៣២ ភាគរយ (ឆ្នាំ ២០១៤) ធ្លាក់ចុះពី៦៣ភាគរយ (ឆ្នាំ១៩៩២) |
| ប្រទេសបូលីវី | • ការឡើងថ្លៃជាក់ស្តែង (Bs/USD) 7.0 (2013) vs 7.5 (2002)<br>• ការឡើងថ្លៃពិត (2005=100): 69.0 (2013) vs 83.0 (2002)<br>• គុណភាពសារពើពន្ធ (% នៃ ផសស ): 0.7% (2013) ធៀបនឹង - 8.8% (2002)<br>• ការថយចុះនៃបំណុលសាធារណៈ (% នៃ ផសស): 37.3% (2013) ធៀបនឹង 84.8% (2002)<br>• កំណើនទុនបម្រុងបរទេស (%នៃ ផសស ): 47.6 (2013) ធៀបនឹង 11.3 (2002)<br>• ការបង្កើតទីផ្សារមូលធនជារូបិយប័ណ្ណក្នុងស្រុក<br>• អតិផរណា 6.5 (2013) vs 2.4 (2002) | • គម្លាតអត្រាប្តូរប្រាក់កាន់តែខ្ពស់ពី ១ ទៅ ១០ សេន<br>• ពន្ធ ០,៣ ភាគរយ លើប្រតិបត្តិការហិរញ្ញវត្ថុជាប្រាក់ដុល្លា<br>• ទុនបម្រុងសំខាន់ខ្ពស់លើប្រាក់បញ្ញើជាប្រាក់ដុល្លាពីប្រហែល ១០ភាគរយ មកត្រឹម ៦៧ភាគរយ ក្នុងឆ្នាំ២០០<br>• ការផ្តល់កម្ចីរូបិយប័ណ្ណបរទេសរហូតដល់ ១,៥ ភាគរយ<br>• គោលការណ៍បើកចំហររយៈពេលវែងរបស់ធនាគារ ធ្លាក់ចុះពី ៧០ភាគរយ មកត្រឹម ៦០ ភាគរយ | • ដុល្លាវូបនីយកម្មឥណទានចំនួន ១១ ភាគរយ (ឆ្នាំ ២០១៣) ធ្លាក់ចុះពី៧៤ភាគរយ (ឆ្នាំ១៩៩៦)<br>• ដុល្លាវូបនីយកម្មប្រាក់បញ្ញើចំនួន ២៣ភាគរយ (ឆ្នាំ២០១៣) ថយចុះ៩៤ ភាគរយ (ឆ្នាំ១៩៩៧) |

ប្រភព ៖ ធនាគារពិភពលោក សិក្ខាសាលាស្តីពីបដិដុល្លាវូបនីយកម្ម (២០១៤) និងបទពិសោធន៍ដុល្លាវូបនីយកម្ម និងបដិដុល្លាវូបនីយកម្មក្នុង LAC. AugusteKouame។

[38]ឯកសារការងាររបស់IMF(២០១១) ៖ តើអ្វីដែលជំរុញឲ្យមានបដិដុល្លាវូបនីយកម្មហិរញ្ញវត្ថុនៅអាមេរិកឡាទីន? Mercedes Garcia-Escribaoនិង Sebastian Sosa។

[39]Hayk Avertisyan (ឆ្នាំ ២០១៤) គោលនយោបាយបដិដុល្លាវូបនីយកម្មក្នុងប្រទេសអាមេនី ៖ ឱកាសសម្រាប់ការតាក់តែងគោលនយោបាយ ៖ សិក្ខាសាលាស្តីពីគោលនយោបាយបដិដុល្លាវូបនីយកម្ម និងបញ្ហាប្រឈម មជ្ឈមណ្ឌលស្រាវជ្រាវនៃធនាគារជាតិរបស់ប្រទេសអាមេនី ថ្ងៃទី ១២-១៣ ខែធ្នូ ឆ្នាំ ២០១៤ ទីក្រុង Diligan ប្រទេសអាមេនី។

# សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា

| | 2011<br>ឆ្នាំ | 2012<br>ឆ្នាំ | 2013<br>ឆ្នាំ | 2014e<br>ឆ្នាំ | 2015p<br>ឆ្នាំ | 2016f<br>ឆ្នាំ | 2017f<br>ឆ្នាំ |
|---|---|---|---|---|---|---|---|
| **ទិន្នផល តម្រូវការក្នុងស្រុក និងតម្លៃ** | | | | | | | |
| ផលិតផលក្នុងស្រុកសរុបពិត (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.1 | 7.3 | 7.4 | 7.0 | 6.9 | 6.9 | 6.8 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 11.3 | 14.9 | 12.1 | 12.4 | 11.0 | 10.7 | 11.1 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ចុងគ្រា-% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 4.9 | 2.5 | 4.6 | 1.2 | 1.5 | 2.0 | 2.0 |
| **វិស័យសាធារណៈ** | | | | | | | |
| ប្រាក់ចំណូលរបស់រដ្ឋាភិបាល (% ផសស) | 13.2 | 15.3 | 15.1 | 16.1 | 16.0 | 16.3 | 16.8 |
| ការចំណាយរបស់រដ្ឋាភិបាល (% ផសស) | 22.8 | 21.0 | 21.5 | 20.4 | 20.5 | 20.5 | 21.0 |
| តុល្យភាពចំណាយរបស់រដ្ឋាភិបាលមិនគិតជំនួយឥតសំណង(% ផសស) | -9.6 | -5.7 | -6.4 | -4.3 | -4.5 | -4.2 | -4.2 |
| តុល្យភាពចំណាយរបស់រដ្ឋាភិបាលគិតទាំងជំនួយឥតសំណង (% ផសស) | -4.6 | -3.3 | -2.7 | -2.5 | -3.8 | -4.9 | -4.7 |
| **ពាណិជ្ជកម្មក្រៅប្រទេស ជញ្ជីងទូទាត់ និងបំណុលបរទេស** | | | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លាអាមេរិក) | -1,490.0 | -2,455.7 | -2,598.4 | -3,010.7 | -3,345.9 | -3,606.9 | -3,897.3 |
| ការនាំចេញទំនិញ (លានដុល្លាអាមេរិក) | 5,219.5 | 5,632.8 | 6,890.2 | 7,569.1 | 8,397.7 | 9,487.2 | 10,768.0 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 34.4 | 7.9 | 22.3 | 9.9 | 10.9 | 13.0 | 13.5 |
| ការនាំចេញសំខាន់ៗ(%ប្រែប្រួលធៀបនឹងឆ្នាំមុន) 1/ | 31.7 | 7.0 | 17.6 | 11.7 | 12.0 | 14.0 | 14.0 |
| ការនាំចូលទំនិញ (លានដុល្លាអាមេរិក) | 6,709.5 | 8,088.5 | 9,488.6 | 10,579.8 | 11,743.6 | 13,094.1 | 14,665.4 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 22.7 | 20.6 | 17.3 | 11.5 | 11.0 | 11.5 | 12.0 |
| តុល្យភាពគណនីចរន្ត (លានដុល្លាអាមេរិក) 2/ | -881.9 | -1,366.0 | -1,639.0 | -1,853.2 | -2,157.7 | -2,259.9 | -2,441.0 |
| (% ផសស) | -6.8 | -9.6 | -10.7 | -11.2 | -11.7 | -11.6 | -10.9 |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លាអាមេរិក) | 1,343.8 | 1,697.9 | 1,826.1 | 1,717.4 | 1,660.0 | 1,620.0 | 1,590.0 |
| បំណុលបរទេស (លានដុល្លាអាមេរិក) | 3,913.4 | 4,559.3 | 5,124.1 | 5,630.6 | 6,019.1 | 6,380.5 | 6,692.7 |
| (% ផសស) | 30.4 | 32.1 | 33.4 | 33.9 | 32.7 | 32.9 | 29.9 |
| អនុបាតសេវាបំណុល (% នៃការនាំចេញទំនិញ និងសេវា) | 1.1 | 1.1 | 1.1 | 1.3 | 1.3 | 1.6 | 1.4 |
| ទុនបម្រុងរូបិយប័ណ្ណបរទេសដុល (លានដុល្លាអាមេរិក) | 3,031.6 | 3,463.0 | 3,642.5 | 4,657.9 | 5,120.0 | 5,530.0 | 5,960.0 |
| (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | 3.4 | 3.1 | 3.5 | 4.0 | 3.9 | 3.8 | 3.7 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | | | |
| ឥណទានក្នុងប្រទេស (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 37.3 | 29.6 | 26.7 | 28.7 | 27.0 | 25.8 | 25.0 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ) | 15.3 | 11.6 | 11.3 | 11.5 | 12.0 | 12.2 | 11.8 |
| អត្រាប្តូរប្រាក់ (ប្រាក់រៀល/ដុល្លាអាមេរិក-ចុងគ្រា) | 4,039.0 | 3,995.0 | 3,995.0 | 4,075.0 | 4,050.0 | 4,050.0 | 4,080.0 |
| អត្រាប្តូរប្រាក់ពិត (2010=100) | 104.9 | 105.4 | 109.9 | 112.1 | 113.5 | 115.5 | 117.8 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 4.9 | 0.5 | 4.3 | 2.0 | 1.3 | 1.7 | 2.0 |
| ចំណាំ ៖ ផសសធម្មតា (លានដុល្លាអាមេរិក) | 12,891 | 14,188 | 15,362 | 16,600 | 18,381 | 19,409 | 22,388 |

ប្រភព ៖ អាជ្ញាធរកម្ពុជានិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

e= ប៉ាន់ស្មាន

f = ព្យាករណ៍

p = ព្យាករណ៍ (គណនា)

1/ សម្លៀកបំពាក់

2/ មិនគិតបង្វែរផ្លូវការ

WORLD BANK GROUP

ធនាគារពិភពលោក
ការិយាល័យប្រចាំប្រទេសកម្ពុជា
ផ្ទះលេខ មហាវិថីនរោត្តម ១១៣
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៨៦១ ៣០០
ទូរសារ ៖ (៨៥៥-២៣) ៨៦១ ៣០១/៣០២
គេហទំព័រ ៖www.worldbank.org/cambodia